

# ការលើកកម្ពស់បរិយាបន្នពិការភាព សមធម៌ និងសិទ្ធិជនមានពិការភាព នៅកម្ពុជា៖ ឯកសារសម្រាប់រៀបចំសកម្មភាព

ខែ តុលា ឆ្នាំ ២០២៤

រូបថតគម្របខាងមុខត្រូវបានថតដោយ អង្គការ ICRC ស្តីពី អត្តពលិករទេះរុញជាស្ត្រីដែលចូលរួមក្នុងវគ្គហ្វឹកហាត់អត្តពលិកកីឡាបាល់បោះរទេះជនពិការកម្ពុជា។

គំនូរតូចៗនៅក្នុងឯកសារនេះដកស្រង់ចេញពីគោលការណ៍ណែនាំ CBR របស់អង្គការសុខភាពពិភពលោក លើកលែងតែមានការបញ្ជាក់ផ្ទុយពីនេះ។

# មាតិកា


**អក្សរកាត់ និងពាក្យបំព្រួញ** ........ iii

**សេចក្តីសង្ខេប** ........ ១

**ផ្នែកទី ១ ៖ សេចក្តីផ្តើម** ........ ៤

១.១ សេចក្តីផ្តើម និងបរិបទ ........ ៤

១.២ គោលបំណងនៃឯកសារនេះ ........ ៥

**ផ្នែកទី ២ ៖ ការលើកកម្ពស់ការយល់ដឹងអំពីបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព** ........ ៧

២.១ និយមន័យនៃពិការភាព ........ ៧

២.២ ពីគំរូបែបសប្បុរសធម៌ទៅជាគំរូផ្អែកលើសិទ្ធិ ........ ៧

២.៣ តើអ្វីទៅជាបរិយាបន្នពិការភាព? ........ ៨

២.៤ គោលការណ៍បរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព ........ ៩

២.៥ ឧបសគ្គរាំងបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព ........ ៩

ការមាក់ងាយ និងការរើសអើង ........ ១០

លទ្ធភាពទទួលបានសេវា និងឱកាស ........ ១០

ការយល់ដឹងអំពីបរិយាបន្នប្រកបដោយអត្ថន័យនៅមានកម្រិត ........ ១០

កង្វះការយល់ដឹងអំពីសិទ្ធិ សេវា និងឱកាសដែលមាន ........ ១១

វិភាជថវិកាមិនគ្រប់គ្រាន់ ........ ១១

២.៦ ការសម្រេចបានបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព ........ ១១

ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយបែបបរិយាបន្ន ........ ១១

អភិក្រមផ្លូវភ្លោះ ........ ១២

ការផ្លាស់ប្តូរសង្គម និងឥរិយាបថ ........ ១២

ភាសាបែបបរិយាបន្ន ........ ១៣

ការរៀបចំផែនការ ការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំថវិកាបែបបរិយាបន្ន ........ ១៤

ការប្រមូលទិន្នន័យ/ការពិនិត្យតាមដាន និងវាយតម្លៃ ........ ១៥

ការអភិវឌ្ឍប្រកបដោយបរិយាបន្នពិការភាព ........ ១៦

**ផ្នែកទី ៣ ៖ សកម្មភាពអាទិភាពដើម្បីពង្រឹងបរិយាបន្នពិការភាព** ........ ១៨

៣.១ ការងារ និងសន្តិសុខសេដ្ឋកិច្ច ........ ១៨

៣.២ សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព ........ ២២

៣.៣ ការអប់រំ និងបំណិនជីវិត ........ ២៦

៣.៤ កិច្ចគាំពារសង្គម និងកម្រិតជីវភាពសមរម្យ ........ ២៩

៣.៥ សហគមន៍ដែលមានបរិយាបន្ន និងការបង្កលក្ខណៈងាយស្រួល ........ ៣១

៣.៦ សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌ ........ ៣៧

៣.៧ ស្ថានភាពហានិភ័យ និងការប្រែប្រួលអាកាសធាតុ ........ ៤០

**ផ្នែកទី ៤ ៖ ផ្លូវឆ្ពោះទៅរកការពង្រឹងបរិយាបន្នពិការភាពនៅថ្នាក់ក្រោមជាតិ ..................................... ៤៣**
៤.១ ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត ..................................... ៤៣
៤.២ ក្រុមប្រឹក្សាឃុំ/សង្កាត់ ..................................... ៤៤
៤.៣ ដំណើរការកំណត់អត្តសញ្ញាណជនមានពិការភាព ..................................... ៤៤
៤.៤ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ..................................... ៤៦
៤.៥ កម្មវិធីវិនិយោគឃុំ/សង្កាត់ ..................................... ៤៨
៤.៦ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ ..................................... ៥០
៤.៧ ការិយាល័យច្រកចេញចូលតែមួយ ..................................... ៥១
៤.៨ បន្ទប់ផ្តល់សេវាចម្រុះ ..................................... ៥១
**ផ្នែកទី ៥ ៖ សេចក្តីសន្និដ្ឋាន និងជំហ៊ានបន្ទាប់ ..................................... ៥៣**
៥.១ សេចក្តីសន្និដ្ឋាន ..................................... ៥៣
៥.២ ជំហ៊ានបន្ទាប់ ..................................... ៥៤
**ឧបសម្ព័ន្ធ ..................................... ៥៦**
ឧបសម្ព័ន្ធ ១ ៖ និយមន័យពាក្យគន្លឹះដើម្បីពង្រឹងការយល់ដឹង ..................................... ៥៦
ឧបសម្ព័ន្ធ ២ ៖ អ្នកពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ..................................... ៥៨
ឧបសម្ព័ន្ធ ៣ ៖ ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយទូលំទូលាយ ដើម្បីលើកកម្ពស់បរិយាបន្នពិការភាព ..................................... ៦៥
ឧបសម្ព័ន្ធ ៤ ៖ ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ដើម្បីលើកកម្ពស់បរិយាបន្នពិការភាព ..................................... ៦៨
ឧបសម្ព័ន្ធ ៥ ៖ ភាសាដែលមានបរិយាបន្នពិការភាព ..................................... ៧០
ឧបសម្ព័ន្ធ ៦ ៖ បញ្ជីត្រួតពិនិត្យសម្រាប់កិច្ចប្រជុំ សន្និសីទ និងព្រឹត្តិការណ៍ផ្សេងៗដែលបង្កលក្ខណៈងាយស្រួល ..................................... ៧២
ឧបសម្ព័ន្ធ ៧ ៖ បញ្ជីឈ្មោះអង្គការ និងអ្នកផ្តល់សេវាដែលបានជ្រើសរើសដែលធ្វើការនៅថ្នាក់ក្រោមជាតិ ...... ៧៣
ឧបសម្ព័ន្ធ ៨ ៖ ធនធាន និងឯកសារណែនាំដែលបានជ្រើសរើស ..................................... ៧៥

# អក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ACCESS 2 | កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាពនិងសមធម៌ ដំណាក់កាលទី២ |
| CBID | ការអភិវឌ្ឍសហគមន៍តាមបែបបរិយាបន្ន |
| CBM | Christian Blind Mission |
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CDP | ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ |
| CDPO | អង្គការជនពិការកម្ពុជា |
| CIP | កម្មវិធីវិនិយោគឃុំ/សង្កាត់ |
| CRPD | អនុសញ្ញាស្តីពីសិទ្ធិជនពិការ |
| CSDGs | ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ |
| CSL | ភាសាសញ្ញាកម្ពុជា |
| C/SWG | ក្រុមការងារឃុំ/សង្កាត់សម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងជនងាយរងគ្រោះ |
| DAC | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| DAC-SG | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ |
| DAWG | ក្រុមការងារសកម្មភាពជនពិការ |
| DDAC | ក្រុមប្រឹក្សាសកម្មភាពជនពិការស្រុក |
| DFAT | ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី |
| DIDRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយប្រកបដោយបរិយាបន្នពិការភាព |
| Disability ID | ការកំណត់អត្តសញ្ញាណជនមានពិការភាព |
| DMIS | ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព |
| DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| GBV | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| GPCC | ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា |
| HEF | មូលនិធិសមធម៌សុខាភិបាល |
| HMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល |
| ICRC | គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម |
| IDPoor | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| IEC | ព័ត៌មាន ការអប់រំ និងទំនាក់ទំនង |
| IO | អង្គការអន្តរជាតិ |
| M&E | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoInf | ក្រសួងព័ត៌មាន |
| MoI | ក្រសួងមហាផ្ទៃ |
| MoLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | |
|---|---|
| MoP | ក្រសួងផែនការ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | ក្រសួងកិច្ចការនារី |
| NAP-DRR | ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០២៤-២០២៨ |
| NAPVAW | ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NDSP | ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព |
| NDSP2 | ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ |
| NDSP3 | ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០២៤-២០២៨ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSAF | មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ) |
| NSPC | ក្រុមប្រឹក្សាជាតិគាំពារសង្គម |
| NSPPF | ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម |
| OPD | អង្គការតំណាងជនមានពិការភាព |
| OSSU | បន្ទប់ផ្តល់សេវាចម្រុះ |
| OWSO | ការិយាល័យច្រកចេញចូលតែមួយ |
| PAfID | អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍបរិយាបន្ន |
| PDAC | ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត |
| PoSVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| PRC | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា |
| PWDF | មូលនិធិជនពិការ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SRHR | សិទ្ធិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ |
| SPOT | សំណុំឯកសារអនឡាញសម្រាប់កិច្ចគាំពារសង្គម |
| TPO | អង្គការចិត្តសង្គមអន្តរវប្បធម៌ |
| TVET | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ) |
| UHC | ការគ្របដណ្តប់សុខភាពជាសកល |
| UN | អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ |
| UNFPA | មូលនិធិប្រជាជននៃអង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) |
| UNOHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| UNWOMEN | អង្គការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី |
| VTC | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ |
| VWG | ក្រុមការងារភូមិ |
| WASH | ទឹកស្អាត និងអនាម័យ |
| WHO | អង្គការសុខភាពពិភពលោក |
| WWDF | វេទិកាស្ត្រីមានពិការភាព |

# សេចក្ដីសង្ខេប

ក្នុងរយៈពេលជាងពីរទសវត្សរ៍មកនេះ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានចាត់វិធានការសំខាន់ៗជាច្រើនដើម្បីលើកកម្ពស់សិទ្ធិ បរិយាបន្ន និងសុខុមាលភាពរបស់ជនមានពិការភាព និងកុមារមានពិការភាព ព្រមទាំងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានសេវា និងឱកាសប្រកបដោយសមធម៌។ ទោះបីជាមានវឌ្ឍនភាពសំខាន់ៗជាច្រើនក៏ដោយ ប៉ុន្តែជនមានពិការភាពនៅតែប្រឈមនឹងឧបសគ្គជាច្រើនក្នុងការទទួលបានសេវា និងឱកាសផ្សេងៗដែលរាំងស្ទះរាល់ការចូលរួមចំណែកលើកកម្ពស់សុខុមាលភាព និងសមត្ថភាពរបស់ពួកគេដើម្បីចូលរួមពេញលេញនៅក្នុងសកម្មភាពសហគមន៍។ ឧបសគ្គទាំងនេះបានកម្រិតសមត្ថភាពរបស់ពួកគេក្នុងការរួមចំណែកដល់សេដ្ឋកិច្ច ឬទទួលបានអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ចរបស់ប្រទេស។

ក្នុងដំណាក់កាលទីមួយនៃកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្ដល់សេវាប្រកបដោយ និរន្តរភាព និងសមធម៌ (ACCESS) ដែលផ្ដល់មូលនិធិដោយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) ឯកសារជាច្រើនត្រូវបានរៀបចំបង្កើតឡើង ហើយការបណ្ដុះបណ្ដាលជាច្រើនត្រូវបានផ្ដល់និងរៀបចំ ក្នុងគោលបំណងបង្កើនការយល់ដឹងអំពីបញ្ហានានា ដូចជា ច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ឆ្នាំ២០០៩ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព (NDSP) ផាសុកវត្ថុ និងកិច្ចគាំពារសង្គម។ សៀវភៅណែនាំលម្អិតសម្រាប់ការបណ្ដុះបណ្ដាលក៏ត្រូវបានបង្កើតឡើងដែរ ក្រោមកិច្ចសហការជាមួយអង្គការ Light for the World ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) និងអង្គការ UNDP ដើម្បីលើកកម្ពស់បរិយាបន្នពិការភាព[1]។

ដំណាក់កាលទី ២ នៃកម្មវិធី ACCESS (ACCESS 2) កត់សម្គាល់ថា គិតត្រឹមពាក់កណ្ដាលឆ្នាំ២០២៤ មិនទាន់មានឯកសាររួមណាមួយដែលអាចចងក្រងជារួមនូវរាល់ឯកសារណែនាំ និងព័ត៌មានផ្សេងៗដែលមានស្រាប់ដើម្បីផ្ដល់ការកសាងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលផ្ដោតសំខាន់លើការលើកកម្ពស់បរិយាបន្នសមធម៌ និងសិទ្ធិជនមានពិការភាពនោះទេ។ វាជាការចាំបាច់ណាស់ដែលត្រូវមានធនធានគ្រប់ជ្រុងជ្រោយមួយដើម្បីបង្កើនការយល់ដឹងដល់ភាគីពាក់ព័ន្ធជាច្រើន និងរួមចំណែកដល់វឌ្ឍនភាពក្នុងការសម្រេចបានចក្ខុវិស័យ និងបេសកកម្មនៃ *ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ២០២៤-២០២៨ (NDSP3)* និងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការមិនទុកនរណាម្នាក់ចោល។ ធនធានបែបនេះនឹងធានាថា នៅពេលដែលមានការផ្លាស់ប្ដូរមន្ត្រីនៅថ្នាក់ក្រោមជាតិ ឬសមាជិកគណៈកម្មាធិការ ឬអ្នកផ្ដល់សេវា ក៏គោលគំនិត និងចំណេះដឹងសំខាន់ៗអំពីការអនុវត្តល្អៗដែលពាក់ព័ន្ធនឹងបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព នឹងមិនបាត់បង់ឡើយ។

***ឯកសារ «ការលើកកម្ពស់បរិយាបន្នពិការភាព សមធម៌ និងសិទ្ធិជនមានពិការភាពនៅកម្ពុជា»*** បានប្រមូលផ្ដុំនូវការស្រាវជ្រាវ ការណែនាំ ឧត្តមានុវត្តន៍ និងយុទ្ធសាស្ត្រក្នុងរយៈពេលជាច្រើនទសវត្សរ៍មកហើយ ដើម្បីផ្ដល់ជាធនធានគ្រប់ជ្រុងជ្រោយមួយដែលមានគោលបំណងបង្កើនការយល់ដឹងក្នុងចំណោមភាគីពាក់ព័ន្ធជាច្រើនអំពីបរិយាបន្នពិការភាពសំខាន់ៗ និងធនធានដែលមានស្រាប់។ ឯកសារ «ការលើកកម្ពស់បរិយាបន្នពិការភាព សមធម៌ និងសិទ្ធិជនមានពិការភាពនៅកម្ពុជា» ចែកចេញជា៥ផ្នែក៖

១. សេចក្ដីផ្ដើម និងបរិបទ
២. ការលើកកម្ពស់ការយល់ដឹងអំពីបរិយាបន្នពិការភាព សមធម៌ និងសិទ្ធិជនមានពិការភាព
៣. សកម្មភាពអាទិភាពដើម្បីលើកកម្ពស់ការយល់ដឹងអំពីបរិយាបន្នពិការភាព សមធម៌ និងសិទ្ធិជនមានពិការភាពនៅកម្ពុជា
៤. ផ្លូវឆ្ពោះទៅរកការលើកកម្ពស់ការយល់ដឹងអំពីបរិយាបន្នពិការភាព សមធម៌ និងសិទ្ធិជនមានពិការភាពនៅថ្នាក់ក្រោមជាតិ
៥. សេចក្ដីសន្និដ្ឋាន និងជំហានបន្ទាប់។

---

[1] *Disability Inclusion Trainer’s Manual: A guide for supporting training capacity for disability inclusion*, Light for the World, DAC and UNDP, [Hereinafter Trainer’s Manual]

***ផ្នែកទី ២ ស្ដីពីការលើកកម្ពស់ការយល់ដឹងអំពីបរិយាបន្នពិការភាព សមធម៌ និងសិទ្ធិជនមានពិការភាព*** មានគោលបំណងបង្កើនការយល់ដឹងអំពីបញ្ហានានា ដូចជា និយមន័យនៃពិការភាព ការផ្លាស់ប្ដូរពីគំរូបែបសប្បុរសធម៌ទៅជាគំរូផ្អែកលើសិទ្ធិ តើអ្វីទៅជាបរិយាបន្នពិការភាព គោលការណ៍នៃបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព ឧបសគ្គរារាំងការពង្រឹងបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព និងការសម្រេចបានបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព។

ឧបសគ្គដែលបានកត់សម្គាល់ រួមមាន ការមាក់ងាយ និងការរើសអើងដោយសារការយល់ឃើញអវិជ្ជមានចំពោះពិការភាព ឧបសគ្គផ្នែករូបវន្ត ឧបសគ្គផ្នែកទំនាក់ទំនង ឧបសគ្គផ្នែកហិរញ្ញវត្ថុ និងឧបសគ្គផ្នែកឥរិយាបថដែលបានកម្រិតលទ្ធភាពទទួលបានសេវា ការយល់ដឹងមានកម្រិតអំពីអត្ថន័យនៃបរិយាបន្នពិការភាព ឬក៏របៀបធ្វើឱ្យសម្រេចបាននូវបរិយាបន្ន និងលទ្ធភាពទទួលបានសេវាប្រកបដោយសមធម៌នៅក្នុងផែនការការងារ កង្វះការ យល់ដឹងអំពីអភិក្រមផ្អែកលើសិទ្ធិ ការរើសអើងនៅក្នុងគ្រួសាររបស់ជនមានពិការភាព ការរើសអើងនៅក្នុងសហគមន៍ របស់ពួកគេ និងការរើសអើងដោយអ្នកផ្ដល់សេវា និងអាជ្ញាធរមូលដ្ឋាន ថវិកាជាតិនៅមានកម្រិតដើម្បីអនុវត្តសេវាដែលប្រកបដោយបរិយាបន្នពិការភាព និងសមធម៌ បន្ថែមលើនេះជនមានពិការភាពមិនទាន់យល់ដឹងទូលំទូលាយពីសិទ្ធិរបស់ពួកគេ ឬរបៀបទាមទារសិទ្ធិទាំងនោះ។

ចំណុចសំខាន់ៗដែលបានកំណត់ដើម្បីសម្រេចបានបរិយាបន្នពិការភាព សមធម៌ និងសិទ្ធិប្រកបដោយប្រសិទ្ធភាព រួមមាន ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយបែបបរិយាបន្ន អភិក្រមផ្លូវភ្លោះ ការផ្លាស់ប្ដូរ សង្គម និងឥរិយាបថ ការប្រើប្រាស់ភាសាបែបបរិយាបន្ន ការរៀបចំផែនការ ការធ្វើសេចក្ដីសម្រេចចិត្ត និងការរៀបចំថវិកាបែបបរិយាបន្ន ការប្រមូលទិន្នន័យ និងការពិនិត្យតាមដាន និងវាយតម្លៃ និងការអភិវឌ្ឍប្រកបដោយបរិយាបន្នពិការភាព។

***ផ្នែកទី ៣ បង្ហាញពីសកម្មភាពអាទិភាពដើម្បីលើកកម្ពស់បរិយាបន្នពិការភាព*** ទិសដៅយុទ្ធសាស្ត្រទាំង ៧ ដែលមានចែងក្នុង NDSP3 ផ្ដល់នូវក្របខណ្ឌសម្រាប់សកម្មភាពតាមរយៈការបញ្ជ្រាបទៅក្នុងគោលនយោបាយ និងកម្មវិធីទូលំទូលាយ។ ទិសដៅយុទ្ធសាស្ត្រទាំងនេះរួមមាន ការងារ និងសន្តិសុខសេដ្ឋកិច្ច, សុខភាព ការស្ដារលទ្ធភាពពលកម្ម និងសុខុមាលភាព, ការអប់រំ និងការរៀនសូត្រពេញមួយជីវិត, កិច្ចគាំពារសង្គម និងកម្រិតជីវភាពរស់នៅសមរម្យ, សហគមន៍ដែលមានបរិយាបន្ន និងការបង្កលក្ខណៈងាយស្រួល, សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌, និងស្ថានភាពហានិភ័យ និងការប្រែប្រួលអាកាសធាតុ។ ទិដ្ឋភាពទូទៅ រួមទាំងគោលនយោបាយ និងផែនការពាក់ព័ន្ធ និងការណែនាំដែលមានផ្ដល់ស្ដីពីបញ្ហានានា ត្រូវបានបង្ហាញឡើងសម្រាប់ទិសដៅយុទ្ធសាស្ត្រនីមួយៗ។ ការផ្ដោតសំខាន់គឺការបញ្ជ្រាបពិការភាពទៅក្នុងកម្មវិធីទូលំទូលាយ ជាជាងការផ្ដល់កិច្ចអន្តរាគមន៍ ដាច់ដោយឡែកផ្អែកតាមពិការភាព និងមានគោលបំណងបំពេញបន្ថែម ឬគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រដែលបានកំណត់ក្រោមគោលដៅនីមួយៗនៃទិសដៅយុទ្ធសាស្ត្ររបស់ NDSP3។

***ផ្នែកទី ៤ ផ្ដល់នូវទិដ្ឋភាពទូទៅអំពីផ្លូវភ្លោះទៅរកការលើកកម្ពស់បរិយាបន្នពិការភាពនៅថ្នាក់ក្រោមជាតិ*** តាមរយៈយន្តការសំខាន់ៗចំនួន ៨ (ប្រាំបី) រួមមាន ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត (PDAC) ក្រុមប្រឹក្សាឃុំ/សង្កាត់ ដំណើរការកំណត់អត្តសញ្ញាណជនមានពិការភាព កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) កម្មវិធីវិនិយោគឃុំ/សង្កាត់ (CIP) គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (CCWC) ការិយាល័យច្រកចេញចូលតែមួយ (OWSO) និងបន្ទប់ផ្ដល់សេវាចម្រុះ (OSSU)។

***ផ្នែកទី ៥ បង្ហាញពីសេចក្តីសន្និដ្ឋាន និងជំហ៊ានបន្ទាប់*** មនុស្សគ្រប់រូប ជាពិសេសក្រសួងសាមីមាននាទីលើកកម្ពស់បរិយាបន្នពិការភាព នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅប្រចាំថ្ងៃក្នុងសហគមន៍របស់ពួកគេ។ សកម្មភាពនានានឹងត្រូវការអភិក្រមពហុមុខព្រួញ និងជាប្រព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជម្នះឧបសគ្គនានា។ *ឯកសារ* ***«ការលើកកម្ពស់បរិយាបន្នពិការភាព សមធម៌ និងសិទ្ធិជនមានពិការភាពនៅកម្ពុជា»*** គូសបញ្ជាក់ពីក្របខណ្ឌ និងការណែនាំដែលមានផ្តល់សម្រាប់ក្រសួង និងអ្នកពាក់ព័ន្ធផ្សេងទៀតដើម្បីចាត់វិធានការ និងអនុវត្តទិសដៅយុទ្ធសាស្ត្ររបស់ NDSP3។ ធនធាននេះក៏ណែនាំផងដែរឱ្យមានការចាត់វិធានការបន្ថែមដែលផ្តោតលើការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធនៅគ្រប់កម្រិត ដើម្បីសម្រេចបានបរិយាបន្នពិការភាព សមធម៌ និងសិទ្ធិប្រកបដោយប្រសិទ្ធភាព។ អនុសាសន៍ចំនួន ៦ ត្រូវបានលើកឡើង៖

- **អនុសាសន៍ទី ១** ៖ បង្កើតធនធានសម្រាប់ការបណ្តុះបណ្តាលដោយផ្ទាល់ និងតាមអនឡាញ ស្តីពីបរិយាបន្នពិការភាព សម្រាប់សមាជិកក្រុមការងារសកម្មភាពជនពិការ ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត និងក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់ស្រុក។
- **អនុសាសន៍ទី ២**៖ បង្កើតធនធានបណ្តុះបណ្តាលសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈកម្មាធិការមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត។
- **អនុសាសន៍ទី ៣**៖ បង្កើតធនធានបណ្តុះបណ្តាលតាមអនឡាញលើការយល់ដឹងអំពីពិការភាពសម្រាប់មន្ត្រីរាជការ បុគ្គលិកកិច្ចសន្យា និងអ្នកផ្តល់សេវា។
- **អនុសាសន៍ទី ៤**៖ បន្តកសាងសមត្ថភាព និងបង្កើនភាពអង់អាចដល់អង្គការតំណាងជនមានពិការភាព (OPD) នៅថ្នាក់ក្រោមជាតិ តាមរយៈការបណ្តុះបណ្តាល ការណែនាំ/ហ្វឹកហ្វឺន និងការផ្តល់សម្ភារៈសមស្របសម្រាប់ការស្វែងរកមតិគាំទ្រ។
- **អនុសាសន៍ទី ៥**៖ ពង្រឹងយន្តការដើម្បីបង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់ OPD/ជនមានពិការភាព នៅក្នុងគណៈកម្មាធិការ និងក្រុមការងារថ្នាក់ក្រោមជាតិទាំងអស់។
- **អនុសាសន៍ទី ៦**៖ បង្កើនការយល់ដឹងជាសាធារណៈស្តីពីសិទ្ធិ និងការរួមចំណែករបស់ជនមានពិការភាពដល់សង្គមបែបបរិយាបន្ន។

# ផ្នែកទី ១ សេចក្ដីផ្ដើម

## ១.១ សេចក្ដីផ្ដើម និងបរិបទ

អស់រយៈពេលជាងពីរទសវត្សរ៍មកនេះ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានចាត់វិធានការសំខាន់ៗជាច្រើនដើម្បីលើកកម្ពស់សិទ្ធិ បរិយាបន្ន និងសុខុមាលភាពរបស់ជនមានពិការភាព រួមទាំងការផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីសិទ្ធិជនពិការ ឆ្នាំ២០០៦ (CRPD) ការរៀបចំសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីការការពារសិទ្ធិជនមានពិការភាព[2] ( ច្បាប់ស្ដីពីពិការភាព ) និងការបង្កើតផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព (NDSP) ចំនួន ៣ ចាប់តាំង ពីឆ្នាំ ២០១៤[3] មក។ ក្រៅពីនេះ ក៏មានក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយផ្សេងទៀតជាច្រើនដែលពាក់ព័ន្ធនឹងការលើកកម្ពស់សិទ្ធិ បរិយាបន្ន និងសុខុមាលភាពរបស់ជនមានពិការភាព និងកុមារដែលមានពិការភាព និងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានសេវា និងឱកាសផ្សេងៗប្រកបដោយសមធម៌។

ទោះបីសម្រេចបានវឌ្ឍនភាពក៏ដោយ ប៉ុន្តែជនមានពិការភាពនៅតែប្រឈមនឹងការរើសអើង និងបរិយាបន្ននៅមានកម្រិតនៅក្នុងការផ្ដល់សេវា និងឱកាសនានា ដោយស្មើភាពជាមួយអ្នកដទៃនៅក្នុងសហគមន៍របស់ពួកគេ។ ឧបសគ្គទាំងនេះបានកម្រិតសមត្ថភាពរបស់ពួកគេក្នុងការរួមចំណែកដល់ការបង្កើនផលិតភាពក្នុងសេដ្ឋកិច្ច ឬទទួលបានអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ ជំងឺរាតត្បាតកូវីដ-១៩ ក៏បានបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់សុខុមាលភាពរបស់ជនមានពិការភាព និងលទ្ធភាពទទួលបានសេវារបស់ពួកគេផងដែរ[4]។

នៅកម្ពុជា មានប្រភពសំខាន់ ៣ ដែលផ្ដល់ទិន្នន័យស្ដីពីពិការភាព គឺទិន្នន័យប្រេវ៉ាឡង់នៅក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា (GPCC) និង*អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា* (CDHS) និងទិន្នន័យរដ្ឋបាលនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព (DMIS) របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY)។

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ រកឃើញថា ប្រជាជនកម្ពុជា ៤,៩ ភាគរយ ( ៦៨៩.៥៣២ នាក់ ) ដែលមានអាយុ ៥ ឆ្នាំឡើងទៅ មាន “ការពិបាក” មួយចំនួនក្នុងការបំពេញមុខងារ។ ស្ត្រីមានប្រេវ៉ាឡង់ពិការភាពខ្ពស់ជាងបុរស។ តំបន់ជនបទ ( ៥,៣ ភាគរយ ) មានអត្រាពិការភាពខ្ពស់ជាងតំបន់ទីប្រជុំជន ( ៤,២ ភាគរយ )។ របាយការណ៍ផ្នែកពិការភាពនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់ថា ជំរឿននេះបានប៉ាន់ស្មានប្រេវ៉ាឡង់ពិការភាពទាបជាងចំនួនជាក់ស្ដែង ជាពិសេសសម្រាប់ពិការភាពកម្រិតស្រាល និងពិការភាពកម្រិតធ្ងន់ធ្ងរ ដោយសារការលំបាកក្នុងការវាស់វែងអត្រាប្រេវ៉ាឡង់ពិការភាព[5]។ CDHS សម្រាប់ ឆ្នាំ ២០២១-២០២២ រកឃើញថា ២៤,៤ ភាគរយនៃសមាជិកគ្រួសារដែលមានអាយុ ៥ ឆ្នាំឡើងទៅ មានការពិបាក មួយចំនួនក្នុងការបំពេញមុខងារយ៉ាងតិចមួយ ហើយប្រជាជន ៤,១ ភាគរយ លើកឡើងថា ពួកគេមានពិការភាពកម្រិតធ្ងន់ធ្ងរ[6]។

---

[2] ច្បាប់ស្ដីពីពិការភាពថ្មីនឹងជំនួសឱ្យច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ឆ្នាំ ២០០៩។

[3] ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ២០២៣-២០២៨ (NDSP3) នឹងត្រូវដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០២៤។

[4] សម្រាប់ព័ត៌មានបន្ថែម សូមមើល National situational analysis and assessment of the impact of the COVID-19 crisis on the rights and wellbeing of persons with disabilities and their access to services and supports, February 2021

[5] National Institute of Statistics, Thematic Report on Disability in Cambodia, General Population Census of Cambodia 2019, Ministry of Planning, Third Draft 25 August 2021, 42 [Thematic Report]

[6] Persons with Disabilities in Cambodia: Findings from the Cambodia Demographic and Health Survey, 2014 & 2021-22, September 2023, 9

គិតត្រឹមថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០២៤ ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព (DMIS) របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[7] បានចុះបញ្ជីជនមានពិការភាពចំនួន ៣៥១.១២១ នាក់ក្នុង ២៥ ខេត្ត/ក្រុង (ស្រី ១៧១.៩៧១ នាក់) ហើយបណ្ណសម្គាល់ជនមានពិការភាពចំនួន ២៥០.៧៣០ ត្រូវបានផ្តល់ជូន[8]។

ជនមានពិការភាពនៅកម្ពុជា រំលេចភាពចម្រុះនៃប្រជាជន។ ភាពចម្រុះនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងប្រភេទផ្សេងៗនៃពិការភាពដែលមានដូចជា ពិការភាពកាយសម្បទា កម្សោយគំហើញ កម្សោយការស្តាប់ កម្សោយសតិបញ្ញា កម្សោយផ្នែកចិត្តសង្គម អូទីស្សឹម របួសខួរក្បាលដែលកើតឡើងក្រោយពេលកើត ពិការភាពសរសៃប្រសាទ របួសខួរឆ្អឹងខ្នង និងពិការភាពដែលមើលមិនឃើញ។ យើងចាំបាច់ត្រូវតែយល់ដឹង ទទួលស្គាល់ និងទទួលយកភាពចម្រុះនៃជនមានពិការភាព រួមទាំងការយល់ដឹងអំពីគោលគំនិតនៃ «ភាពប្រសព្វគ្នា» (intersectionality)។ ភាពប្រសព្វគ្នាទទួលស្គាល់ថា អ្នកដែលស្ថិតក្នុងក្រុមជួបការលំបាកចាប់ពី ២ ឡើងទៅ ជួបប្រទះការរើសអើងក្នុងលក្ខណៈផ្សេងៗពីគ្នា និងខុសពីអ្នកដែលស្ថិតក្នុងក្រុមជួបការលំបាកតែមួយ។ ភាពប្រសព្វគ្នាទទួលស្គាល់ថា កត្តាសម្គាល់អត្តសញ្ញាណ ដូចជា «ស្ត្រី» «ជនជាតិដើមភាគតិច» ឬ «ជនមានពិការភាព» សុទ្ធតែពាក់ព័ន្ធនឹងកត្តាផ្សេងទៀត។ កត្តាសម្គាល់នីមួយៗជះឥទ្ធិពលលើគ្នាទៅវិញទៅមក និងអាចបង្កផលជះដែលត្រួតគ្នា និងកើនឡើងជាលំដាប់។

គេទទួលស្គាល់ថា មិនមែនជនមានពិការភាពទាំងអស់សុទ្ធតែងាយរងគ្រោះ ឬជួបការលំបាកដូចគ្នានោះទេ។ ជនមានពិការភាព ជាពិសេសអ្នកដែលនៅតំបន់ជនបទ និងដាច់ស្រយាល និងក្រុមងាយរងគ្រោះមួយចំនួនប្រឈមនឹងបញ្ហាជាច្រើននៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ដូចជា ភាពក្រីក្រ និងរបរចិញ្ចឹមជីវិតដែលគ្មាននិរន្តរភាព ការរើសអើង និងឥរិយាបថអវិជ្ជមានពីមនុស្សគ្រប់ស្រទាប់នៅក្នុងសង្គម លទ្ធភាពមានកម្រិតក្នុងការទទួលបានសេវាព័ត៌មាន និងឱកាសសមស្រប ការមិនអាចទទួលបានហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កង្វះព័ត៌មានដែលបង្កលក្ខណៈងាយស្រួលស្តីពីសេវា និងឱកាសផ្សេងៗ កង្វះចំណេះដឹងស្តីពីសិទ្ធិជនមានពិការភាពក្នុងចំណោមអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា និងកង្វះបរិយាបន្នក្នុងសេវាសំខាន់ៗ និងឱកាសនានា។

ចក្ខុវិស័យនៃ*ផែនការយុទ្ធសាស្រ្តជាតិថ្មីស្តីពីពិការភាព ២០២៤-២០២៨* (NDSP3) គឺ «ជនមានពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យ និងគ្រួសាររបស់ពួកគេ រស់នៅប្រកបដោយសុខុមាលភាពក្នុងគ្រប់ទិដ្ឋភាពនៃជីវិត និងចូលរួមយ៉ាងពេញលេញ និងស្មើភាពក្នុងសង្គមមួយដែលគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងភាពចម្រុះរបស់ពួកគេ ដោយមានបរិយាបន្នក្នុងគ្រប់វិស័យ និងការអភិវឌ្ឍ»។ លើសពីនេះ បេសកកម្មដែលបានចែងក្នុង NDSP3 គឺ «ដើម្បីសម្រេចបានបរិយាបន្នពិការភាពក្នុងការងារ និងថវិការបស់ក្រសួង និងស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ»។

## ១.២ គោលបំណងនៃឯកសារនេះ

*ឯកសារ «ការលើកកម្ពស់បរិយាបន្នពិការភាព សមធម៌ និងសិទ្ធិជនមានពិការភាពនៅកម្ពុជា»* មានគោលបំណងកសាងការយល់ដឹង និងចំណេះដឹងសមស្របអំពីបញ្ហាសំខាន់ៗ និងការណែនាំដែលមាន ក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់។ ឯកសារនេះនឹងដើរតួនាទីជាធនធានដែលមានប្រយោជន៍សម្រាប់តួអង្គជាច្រើន រួមទាំងអ្នកមានកាតព្វកិច្ច និងអ្នកមានសិទ្ធិ ៖ ក្រសួង និងអង្គភាពរបស់រាជរដ្ឋាភិបាលកម្ពុជានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត (PDAC) និងក្រុមការងារសកម្មភាពជនពិការ (DAWG) អាជ្ញាធរមូលដ្ឋាន ដូចជា ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការថ្នាក់ក្រោមជាតិ អ្នកផ្តល់សេវា ដៃគូអភិវឌ្ឍន៍ និងជនមានពិការភាព និង

[7] DMIS ត្រូវបានបង្កើតឡើងក្រោមអនុក្រឹត្យលេខ ២០២ ស្តីពីអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០២៣ (ការបកប្រែក្រៅផ្លូវការ)។

[8] សេចក្តីសង្ខេបសុន្ទរកថារបស់ឯកឧត្តម សន សុផល អគ្គនាយកនៃអគ្គនាយកដ្ឋានស្តារសម្បទានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា ក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីការផ្សព្វផ្សាយរបាយការណ៍ទិន្នន័យអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋានដល់ក្រសួង ស្ថាប័ន និងមន្ទីរពាក់ព័ន្ធ រាជធានី និងខេត្ត នៅភោជនីយដ្ឋាន ទន្លេបាសាក់ ២ រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២៤។

អង្គការតំណាងរបស់ពួកគេដែលអាចមិនយល់ច្បាស់ពីសិទ្ធិរបស់ពួកគេ ឬរបៀបទទួលបានសេវា និងឱកាសដែលស្មើភាពជាមួយសមាជិកផ្សេងទៀតនៃសហគមន៍របស់ពួកគេ[9]។

ធនធាននេះត្រូវបានបង្កើតឡើងតាមរយៈការស្រាវជ្រាវឯកសារច្បាប់ គោលនយោបាយ ផែនការ ឯកសារពាក់ព័ន្ធផ្សេងទៀត និងគេហទំព័រដែលមានទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស។ ក្រៅពីនេះ មានការរួមចំណែកដ៏មានតម្លៃពីសំណាក់ក្រុមការងារកម្មវិធី ACCESS 2 អង្គការជនពិការកម្ពុជា (អ.ព.ក) និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលធ្វើការជាមួយ និងដើម្បីជនមានពិការភាព តាមរយៈការពិគ្រោះយោបល់ កិច្ចពិភាក្សាជាក្រុម និងយោបល់ត្រឡប់ជាលាយលក្ខណ៍អក្សរ[10]។

*ឯកសារ «ការលើកកម្ពស់បរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាពនៅកម្ពុជា»* ត្រូវបានបង្ហាញឡើងជា ៥ (ប្រាំ) ផ្នែក៖ (១) សេចក្តីផ្តើម និងបរិបទ (២) ការលើកកម្ពស់ការយល់ដឹងអំពីបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព (៣) សកម្មភាពអាទិភាពដើម្បីលើកកម្ពស់បរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាពនៅកម្ពុជា (៤) មាគ៌ាឆ្ពោះទៅរកការលើកកម្ពស់បរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាពនៅថ្នាក់ក្រោមជាតិ និង (៥) សេចក្តីសន្និដ្ឋាន និងសកម្មភាពឆ្ពោះទៅមុខ។ ផ្នែកទី ៣ ឆ្លុះបញ្ចាំងពីទិសដៅយុទ្ធសាស្ត្ររបស់ NDSP3 និងផ្តល់នូវទិដ្ឋភាពទូទៅ រួមទាំងគោលនយោបាយ និងផែនការពាក់ព័ន្ធ និងការណែនាំដែលមានស្តីពីបញ្ហានានាដូចជាការងារ និងសន្តិសុខសេដ្ឋកិច្ច សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព ការអប់រំ និងបំណិនជីវិត កិច្ចគាំពារសង្គម និងកម្រិតជីវភាពរស់នៅសមរម្យ សហគមន៍ដែលមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួល សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌ និងស្ថានភាពហានិភ័យ និងការប្រែប្រួលអាកាសធាតុ។ ចំណុចផ្តោតសំខាន់នៃផ្នែកទី ៣ គឺការដាក់បញ្ចូលពិការភាពទៅក្នុងកម្មវិធីទូលំទូលាយ ជាជាងការផ្តល់កិច្ចអន្តរាគមន៍ដាច់ដោយឡែកតាមផ្នែកពិការភាព និងមានគោលបំណងបំពេញបន្ថែម ឬគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រដែលបានកំណត់ក្រោមគោលដៅនីមួយៗនៃទិសដៅយុទ្ធសាស្ត្រ។



9 សូមមើលឧបសម្ព័ន្ធ ២ សម្រាប់ទិដ្ឋភាពទូទៅស្តីពីអ្នកពាក់ព័ន្ធសំខាន់ៗដែលមានតួនាទីលើកកម្ពស់បរិយាបន្នពិការភាព។

10 អ្នកពាក់ព័ន្ធផ្សេងទៀតដែលបានផ្តល់ការរួមចំណែក និងជំបូន្មាន រួមមាន PAfID, UNICEF, UNDP, UNFPA, UNOHCHR, ICRC, CARE Cambodia, Exceed Worldwide, Humanity & Inclusion, CHAI និងតំណាងស្ថានទូតអូស្ត្រាលីប្រចាំរាជធានីភ្នំពេញ។

# ផ្នែកទី ២ ការលើកកម្ពស់ការយល់ដឹងអំពីបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព

ដើម្បីសម្រេចបានចក្ខុវិស័យ និងបេសកកម្មរបស់ NDSP3 ចាំបាច់ត្រូវមានអភិក្រមទូទាំងរដ្ឋាភិបាល និងពហុវិស័យ រួមទាំងការចូលរួមប្រកបដោយអត្ថន័យរបស់ជនមានពិការភាព។ ការលើកកម្ពស់បរិយាបន្នពិការភាពគួរតែផ្អែកតាមសមធម៌ ដោយទទួលស្គាល់នូវឧបសគ្គគ្រប់ប្រភេទដែលរារាំងជនមានពិការភាពមិនឱ្យចូលរួមដោយស្មើភាពជាមួយអ្នកដទៃ។

ផ្នែកនេះមានគោលបំណងបង្កើនការយល់ដឹងអំពីចំណុចនានា ដូចជា និយមន័យនៃពិការភាព ការផ្លាស់ប្តូរពីគំរូបែបសប្បុរសធម៌ទៅជាគំរូផ្អែកលើសិទ្ធិ តើអ្វីទៅជាបរិយាបន្នពិការភាព គោលការណ៍នៃបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព ឧបសគ្គរារាំងការពង្រឹងបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព និងការសម្រេចបានបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព។

## ២.១ និយមន័យនៃពិការភាព

អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) មិនមានផ្តល់និយមន័យលម្អិតនៃ «ពិការភាព» ឬ «ជនមានពិការភាព» នៅក្នុងផ្នែកនិយមន័យទេ។ ទោះយ៉ាងណា មាត្រា ១ បញ្ជាក់ថា «ជនពិការសំដៅលើអ្នកទាំងឡាយដែលមានភាពអន់ខ្សោយរយៈពេលយូរផ្នែកកាយសម្បទា ផ្លូវចិត្ត ប្រាជ្ញា ឬវិញ្ញាណ ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានាអាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គម ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។» និយមន័យនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុង NDSP3 និងសេចក្តីព្រាងច្បាប់ស្តីពីពិការភាពថ្មី។ NDSP3 លើកទឹកចិត្តឱ្យមានសកម្មភាពដោះស្រាយសិទ្ធិ និងភាពចម្រុះរបស់មនុស្សពេញវ័យ យុវជន កុមារ និងចាស់ជរាដែលមានពិការភាពផ្សេងៗគ្នា ដោយមិនគិតពីដើមហេតុបង្កឱ្យមានពិការភាព។

## ២.២ ការផ្លាស់ប្តូរពីគំរូបែបសប្បុរសធម៌ ទៅជាគំរូផ្អែកលើសិទ្ធិ

អភិក្រមសំខាន់ៗ ៤ សម្រាប់ពិការភាព មានការវិវត្តជាបន្តបន្ទាប់ ៖ គំរូសប្បុរសធម៌ គំរូវេជ្ជសាស្ត្រ គំរូសង្គម និងគំរូផ្អែកលើសិទ្ធិ។ គំរូសប្បុរសធម៌ផ្តោតលើបុគ្គល និងច្រើនតែចាត់ទុកជនមានពិការភាពជាជនរងគ្រោះ ឬជាកម្មវត្ថុនៃការអាណិតអាសូរ ដែលត្រូវបានកំណត់អត្តសញ្ញាណដោយពិការភាពរបស់ពួកគេ។ គំរូវេជ្ជសាស្ត្រក៏ផ្តោតលើពិការភាពរបស់បុគ្គលផងដែរ និងចាត់ទុកពិការភាពជាបញ្ហា ឬស្ថានភាពសុខភាព ដែលត្រូវការជំនួយ ឬត្រូវការការព្យាបាល។ គំរូសង្គមផ្តោតលើការកែទម្រង់សង្គម ការលុបបំបាត់ឧបសគ្គ រារាំងការចូលរួម ការលើកកម្ពស់ការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបថ ការអនុវត្ត និងគោលនយោបាយ។ គំរូផ្អែកលើសិទ្ធិ ផ្តោតលើសមធម៌ និងសិទ្ធិ និងការខិតខំរួមបញ្ចូលមនុស្សគ្រប់រូបទៅក្នុងសង្គមដោយស្មើភាព។ គំរូនេះផ្អែកលើគោលការណ៍ថា សិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់រូប គឺជាសិទ្ធិដែល



មិនអាចដកហូតបាន ហើយសិទ្ធិទាំងអស់អាចអនុវត្តបាន និងមិនអាចបំបែកបាន។ អភិក្រមនេះអំពាវនាវឱ្យអ្នកមានកាតព្វកិច្ចនៅគ្រប់កម្រិត បំពេញការទទួលខុសត្រូវរបស់ពួកគេ និងចាត់ទុកជនមានពិការភាពជាតួអង្គសំខាន់ក្នុងការរៀបចំផែនការជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ជាអ្នកធ្វើសេចក្តីសម្រេចចិត្ត ជាពលរដ្ឋម្នាក់ និងជាអ្នកមានសិទ្ធិម្នាក់[11]។

ការអនុម័តអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) បាននាំមកនូវ «ការផ្លាស់ប្តូរគំរូ» ក្នុងអភិក្រម និងការគិតអំពីពិការភាព។ ជនមានពិការភាពលែងត្រូវបានចាត់ទុកត្រឹមតែជាកម្មវត្ថុនៃការព្យាបាលវេជ្ជសាស្ត្រ សប្បុរសធម៌ និងត្រូវការការការពារទៀតហើយ។ ខណៈដែលលទ្ធភាពទទួលបានការថែទាំវេជ្ជសាស្ត្រ និងការស្តារលទ្ធភាពពលកម្មសមស្របអាចជាបុរេលក្ខខណ្ឌដើម្បីទ្រទ្រង់ភាពម្ចាស់ការ និងរួមចំណែកដល់ការចូលរួមពេញលេញហើយ CRPD លើកកម្ពស់អភិក្រមមួយដែលជនមានពិការភាពគឺជាអ្នកមានសិទ្ធិ ចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្តលើអ្វីដែលអាចមានផលជះដល់ជីវិតរបស់ពួកគេ និងមានភាពអង់អាចក្នុងការទាមទារសិទ្ធិរបស់ពួកគេ។ ច្បាប់ស្តីពីពិការភាពថ្មី និង NDSP3 ឆ្លុះបញ្ចាំងពីគំរូផ្អែកលើសិទ្ធិ។

## ២.៣ តើអ្វីទៅជាបរិយាបន្នពិការភាព?

បរិយាបន្នមានគោលបំណងធានាថា មនុស្សគ្រប់រូបអាចចូលរួមយ៉ាងសកម្មក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅក្នុងសហគមន៍របស់ពួកគេ ដោយមិនគិតពីភេទ អាយុ យេនឌ័រ ពិការភាព សាសនា ស្ថានភាពសុខភាព ជាតិសាសន៍ ទំនោរផ្លូវភេទ ឬចរិតលក្ខណៈផ្សេងទៀត។ ជាពិសេស បរិយាបន្នពិការភាពមានគោលបំណងធានាថា ជនមានពិការភាពមានលទ្ធភាពស្មើគ្នា និងសមស្របក្នុងការទទួលបានសេវាសំខាន់ៗដែលមានផ្តល់ដូចគ្នាទៅនឹងជនគ្មានពិការភាពដែរ។ បរិយាបន្នគឺជាសិទ្ធិមនុស្ស។ ជនមានពិការភាពមានសិទ្ធិដូចគ្នានឹងជនគ្មានពិការភាព គឺការដាក់បញ្ចូលទៅក្នុងសកម្មភាពដែលមានទាំងអស់។ ការដាក់បញ្ចូលជនមានពិការភាពទៅក្នុងគោលនយោបាយ កម្មវិធី និងសេវាទូលំទូលាយរបស់រដ្ឋាភិបាល មានន័យថា ពួកគេអាចចូលរួមក្នុងនាមជាសមាជិកស្មើភាពនៅក្នុងសង្គម[12]។

ចំនុចសំខាន់នោះគឺត្រូវយល់ពីភាពខុសគ្នារវាង «បរិយាបន្ន» «សមាហរណកម្ម» «ការបំបែកចេញដោយឡែក» និង «ការផាត់ចេញ»។ **បរិយាបន្ន**សំដៅដល់ដំណើរការនៃការផ្លាស់ប្តូរសង្គម និងប្រព័ន្ធ និងរចនាសម្ព័ន្ធរបស់វា ដើម្បីដាក់បញ្ចូលមនុស្សគ្រប់រូប ដោយមិនគិតពីស្ថានភាពរបស់ពួកគេ។ **សមាហរណកម្ម**គឺជាដំណើរការនៃការធ្វើ


© ACCESS 2

[11] សម្រាប់ព័ត៌មានបន្ថែមស្តីពីអភិក្រមផ្សេងៗសម្រាប់ពិការភាព សូមមើល *Disability-Inclusive Development Toolkit*, CBM, January 2017, 21-22 (តទៅនេះ ហៅថា កញ្ចប់ឧបករណ៍ CBM DID)។

[12] Trainer's Manual, 92

ឱ្យបុគ្គលម្នាក់សម្របខ្លួនទៅនឹងសង្គម។ **ការបំបែកចេញដោយឡែក** កើតឡើងនៅពេលដែលសេវាដូចគ្នាត្រូវបានផ្ដល់ដល់ជនមានពិការភាព ក្នុងបរិបទដាច់ដោយឡែកពីជនគ្មានពិការភាព។ **ការផាត់ចេញ** កើតឡើងនៅពេលជនមានពិការភាព ត្រូវបានគេបដិសេធដោយផ្ទាល់ ឬដោយប្រយោលមិនឱ្យទទួលបានសេវា និងឱកាស ដោយស្មើភាពដូចជនគ្មានពិការភាព។ សម្រាប់ជនមានពិការភាព បរិយាបន្នមានន័យវិជ្ជមាន ខណៈដែលសមាហរណកម្មអាចមានន័យអវិជ្ជមាន[13]។

## ២.៤ គោលការណ៍បរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព

គោលការណ៍បរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព លើកកម្ពស់សមធម៌ លទ្ធភាពទទួលបាន ឱកាស និងសិទ្ធិរបស់ប្រជាជនដែលមានពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យ ដោយគ្មានការរើសអើង។ កិច្ចខិតខំប្រឹងប្រែងលើកកម្ពស់បរិយាបន្ន គួរផ្ដោតលើការយល់ថា៖

- ជនមានពិការភាពមានសិទ្ធិទទួលបានឱកាស និងចូលរួមយ៉ាងពេញលេញ និងមានអត្ថន័យ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។
- ជនមានពិការភាពគឺជាក្រុមចម្រុះមួយ ហើយភាពចម្រុះនេះត្រូវតែទទួលបានការគោរព និងការពិចារណានៅក្នុងការរៀបចំគោលនយោបាយ កម្មវិធី និងគម្រោងនានា។
- ជនមានពិការភាពគួរត្រូវបានបង្កើនភាពអង់អាចឱ្យរួមចំណែក និងដើរតួនាទីសកម្ម និងសំខាន់ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។

គោលការណ៍ដែលមានចែងក្នុងមាត្រា ៣ នៃ CRPD ក៏ពាក់ព័ន្ធនឹងបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាពផងដែរ៖

- ការគោរពសេចក្ដីថ្លៃថ្នូរដែលមានពីកំណើត ស្វ័យភាពបុគ្គល រួមទាំងសេរីភាពក្នុងការជ្រើសរើសដោយខ្លួនឯងផ្ទាល់ និងឯករាជ្យភាពរបស់បុគ្គល
- ការមិនរើសអើង
- ការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាព និងបរិយាបន្នក្នុងសង្គម
- ការគោរពជនមានពិការភាពគ្រប់ប្រភេទ ហើយត្រូវទទួលស្គាល់ថា ជនមានពិការភាពជាចំណែកនៃភាពចម្រុះគ្នារបស់មនុស្ស និងមនុស្សជាតិ
- ឱកាសស្មើភាពគ្នា
- ផាសុកវត្ថុ ឬ ការបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព
- សមភាពរវាងបុរស និងស្ត្រី
- ការគោរពសមត្ថភាពរីកចម្រើនរបស់កុមារមានពិការភាព និងការគោរពសិទ្ធិកុមារមានពិការភាពដើម្បីរក្សានូវអត្តសញ្ញាណរបស់ពួកគេ។

## ២.៥ ឧបសគ្គរាំងបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព

ដូចនៅប្រទេសជាច្រើនដែរ ជនមានពិការភាពនៅកម្ពុជាច្រើនតែស្ថិតក្នុងចំណោមប្រជាជនដែលជួបការលំបាកត្រូវបានផាត់ចេញ និងងាយរងគ្រោះបំផុត។ ជនមានពិការភាពជួបប្រទះឧបសគ្គជាច្រើនក្នុងការទទួលបានសេវា និងឱកាសដែលនឹងលើកកម្ពស់សុខុមាលភាព និងសមត្ថភាពរបស់ពួកគេដើម្បីចូលរួមពេញលេញក្នុងសង្គម។ ការចូលរួមប្រកបដោយអត្ថន័យ និងការឆ្លើយតបនឹងការអំពាវនាវ «**គ្មានអ្វីអំពីយើង ដោយគ្មានរូបយើងនោះទេ**» នៅតែជាបញ្ហាចោទសម្រាប់អ្នកពាក់ព័ន្ធទាំងក្នុង និងក្រៅរដ្ឋាភិបាល និងសម្រាប់វិស័យឯកជន។ ឧបសគ្គរាំងបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាពរួមមាន ការមាក់ងាយ និងការរើសអើង លទ្ធភាពទទួលបានសេវា

---

[13] *Disability-Inclusive Language Guidelines*, United Nations Office at Geneva, 2021

និងឱកាស ការយល់ដឹងមានកម្រិតស្ដីពីបរិយាបន្នប្រកបដោយអត្ថន័យ កង្វះការយល់ដឹងអំពីសិទ្ធិ និងសេវា និងឱកាសដែលមាន និងការវិភាជថវិកាមិនគ្រប់គ្រាន់។

## ការមាក់ងាយ និងការរើសអើង

ជាញឹកញាប់ ជនមានពិការភាពប្រឈមនឹងការមាក់ងាយ និងការរើសអើងដោយសារការយល់ឃើញអវិជ្ជមានចំពោះពិការភាព ឬការយល់ខុសដែលទាក់ទងនឹងជំនឿវប្បធម៌ និងសាសនា។ ឥរិយាបថ និងជំនឿទាំងនេះឆ្លុះបញ្ចាំងពីប្រព័ន្ធគុណតម្លៃដែលរើសអើងជនមានពិការភាពដោយផ្អែកលើការយល់ថា រូបរាង ការបំពេញមុខងារ និងអាកប្បកិរិយាមួយចំនួន មានសារៈសំខាន់សម្រាប់ការរស់នៅប្រកបដោយគុណតម្លៃ។ ពេលខ្លះ ពួកគេត្រូវបានចាត់ទុកថាត្រូវការ «ការកែតម្រូវ ឬការកែខៃ» មិនសូវមានសមត្ថភាពក្នុងការរួមចំណែក និងការចូលរួម មិនសូវសក្តិសមនឹងទទួលបានការយកចិត្តទុកដាក់ និងមិនសូវមានតម្លៃសម្រាប់គ្រួសារ និងសហគមន៍[14]។

ការមាក់ងាយអាចនាំទៅរកការរើសអើង និងការផាត់ចេញ ដែលប៉ះពាល់ដល់ទិដ្ឋភាពផ្សេងៗនៃជីវិតរស់នៅប្រចាំថ្ងៃរបស់ជនមានពិការភាព រួមទាំងអន្តរកម្មក្នុងសង្គម និងលទ្ធភាពទទួលបានឱកាសសម្រាប់ការងារ ការអប់រំ និងការថែទាំសុខភាព។ ការមាក់ងាយមិនត្រឹមតែបង្កើតជាឧបសគ្គដែលស្ដែងឱ្យឃើញប៉ុណ្ណោះទេ ប៉ុន្តែជនមានពិការភាពខ្លួនឯងក៏អាចគិតដោយខ្លួនឯង ដែលនាំឱ្យពួកគេផ្ដាច់ខ្លួនពីអ្នកដទៃ និងបន្ទាបតម្លៃផ្ទាល់ខ្លួនផងដែរ។

ការរើសអើងកើតឡើង នៅពេលដែលជនមានពិការភាពត្រូវបានគេប្រព្រឹត្តមិនល្អចំពោះខ្លួន ឬមិនត្រូវបានផ្ដល់ឱកាសដូចអ្នកផ្សេងទៀត ដោយសារពិការភាពរបស់ពួកគេ។ ពេលខ្លះ ទង្វើនេះអាចធ្វើឡើងដោយអចេតនាដោយសារការយល់ខុស និងកង្វះការយល់ដឹងថា ពិការភាពគឺជាផ្នែកមួយនៃជីវិត និងភាពចម្រុះរបស់មនុស្ស។

លើសពីនេះ គួរទទួលស្គាល់ថា គ្រួសារ ឬអ្នកថែទាំកុមារ និងមនុស្សពេញវ័យដែលមានពិការភាព ជាពិសេសអ្នកដែលមានកម្សោយសតិបញ្ញា ឬពិការភាពកម្រិតធ្ងន់ធ្ងរ ក៏អាចប្រឈមនឹងការមាក់ងាយ និងការរើសអើងក្នុងសហគមន៍ និងជួបប្រទះការផាត់ចេញពីសង្គម និងលទ្ធភាពមានកម្រិតក្នុងការទទួលបានសេវា និងឱកាសផងដែរ។

## លទ្ធភាពទទួលបានសេវា និងឱកាស

ទោះបីជាមានវឌ្ឍនភាពក្នុងការពង្រឹងច្បាប់ និងគោលនយោបាយ ដើម្បីធានាថា ជនមានពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យ មានសិទ្ធិទទួលបានសេវា និងឱកាសក៏ដោយ ប៉ុន្តែមនុស្សជាច្រើននៅតែប្រឈមនឹងឧបសគ្គ ក្នុងលទ្ធភាពទទួលបានសេវា និងឱកាសទាំងនេះ។ ឧបសគ្គទាំងនេះអាចជា៖

- **ឧបសគ្គរូបវន្ត** ៖ ទីតាំងផ្ដល់សេវាមិនបង្កលក្ខណៈងាយស្រួល (មិនមានជាសុកវត្ថុ) ឬនៅឆ្ងាយពីកន្លែងដែលជនមានពិការភាពរស់នៅ។
- **ឧបសគ្គទំនាក់ទំនង** ៖ ព័ត៌មានអំពីសេវា/ឱកាសមិនមានក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួល ឬក៏អ្នកផ្ដល់សេវាមិនអាចធ្វើទំនាក់ទំនងសមស្របជាមួយជនមានពិការភាព។
- **ឧបសគ្គហិរញ្ញវត្ថុ** ៖ ជនមានពិកាភាពគ្មានធនធានហិរញ្ញវត្ថុដើម្បីបង់ថ្លៃសេវា ឬថ្លៃធ្វើដំណើរទៅកាន់ទីតាំងផ្ដល់សេវា។
- **ឧបសគ្គឥរិយាបថ** ៖ គ្រួសារ សហគមន៍ និងអ្នកផ្ដល់សេវាអាចមានឥរិយាបថអវិជ្ជមានចំពោះជនមានពិការភាព ដោយសារជំនឿសាសនា ភាពល្ងង់ខ្លៅ និងគំនិតសន្មតជាមុនដែលអាចនាំឱ្យមានការមាក់ងាយ ការកំណត់ផ្ទត់គំនិត ការរើសអើង និងភាពលម្អៀង ឬការប្រកាន់។

## ការយល់ដឹងអំពីបរិយាបន្នប្រកបដោយអត្ថន័យនៅមានកម្រិត

ការពិនិត្យឡើងវិញលើការអនុវត្ត*ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ២០១៩-២០២៣* (NDSP2) រកឃើញថា មានការយល់ដឹងមានកម្រិត ជាពិសេសនៅថ្នាក់ក្រោមជាតិ អំពីអត្ថន័យនៃបរិយាបន្នពិការភាព ឬរបៀបសម្រេចបានបរិយាបន្ន និងលទ្ធភាពទទួលបានសេវាប្រកបដោយសមធម៌នៅក្នុងផែនការការងារ ថវិកា សកម្មភាព និងការ

---

[14] *Reducing stigma and discrimination against children with disabilities*, UNICEF

បណ្តុះបណ្តាលទូលំទូលាយ។ មានកត្តាជាច្រើនដែលរួមចំណែកបង្កជាឧបសគ្គរាំងបរិយាបន្ន ដូចជា អត្រាខ្ពស់នៃការផ្លាស់ចេញចូលមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកដែលត្រូវបានប្រគល់ភារកិច្ចឱ្យធ្វើការងារលើបញ្ហាពាក់ព័ន្ធនឹងពិការភាព និងភាពចាំបាច់នៃការផ្លាស់ប្តូរផ្នត់គំនិតដើម្បីលុបបំបាត់ការមាក់ងាយ និងការរើសអើង និងការមើលឃើញពិការភាពជាបញ្ហាដាច់ដោយឡែក។ ក្រៅពីនេះ គឺកង្វះការយល់ដឹងអំពីពិការភាព និងអត្ថន័យនៃអភិក្រមផ្អែកលើសិទ្ធិ និងបរិយាបន្នពិការភាព ក្នុងចំណោមគ្រួសាររបស់ជនមានពិការភាព សហគមន៍របស់ពួកគេ អ្នកផ្តល់សេវា និងអាជ្ញាធរមូលដ្ឋាន។

## កង្វះការយល់ដឹងអំពីសិទ្ធិ សេវា និងឱកាសដែលមាន

ជនមានពិការភាពជាច្រើន អាចមិនយល់ច្បាស់អំពីសិទ្ធិរបស់ពួកគេ ឬរបៀបទាមទារសិទ្ធិរបស់ពួកគេ។ ពួកគេអាចគ្មានចំណេះដឹងអំពីរបៀបចុះឈ្មោះដើម្បីទទួលបានបណ្ណសម្គាល់ជនមានពិការភាព ឬបណ្ណសមធម៌ ឬអត្ថប្រយោជន៍ដែលទទួលបានពីការមានបណ្ណសម្គាល់ជនមានពិការភាព[15] ឬបណ្ណសមធម៌ ដូចជា លទ្ធភាពទទួលបានការថែទាំសុខភាពដោយឥតគិតថ្លៃ ការគាំទ្រប្រាក់ចំណូលក្រោមកម្មវិធីគាំពារសង្គម ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឱកាសផ្សេងទៀតសម្រាប់ជនមានពិការភាព និងគ្រួសារដែលមានសិទ្ធិទទួលបាន។ បណ្តាញអង្គការតំណាងជនមានពិការភាព (OPD) រួមទាំងវេទិកាស្ត្រីពិការ (WWDF) ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសកម្ពុជា។ ទោះយ៉ាងណា អង្គការជាច្រើនខ្វះសមត្ថភាព និងធនធានហិរញ្ញវត្ថុសម្រាប់លើកកម្ពស់ការយល់ដឹងក្នុងចំណោមជនមានពិការភាព ឬតស៊ូមតិឱ្យគាំទ្រសិទ្ធិរបស់ពួកគេនៅក្នុងតំបន់គោលដៅប្រកបដោយប្រសិទ្ធភាព។

## ការវិភាជថវិកាមិនគ្រប់គ្រាន់

ឧបសគ្គចម្បងមួយដែលរាំងការដាក់បញ្ចូលពិការភាពទៅក្នុងកម្មវិធី សេវា និងឱកាសទូលំទូលាយប្រកបដោយប្រសិទ្ធភាព និងក្នុងការផ្តល់កិច្ចអន្តរាគមន៍ផ្អែកតាមពិការភាព គឺការវិភាជថវិកាមិនគ្រប់គ្រាន់សម្រាប់អនុវត្តសកម្មភាព ឬកសាងសមត្ថភាពរបស់អ្នកផ្តល់សេវាដើម្បីធ្វើការជាមួយជនមានពិការភាព។

# ២.៦ ការសម្រេចបានបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព

ការអនុវត្តបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព ទៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅក្នុងសង្គម វប្បធម៌ សាសនា សេដ្ឋកិច្ច និងនយោបាយនៃសហគមន៍របស់ពួកគេ ទាមទារអភិក្រមពហុមុខព្រួញ និងជាប្រព័ន្ធ នៅគ្រប់កម្រិត ដើម្បីជម្នះឧបសគ្គរាំងបរិយាបន្ន។ ការសម្រេចបានបរិយាបន្នពិការភាព និងលទ្ធភាពទទួលបានសេវា និងឱកាសប្រកបដោយសមធម៌ ទាមទារឱ្យមានការផ្តោតការយកចិត្តទុកដាក់លើបញ្ហានានា ដូចជា ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយបែបបរិយាបន្ន អភិក្រមផ្លូវភ្លោះ ការផ្លាស់ប្តូរសង្គម និងឥរិយាបថ ភាសាបែបបរិយាបន្ន ការរៀបចំផែនការ ការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំថវិកាបែបបរិយាបន្ន ការប្រមូលទិន្នន័យ/ការពិនិត្យតាមដាន និងវាយតម្លៃ (M&E) និងការអភិវឌ្ឍប្រកបដោយបរិយាបន្នពិការភាព។

## ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយបែបបរិយាបន្ន

កម្ពុជាមានក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយដែលអាចនាំឱ្យសម្រេចបានបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព។ លិខិតុបករណ៍ច្បាប់ និងគោលនយោបាយសំខាន់ៗ រួមមាន រដ្ឋធម្មនុញ្ញ, យុទ្ធសាស្ត្របញ្ចកោណ, និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០២៣-២០២៨, *ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ ២០២៤-២០៣៥*, *ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា* (CSDGs), សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ, ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០២៤-២០២៨, អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD), និងយុទ្ធសាស្ត្រអ៊ីនឈាន់[16]។

---

[15] សូមមើលផ្នែកទី ៤ សម្រាប់ព័ត៌មានបន្ថែមស្តីពីបណ្ណសម្គាល់ជនមានពិការភាព និងដំណើរការដើម្បីទទួលបានបណ្ណនេះ និងអត្ថប្រយោជន៍សម្រាប់ម្ចាស់បណ្ណ។

[16] ក្របខណ្ឌគោលនយោបាយពាក់ព័ន្ធមានបង្ហាញក្នុងផ្នែកទី ៣ ស្តីពីសកម្មភាពអាទិភាព។ សម្រាប់ព័ត៌មានបន្ថែមស្តីពីក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយសំខាន់ៗ សូមមើលឧបសម្ព័ន្ធ ៣។ សូមមើលផងដែរ ឧបសម្ព័ន្ធ ៤ សម្រាប់ព័ត៌មានសង្ខេបស្តីពីក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយពាក់ព័ន្ធផ្សេងទៀត។

លើសពីនេះ យន្តការសំខាន់មួយដែលអាចជួយលើកកម្ពស់បរិយាបន្នពិការភាពគឺក្រុមការងារសកម្មភាពជនពិការ (DAWG)។ DAWG ត្រូវបានបង្កើតឡើងនៅគ្រប់ក្រសួង និងស្ថាប័នរដ្ឋាភិបាលទាំងអស់ តបតាមការស្នើឡើងក្នុងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC)[17]។ បន្ទាប់មក ប្រកាសឆ្នាំ ២០១៤ របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ បានគូសបញ្ជាក់ពីសមាសភាព និងតួនាទី និងការទទួលខុសត្រូវរបស់ DAWG ដោយបញ្ជាក់ថា DAWG គឺជាយន្តការសម្របសម្រួល និងផ្តល់យោបល់លើបញ្ហាពិការភាពនៅតាមក្រសួង/ស្ថាប័ននីមួយៗ[18]។ DAWG ដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នពិការភាពទៅក្នុងគោលនយោបាយ និងកម្មវិធីទូលំទូលាយរបស់ក្រសួង ឬស្ថាប័នរបស់ពួកគេ។

ទោះបីជាក្របខណ្ឌ និងយន្តការទាំងនេះអាចជួយលើកកម្ពស់បរិយាបន្នពិការភាព ដើម្បីជម្នះឧបសគ្គរារាំងបរិយាបន្នក៏ដោយ ប៉ុន្តែចាំបាច់ត្រូវមានដំណើរការកែទម្រង់ជាប្រព័ន្ធដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរ និងកែប្រែអភិក្រមរចនាសម្ព័ន្ធ យុទ្ធសាស្ត្រ និងឥរិយាបថ។

## អភិក្រមផ្លូវភ្លោះ

បរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាពអាចសម្រេចទៅបាន លុះត្រាតែមានការដាក់បញ្ចូលពិការភាពទៅក្នុងគោលនយោបាយ និងកម្មវិធីទូលំទូលាយ និងការផ្តល់កិច្ចអន្តរាគមន៍ផ្អែកតាមពិការភាពនៅពេលចាំបាច់ គឺអភិក្រមផ្លូវភ្លោះ។ អភិក្រមផ្លូវភ្លោះដើម្បីលើកកម្ពស់បរិយាបន្នពិការភាព ពាក់ព័ន្ធនឹងការអនុវត្តដំណើរការស្របគ្នាពីរ គឺការបញ្រ្ជាបពិការភាព និងកិច្ចអន្តរាគមន៍ផ្អែកតាមពិការភាព[19]។

- ***ការបញ្រ្ជាបពិការភាព៖*** ដំណើរការនៃការលុបបំបាត់ឧបសគ្គដើម្បីសម្រួលដល់ការចូលរួមរបស់ជនមានពិការភាពក្នុងកម្មវិធី សកម្មភាព និងឱកាសទាំងអស់ ដោយស្មើភាពជាមួយជនគ្មានពិការភាព។
- ***កិច្ចអន្តរាគមន៍ផ្អែកតាមពិការភាព៖*** ការផ្តល់សេវា និងសកម្មភាពដើម្បីបំពេញតម្រូវការជាក់លាក់ ដូចជា ការស្តារលទ្ធភាពពលកម្មកាយសម្បទា បច្ចេកវិទ្យាជំនួយ ឧបករណ៍ជំនួយចល័តភាព ការគាំទ្រដល់ទំនាក់ទំនងការបកប្រែភាសាសញ្ញា និងការបង្កើនភាពអង់អាចដល់ជនមានពិការភាពឱ្យចូលរួមដោយស្មើភាពជាមួយសមាជិកទាំងអស់នៃសហគមន៍របស់ពួកគេ។ ការផ្តល់បច្ចេកវិទ្យាជំនួយសមស្រប អាចរួមចំណែកដល់ការកាត់បន្ថយឧបសគ្គរារាំងបរិយាបន្នប្រកបដោយប្រសិទ្ធភាព។

លទ្ធផលជោគជ័យសម្រាប់ជនមានពិការភាពតាមរយៈអភិក្រមផ្លូវភ្លោះ អាចសម្រេចទៅបានលុះត្រាតែមានការផ្តោតការយកចិត្តទុកដាក់ស្មើគ្នាលើផ្លូវទាំងពីរ។ ក្នុងបរិបទកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ ការផ្តោតសំខាន់គឺការផ្តល់អន្តរាគមន៍ផ្អែកតាមពិការភាព។

## ការផ្លាស់ប្តូរសង្គម និងឥរិយាបថ

មនុស្សពេញវ័យ និងកុមារដែលមានពិការភាព ប្រឈមនឹងការមាក់ងាយ និងការរើសអើងដោយសារផ្នត់គំនិតអវិជ្ជមានចំពោះពិការភាព។ ការសិក្សាដែលធ្វើឡើងដោយអង្គការយូនីសេហ្វ បានរកឃើញថា កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការមាក់ងាយ និងការរើសអើងដែលដោះស្រាយកម្រិតឥទ្ធិពលជាច្រើន ផ្តោតលើក្រុមគោលដៅចម្រុះ និងប្រើមធ្យោបាយចម្រុះនៃទំនាក់ទំនង ការតស៊ូមតិ និងការរៀបចំកម្មវិធី មានប្រសិទ្ធភាពជាងគំនិតផ្តួចផ្តើមដាច់ដោយឡែក។ ការសិក្សានេះក៏រកឃើញផងដែរថា ដើម្បីសម្រេចបានការផ្លាស់ប្តូរសង្គម និងឥរិយាបថជាប្រព័ន្ធគឺត្រូវ ទាមទារពេលវេលា ការវិនិយោគ និងកិច្ចអន្តរាគមន៍ចម្រុះនៃទំនាក់ទំនង កម្មវិធី និងការតស៊ូមតិ[20]។

---

[17] សម្រាប់ព័ត៌មានបន្ថែម សូមមើលមាត្រា ១៤ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣

[18] សម្រាប់ព័ត៌មានបន្ថែម សូមមើលប្រកាសលេខ ០០១ កសជ.ប្រក របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារសកម្មភាពជនពិការ នៅតាមក្រសួង ស្ថាប័ន

[19] CBM DID Toolkit, 55; see also Trainer's Manual, 92

[20] *Reducing stigma and discrimination against children with disabilities*, UNICEF, 2021

របាយការណ៍ចុងក្រោយបង្ហាញព័ត៌មានអំពីការអនុវត្តល្អក្នុងអន្តរាគមន៍ និងអភិក្រមផ្លាស់ប្តូរសង្គម និងឥរិយាបថដើម្បីលើកកម្ពស់ បរិយាបន្ន និងការបង្កើនភាពអង់អាចដល់កុមារ និងក្មេងជំទង់ដែលមានពិការភាព រួមទាំងលទ្ធភាពរបស់ពួកគេក្នុងការទទួលបាន និងប្រើប្រាស់សេវា។ របាយការណ៍នេះក៏បានរំលេចគោលការណ៍ យុទ្ធសាស្រ្ត និងវិធីសាស្រ្តដើម្បីដោះស្រាយឧបសគ្គផ្នែកឥរិយាបថ ព័ត៌មាន បរិស្ថាន និងស្ថាប័នផងដែរ[21]។

ការផ្លាស់ប្តូរឥរិយាបថចំពោះជនមានពិការភាព ក៏អាចជួយកាត់បន្ថយការផាត់ចេញពីសង្គមដោយគ្រួសារ ឬអ្នកថែទាំរបស់ពួកគេផងដែរ។

ការផ្លាស់ប្តូរសង្គម និងឥរិយាបថដើម្បីលើកកម្ពស់ឥរិយាបថ និងអាកប្បកិរិយាដែលមានបរិយាបន្នពិការភាព គឺជាការទទួលខុសត្រូវរបស់មនុស្សគ្រប់រូប រួមទាំងប្រធានសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា។ ការលើកកម្ពស់ការយល់ដឹងក្នុងចំណោម និងការផ្លាស់ប្តូរឥរិយាបថរបស់មន្រ្តីរដ្ឋាភិបាល អ្នកផ្តល់សេវា សមាជិកសហគមន៍ និងគ្រួសារ គឺជាចំណុចស្នូលនៃការលើកកម្ពស់បរិយាបន្នពិការភាពដើម្បីឱ្យជនមានពិការភាពបានចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាព។

ទោះបីជាធនធានមានកម្រិតក៏ដោយ ក៏ CDPO ដើរតួនាទីសំខាន់ក្នុងនាមជាអ្នកអប់រំអំពីសិទ្ធិជនមានពិការភាព និងអនុវត្តសកម្មភាពនានាដើម្បីលើកកម្ពស់ការយល់ដឹង និងកសាងសមត្ថភាពនៅគ្រប់កម្រិត។ ការតស៊ូមតិសម្រាប់ជនមានពិការភាព ក៏បានជួយឱ្យពួកគេការពារសិទ្ធិរបស់ខ្លួន ទទួលបានសមភាព និងជម្នះឧបសគ្គដែលអាចប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការចូលរួមក្នុងសហគមន៍ផងដែរ។ អង្គការតំណាងជនមានពិការភាព (OPD) រួមទាំងវេទិកាស្រ្តីពិការ (WWDF) ដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹង និងកសាងសមត្ថភាពរបស់សមាជិកដើម្បីចូលរួមក្នុងសេវា និងឱកាសនានា ដោយស្មើភាពជាមួយអ្នកដទៃក្នុងសហគមន៍របស់ពួកគេ។

## ភាសាបែបបរិយាបន្ន

ការប្រើប្រាស់ភាសាមិនសមរម្យនៅពេលប្រាស្រ័យទាក់ទង ឬនិយាយអំពីជនមានពិការភាព អាចបង្កការឈឺចាប់ ភាពលម្អៀង/ការប្រកាន់ និងការរើសអើង និងរឹតត្បិតសក្តានុពលសម្រាប់បរិយាបន្ន។ ពេលខ្លះ គ្រួសារ សមាជិកសហគមន៍ ប្រព័ន្ធផ្សព្វផ្សាយ អ្នកផ្តល់សេវា និងអាជ្ញាធរ មិនបានដឹងខ្លួនថា ពួកគេបានប្រើប្រាស់ពាក្យមិនសមរម្យនោះទេ ដោយសារកង្វះការយល់ដឹង និងភាពលម្អៀង/ការប្រកាន់ដែលពួកគេបានឆ្លងកាត់កន្លងមក។ ជនមានពិការភាពត្រូវតែទទួលបានសេចក្តីថ្លៃថ្នូរ និងការគោរព និងការទទួលស្គាល់ថាជាបុគ្គលដែលមានសិទ្ធិដូចសមាជិកដទៃទៀតនៅក្នុងសហគមន៍ដែរ។ ឧទាហរណ៍ វាជាការមិនសមរម្យ ឬមិនផ្តល់ការគោរពក្នុងការសំដៅដល់ជនមានពិការភាពថាជា PWDs ឬជនពិការ ឬហៅពួកគេទៅតាមប្រភេទពិការភាពរបស់ពួកគេ។

គួរពិចារណាពីគោលការណ៍ទូទៅចំនួន ៤ (បួន) ដើម្បីសម្រួលដល់ការប្រើប្រាស់ភាសាសមរម្យ៖

- ប្រើភាសាដែលផ្តោតអាទិភាពចម្បងលើមនុស្ស ៖ សង្កត់ធ្ងន់លើមនុស្សមិនមែនពិការភាពទេ (ជនមានពិការភាព/ជនមានកម្សោយសតិបញ្ញា មិនមែននិយាយថាជនពិការទេ)។
- ជៀសវាងការដាក់ស្លាកសម្គាល់ និងផ្នត់គំនិត ៖ ជៀសវាងពាក្យពេចន៍ដែលបង្ហាញឱ្យឃើញថា ជនមានពិការភាពគឺ «ក្លាហាន» ឬបាន «ជម្នះ» ពិការភាពរបស់គេ ឬ «ងាយរងគ្រោះ»។
- មិនត្រូវប្រើពាក្យសម្រាលដែលបង្ហាញពីឧត្តមភាព ៖ ជៀសវាងប្រើពាក្យ ដូចជា «មានសមត្ថភាពខុសគេ» ឬ «ពិសេស»។
- មិនត្រូវសំដៅទៅលើពិការភាពថាជាជំងឺ ឬបញ្ហា ៖ ជៀសវាងប្រើពាក្យ ដូចជា «រងគ្រោះដោយសារ» ឬ «រងទុក្ខដោយសារ» និងពាក្យដែលបង្ហាញឱ្យឃើញថា ជនមានពិការភាពគឺជាកម្មវត្ថុដែលត្រូវការជំនួយសប្បុរសធម៌ ឬការអាណិតអាសូរ[22]។

---

[21] *Social and Behavioural Change Interventions to Strengthen Disability-Inclusive Programming: A synthesis of the evidence*, UNICEF, November 2020

[22] *Disability-Inclusive Language Guidelines*

ឧបសម្ព័ន្ធ ៥ មានផ្តល់ឧទាហរណ៍នៃភាសាបែបបរិយាបន្ន និងភាសាដែលត្រូវជៀសវាង។ ការប្រើប្រាស់ភាសាសមរម្យ នៅពេលនិយាយជាមួយ ឬនិយាយអំពីជនមានពិការភាព អាចជួយបង្កើនបរិយាបន្ននៅគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅប្រចាំថ្ងៃ។

## ការរៀបចំផែនការ ការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំថវិកាបែបបរិយាបន្ន

ជនមានពិការភាព និងអង្គការតំណាងរបស់ពួកគេ គឺជាសមាជិកនៃស្ថាប័នធ្វើសេចក្តីសម្រេចចិត្ត ដូចជាក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) និងក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត (PDAC) និងបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ ទោះយ៉ាងណា ជនមានពិការភាពច្រើនតែត្រូវបានផាត់ចេញ ឬទទួលបានបទពិសោធន៍មិនល្អនៅពេលចូលរួមក្នុងដំណើរការទូលំទូលាយសម្រាប់ការអភិវឌ្ឍ និងអនុវត្តគោលនយោបាយ កម្មវិធី និងសេវា។

ជនមានពិការភាព និងគ្រួសាររបស់ពួកគេស្គាល់ច្បាស់ថាតើសេវា និងឱកាសអ្វីខ្លះដែលនឹងរួមចំណែកច្រើនបំផុតដល់ភាពប្រសើរឡើងនៃសុខុមាលភាពរបស់ពួកគេ។ សារច្បាស់លាស់នៃចលនាពិការភាព «គ្មានអ្វីអំពីយើងដោយគ្មានរូបយើងនោះទេ» ផ្អែកលើគោលការណ៍នៃការចូលរួម និងបរិយាបន្នក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅប្រចាំថ្ងៃ។ បរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព អាចសម្រេចទៅបាន លុះត្រាតែមានការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យរបស់ជនមានពិការភាព និងអង្គការតំណាងរបស់ពួកគេ នៅក្នុងដំណើរការរៀបចំផែនការ និងធ្វើសេចក្តីសម្រេចចិត្ត។

ពេលខ្លះ អាជ្ញាធរអាចមានការរារែកក្នុងការធ្វើការជាមួយជនមានពិការភាព ដោយសារគំនិតសន្មតជាមុនចំពោះ ពិការភាព ឬរបៀបប្រាស្រ័យទាក់ទងជាមួយជនមានពិការភាព។ មានគោលការណ៍ណែនាំការអនុវត្តល្អសម្រាប់រដ្ឋាភិបាល ធុរកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការអភិវឌ្ឍដំណើរការពិគ្រោះយោបល់ និងជំរុញការចូលរួមដែលមានបរិយាបន្ន បង្កលក្ខណៈងាយស្រួល និងដោយអត្ថន័យ ជាមួយជនមានពិការភាព[23]។

អ្វីដែលសំខាន់ផងដែរនោះ គឺក្នុងអំឡុងដំណើរការរៀបចំផែនការ និងថវិកា ត្រូវមានការបែងចែកមូលនិធិដើម្បីលុបបំបាត់ឧបសគ្គដែលអាចរារាំងការចូលរួមប្រកបដោយអត្ថន័យរបស់ជនមានពិការភាព និងលើកកម្ពស់ការរួមបញ្ចូលពួកគេ។ នេះអាចរួមបញ្ចូលការបណ្តុះបណ្តាលការយល់ដឹងអំពីពិការភាព ឬការបង្កើនជំនាញរបស់អ្នកផ្តល់សេវា។ ក្រៅពីនេះ ថវិកាដែលមានបរិយាបន្នពិការភាពនៅក្នុងកម្មវិធី និងផែនការសំខាន់ៗ គួរពិចារណាផងដែរលើថ្លៃចំណាយនានា ដូចជា ការបង្កើនភាពងាយស្រួលផ្នែករូបវន្ត ការផ្តល់ជាសុកសមរម្យ និងការផ្តល់ព័ត៌មាន និងការផ្សព្វផ្សាយក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួល។

អង្គការយូនីសេហ្វ បានពណ៌នាពីការរៀបចំថវិកាដែលមានបរិយាបន្នពិការភាពថាជាអភិក្រមដែលរដ្ឋាភិបាលច្របាច់បញ្ចូលគ្នានូវយុទ្ធសាស្ត្រដែលផ្តោតលើជនមានពិការភាព និងយុទ្ធសាស្ត្របញ្ជ្រាប ដោយធានាភាពបន្ទ័គ្នាទៅនឹងអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) រួមជាមួយនឹងការកៀរគរ បែងចែក ប្រើប្រាស់ និងធ្វើរបាយការណ៍អំពីធនធានសាធារណៈ ដើម្បីសម្រេចបានបរិយាបន្នពិការភាព។ អភិក្រមនេះតម្រូវឱ្យអ្នកបង្កើតគោលនយោបាយ និងអ្នកចាត់ចែងថវិកា ពិចារណាលើតម្រូវការពិសេសរបស់ជនមានពិការភាពនៅក្នុងវដ្តថវិកាទាំងមូល ក៏ដូចជានៅក្នុងក្របខណ្ឌនៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ផ្សេងទៀត។ អភិក្រមនេះនឹងធានាផងដែរថានឹងមានការពិចារណា និងការសម្រុះសម្រួលបញ្ហាផ្នែកសិទ្ធិមនុស្ស និងសេដ្ឋកិច្ច ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ការវិនិយោគសាធារណៈលើជនមានពិការភាពដែលប្រកបដោយចីរភាព ប្រសិទ្ធភាព និងសមធម៌[24]។

គោលការណែនាំរបស់អង្គការយូនីសេហ្វ មានគោលបំណងបញ្ជាក់ពីអត្ថន័យនៃការរៀបចំថវិកាដែលមានបរិយាបន្នពិការភាពចេញពីទស្សនវិស័យនៃសិទ្ធិកុមារ និងគូសបញ្ជាក់ពីច្រកចូល/ចំនុចចាប់ផ្តើម ឬវិធីសាស្ត្រ

[23] សម្រាប់ព័ត៌មានបន្ថែម សូមមើល *Good Practice Guidelines for Engaging with People with Disability*, Commonwealth of Australia (Department of Social Services), 2023។

[24] *Disability Inclusive Budgeting from a Child Rights Perspective: Pathways of Change for UNICEF and Partners*, UNICEF Eastern and Southern Africa Regional Office, Social Policy and Disability Inclusion, Technical Note, March 2024, 7

នៃការផ្លាស់ប្ដូរសំខាន់ៗសម្រាប់អង្គការយូនីសេហ្វ និងដៃគូ ដើម្បីជះឥទ្ធិពលលើការសម្រេចចិត្តសំដៅធ្វើឱ្យគោលនយោបាយសារពើពន្ធ និងការរៀបចំថវិកា ប្រកបដោយបរិយាបន្នពិការភាព។ ទោះបីជាផ្ដោតសំខាន់លើការធ្វើឱ្យថវិកាដំណើរការសម្រាប់កុមារមានពិការភាពក៏ដោយ ប៉ុន្តែការយល់ដឹង និងការណែនាំក៏ពាក់ព័ន្ធនឹងមនុស្សពេញវ័យដែលមានពិការផងដែរ[25]។

ក្នុងផ្នែកមួយនៃដំណើរការរៀបចំផែនការ និងថវិកា គួរផ្ដោតការយកចិត្តទុកដាក់លើការពង្រឹងប្រព័ន្ធបញ្ជូនបន្ត និងយន្តការផ្សេងទៀត ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នកផ្ដល់សេវាអំពីសិទ្ធិរបស់ជនមានពិការភាពក្នុងការទទួលបានសេវា និងឱកាស និងដើម្បីបញ្ជូនជនមានពិការភាពទៅរកសេវាសំខាន់ៗដែលមានផ្ដល់ ក៏ដូចជាបញ្ជូនទៅរកសេវាជាក់លាក់សម្រាប់ជនមានពិការភាព។

ធាតុផ្សំសំខាន់មួយនៃការរៀបចំផែនការ និងការធ្វើសេចក្ដីសម្រេចចិត្តបែបបរិយាបន្ន គឺការធានាថា កិច្ចប្រជុំ សន្និសីទ និងព្រឹត្តិការណ៍ផ្សេងទៀតអាចឱ្យជនមានពិការភាពគ្រប់ប្រភេទចូលរួមបាន។ ចាំបាច់ត្រូវពិចារណាទាំងលើផាសុកវត្ថុផ្នែករូបវន្តនៅក្នុងទីតាំង និងលទ្ធភាពទទួលបានការផ្សព្វផ្សាយ និងព័ត៌មាន។ យើងមានការណែនាំដើម្បីគាំទ្រដល់ការរៀបចំផែនការ និងការអនុវត្តកិច្ចប្រជុំ សន្និសីទ និងព្រឹត្តិការណ៍ផ្សេងទៀតតាមបែបបរិយាបន្ន។ *កញ្ចប់ឧបករណ៍របស់ CMB សម្រាប់ការរៀបចំកិច្ចប្រជុំ និងព្រឹត្តិការណ៍ដែលមានផាសុកវត្ថុ* ផ្ដល់ការណែនាំអំពីការរៀបចំកិច្ចប្រជុំ និងព្រឹត្តិការណ៍ដែលមានផាសុកវត្ថុ និងមានបរិយាបន្ន ក្នុងដំណាក់កាលរៀបចំផែនការ អនុវត្ត និងតាមដានបន្ត[26]។ ក្នុងឧបសម្ព័ន្ធ ៦ មានបញ្ជីត្រួតពិនិត្យសម្រាប់ការរៀបចំផែនការកិច្ចប្រជុំដែលមានផាសុកវត្ថុ និងមានបរិយាបន្ន។

## ការប្រមូលទិន្នន័យ/ការពិនិត្យតាមដាន និងវាយតម្លៃ

ជាញឹកញាប់ ជនមានពិការភាពប្រឈមនឹងឧបសគ្គធំៗក្នុងការទទួលបានសេវា និងឱកាសសំខាន់ៗ។ ទោះយ៉ាងណា ឧបសគ្គទាំងនេះមិនសុទ្ធតែអាចកំណត់បាននោះទេ ហើយផលប៉ះពាល់នៃកម្មវិធីលើជនមានពិការភាពមិនត្រូវបានវាស់វែងឡើយ ព្រោះដំណើរការពិនិត្យតាមដានមិនត្រូវបានរៀបចំឡើងដើម្បីប្រមូលទិន្នន័យពិការភាព។ គេត្រូវការទិន្នន័យពិការភាពដើម្បីអាចអភិវឌ្ឍគោលនយោបាយ និងកម្មវិធីផ្អែកលើភស្តុតាង និងវាស់វែងវឌ្ឍនភាពនៃការសម្រេចបានបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព ក៏ដូចជាកំណត់រកឧបសគ្គដែលមិនទាន់បានដោះស្រាយ។ ទោះយ៉ាងណា ជនមានពិការភាពច្រើនតែមិនបានចូលរួមក្នុងដំណើរការប្រមូលទិន្នន័យ ការពិនិត្យតាមដាន និងវាយតម្លៃ (M&E) ឬក្នុងការរៀបចំដំណើរការ និងយន្តការពិនិត្យតាមដាន និងវាយតម្លៃ។ ការចូលរួមប្រកបដោយអត្ថន័យរបស់ពួកគេមានសារៈសំខាន់ណាស់។

កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការប្រមូលទិន្នន័យស្ដីពីជនមានពិការភាព រួមទាំងសម្រាប់ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា (GPCC) និងអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ដោយប្រើកម្រងសំណួរខ្លីរបស់ក្រុមវ៉ាស៊ីនតោន (Washington Group Short Set on Functioning)។

នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០២៣ សម្ដេច ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី បានចុះហត្ថលេខាលើអនុក្រឹត្យលេខ ២០២ ស្ដីពីអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន។ អនុក្រឹត្យនេះបែងចែកពិការភាពជាប្រាំប្រភេទ៖ ពិការភាពកាយសម្បទា ពិការភាពវិញ្ញាណដឹង ពិការភាពសតិបញ្ញា ពិការភាពផ្លូវចិត្ត និងពិការភាពផ្សេងៗទៀត។ ប្រភេទពិការភាពនីមួយៗត្រូវបានបែងចែកជាបីកម្រិត៖ កម្រិតទី ១ ( ធ្ងន់ ) កម្រិតទី ២ ( មធ្យម ) និងកម្រិតទី ៣ ( ស្រាល )[27]។ ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព (DMIS) របស់ក្រសួងសង្គមកិច្ច  អតីតយុទ្ធជន និងយុវនីតិសម្បទា មានទិន្នន័យលម្អិតស្ដីពីជនមានពិការភាពនៅគ្រប់ខេត្ត។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC-SG) បានអភិវឌ្ឍប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ

---

[25] សម្រាប់ព័ត៌មានបន្ថែម សូមមើល *Disability Inclusive Budgeting from a Child Rights Perspective: Pathways of Change for UNICEF and Partners*

[26] *Accessible meetings and events: a toolkit*, CBM, May 2021

[27] អនុក្រឹត្យលេខ ២០២ ស្ដីពីអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០២៣ អនុក្រឹត្យនេះមានគោលបំណង ២ ៖ រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មពិការភាពសម្រាប់ជាមូលដ្ឋានក្នុងការលើកកម្ពស់ជីវភាព ការទទួលបានសេវាសង្គម និងកម្មវិធីជំនួយសង្គម និងផ្ដល់បណ្ណសម្គាល់ជនមានពិការភាព។

(M&E) ដើម្បីវាស់វែងវឌ្ឍនភាពក្នុងការអនុវត្ត NDSP3 ដែលនឹងវាស់វែងផងដែរនូវវឌ្ឍនភាពនៃបរិយាបន្នពិការភាព នៅក្នុងកម្មវិធីសំខាន់ៗ។ ទោះយ៉ាងណា មិនមែនគ្រប់ក្រសួង ស្ថាប័ន និងអ្នកផ្តល់សេវាផ្សេងទៀតទាំងអស់សុទ្ធតែមានយន្តការដែលកំពុងដំណើរការ ដើម្បីប្រមូលទិន្នន័យស្តីពីជនមានពិការភាពដែលទទួលបានកម្មវិធីរបស់ពួកគេ រួមទាំងទិន្នន័យស្តីពីអ្នកដែលទើបតែមានកម្សោយ ឬយន្តការដើម្បីចែករំលែកទិន្នន័យ និងលទ្ធផលស្រាវជ្រាវផ្សេងទៀតជាមួយអគ្គលេខាធិការដ្ឋាននេះ និងអ្នកផ្តល់សេវាផ្សេងទៀត។

យើងមានឯកសារណែនាំសម្រាប់ពង្រឹងការប្រមូលទិន្នន័យពិការភាព ដើម្បីគាំទ្រដល់ការពិនិត្យតាមដាន និងវាយតម្លៃ។ សៀវភៅណែនាំស្តីពី «*ការប្រមូល និងការប្រើប្រាស់ទិន្នន័យស្តីពីពិការភាពដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការអភិវឌ្ឍបែបបរិយាបន្ន*» ផ្តល់ការណែនាំជាក់ស្តែងស្តីពីវិធីសាស្រ្តប្រមូលទិន្នន័យ។ សៀវភៅណែនាំនេះបង្ហាញពីទិដ្ឋភាពសង្ខេបនៃការអនុវត្តការអភិវឌ្ឍប្រកបដោយបរិយាបន្នពិការភាព និងតម្រូវការទិន្នន័យដើម្បីគាំទ្រដល់ការអនុវត្តនេះ បញ្ហា និងគោលការណ៍សំខាន់ៗមួយចំនួនដែលត្រូវពិចារណា នៅពេលដែលការប្រមូលទិន្នន័យមានបរិយាបន្នពិការភាព របៀបប្រើប្រាស់ព័ត៌មានបែបនេះដើម្បីពង្រឹងបរិយាបន្នពិការភាពនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង និងកម្មវិធី និងវិធីសាស្រ្ត និងឧបករណ៍ដែលអាចយកមកប្រើប្រាស់ដើម្បីប្រមូលទិន្នន័យទាំងជាមួយមនុស្សពេញវ័យ និងកុមារដែលមានពិការភាព[28]។

លើសពីនេះ អង្គការយូនីសេហ្វ បានរៀបចំសេចក្តីណែនាំដើម្បីគាំទ្រដល់ការអភិវឌ្ឍការប្រមូលទិន្នន័យដែលមានបរិយាបន្នពិការភាព ការពិនិត្យតាមដាន និងការធ្វើរបាយការណ៍ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ (WASH) ដែលអាចត្រូវបានកែសម្រួលសម្រាប់ប្រើប្រាស់ជាមួយប្រភេទកម្មវិធីផ្សេងទៀត។ សេចក្តីណែនាំនេះមានអភិក្រម និងគន្លឹះដើម្បីប្រមូលទិន្នន័យពិការភាពដែលអាចកំណត់អត្តសញ្ញាណជនមានពិការភាព និងកំណត់រកឧបសគ្គរបស់ពួកគេក្នុងការទទួលបានកម្មវិធី ក៏ដូចជាពិនិត្យតាមដាន និងវាយការណ៍អំពីលទ្ធផល និងផលជះនៃកម្មវិធីនានាសម្រាប់ជនមានពិការភាព[29]។

## ការអភិវឌ្ឍប្រកបដោយបរិយាបន្នពិការភាព

ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍត្រូវតែខិតខំរួមបញ្ចូល និងផ្តល់អត្ថប្រយោជន៍ដល់ជនមានពិការភាព។ ការអភិវឌ្ឍប្រកបដោយបរិយាបន្នពិការភាពផ្តល់ឱកាសឱ្យជនមានពិការភាពចូលរួមដោយស្មើភាពជាមួយអ្នកដទៃ និងសម្រេចបានសក្តានុពលពេញលេញដើម្បីក្លាយខ្លួនជាអ្នករួមចំណែកប្រកបដោយផលិតភាពដល់កំណើនសេដ្ឋកិច្ចក្នុងសហគមន៍ និងប្រទេសរបស់ពួកគេ។ អភិក្រមបរិយាបន្នពិការភាពសម្រាប់ការអភិវឌ្ឍព្យាយាមកំណត់ និងដោះស្រាយឧបសគ្គដែលរារាំងជនមានពិការភាពមិនឱ្យចូលរួម និងទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍ។

*កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា* បញ្ជាក់ឡើងវិញថា ការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ (NSDP) គួរ «ធានាមិនទុកឱ្យប្រជាជនណាម្នាក់ស្ថិតនៅក្រៅដំណើរការអភិវឌ្ឍន៍[30]»។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) ក៏មានបរិយាបន្នពិការភាពផងដែរ។ លើសពីនេះ កម្ពុជាគឺជាប្រទេសហត្ថលេខីនៃ*យុទ្ធសាស្រ្តអ៊ីនឈាន់* ដែលជាកិច្ចព្រមព្រៀងកម្រិតតំបន់ដំបូងគេស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយបរិយាបន្នពិការភាព។

ការអភិវឌ្ឍសហគមន៍តាមបែបបរិយាបន្ន (CBID) គឺជាអភិក្រមមួយទៀតដែលដំណើរការនៅកម្រិតមូលដ្ឋានដើម្បីដោះស្រាយឧបសគ្គរាំងបរិយាបន្នជនមានពិការភាព។ អភិក្រមនេះអាចធានាថា ជនមានពិការភាពត្រូវបានគោរព និងដាក់បញ្ចូលទៅក្នុងសហគមន៍របស់ពួកគេ ដោយស្មើភាពជាមួយអ្នកដទៃ ក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅប្រចាំថ្ងៃ។ CBID ផ្តល់ដំណោះស្រាយជាក់ស្តែងលើបញ្ហាប្រឈមរបស់ជនមានពិការភាព គ្រួសារ និងសហគមន៍

---

28 Practice note: Collecting and using data on disability to inform inclusive development, Plan International Australia and CBM Australia-Nossal Institute Partnership for Disability Inclusive Development, July 2015

29 MAKE IT COUNT: Guidance on disability inclusive WASH programme data collection, monitoring and reporting, UNICEF, 2021

30 កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ ២០២៣-២០២៨, ២

របស់ពួកគេ។ កម្មវិធី CBID អាចរួមបញ្ចូលសកម្មភាពពាក់ព័ន្ធនឹងសុខភាព ការអប់រំ របរចិញ្ចឹមជីវិត សង្គម និងការបង្កើនភាពអង់អាច តាមរយៈការធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូក្នុងមូលដ្ឋាន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការតំណាងជនមានពិការភាព។ CBID អាចផ្តល់ការរួមចំណែកយ៉ាងមានតម្លៃដល់គោលដៅ "មិនទុកឱ្យប្រជាជនណាម្នាក់ស្ថិតនៅក្រៅដំណើរការអភិវឌ្ឍន៍" របស់រាជរដ្ឋាភិបាលកម្ពុជា[31]។

ខាងក្រោមនេះជាឯកសារណែនាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍដែលមានបរិយាបន្នពិការភាព ៖

- ***កញ្ចប់ឧបករណ៍សម្រាប់ការអភិវឌ្ឍដែលមានបរិយាបន្នពិការភាព*** គ្របដណ្តប់លើបញ្ហានានា ដូចជា អ្វីទៅជាពិការភាព គំរូនៃពិការភាព ភាសា និងទំនាក់ទំនង សេចក្តីផ្តើមស្តីពីការអភិវឌ្ឍដែលមានបរិយាបន្នពិការភាព និងធាតុផ្សំសំខាន់ៗនៃការអភិវឌ្ឍដែលមានបរិយាបន្នពិការភាព[32]។

ជម្នះរាល់ឧបសគ្គ ត្រូវការយុទ្ធសាស្ត្រប្រកបដោយបរិយាបន្ន ដែលឆ្លើយតប និងដោះស្រាយគ្រប់ទម្រង់នៃឧបសគ្គ ខណៈពេលដែលដំណោះស្រាយមួយៗ តាមផ្នែកមិនអាចដោះស្រាយបាន។




ប្រភព៖ កែសម្រួលពីឯកសារ «ការធ្វើឱ្យ PRSP មានបរិយាបន្ន ផលិតដោយអង្គការ HI និង អង្គការ CBM, ខែមករា 2006, ទីក្រុង Munich, ប្រទេសអាល្លឺម៉ង់, 58

[31] សម្រាប់ព័ត៌មានបន្ថែមស្តីពី CBID និង CBID នៅកម្ពុជា សូមចូលទៅកាន់ ៖ https://cbid5.dac.gov.kh/background/។

[32] Disability-Inclusive Development Toolkit, Christian Blind Mission (CBM), January 2017

# ផ្នែកទី ៣ សកម្មភាពអាទិភាពដើម្បីពង្រឹងបរិយាបន្នពិការភាព

កម្ពុជាមានរចនាសម្ព័ន្ធរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលផ្តោតលើបញ្ហាពាក់ព័ន្ធនឹងការពង្រឹងបរិយាបន្នពិការភាព ៖ ក្រសួង និងទីភ្នាក់ងារនានា ស្ថាប័នសម្របសម្រួលអន្តរក្រសួង និងពហុភាគី និងគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារជាច្រើន[33]។ បច្ចុប្បន្ន មានការយល់ដឹងកាន់តែច្រើនឡើងថា កិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាសិទ្ធិ និងបរិយាបន្នរបស់ប្រជាជនដែលមានពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យទាមទារអភិក្រមទូទាំងរដ្ឋាភិបាល និងពហុវិស័យ។ ទោះយ៉ាងណា ការធានាបរិយាបន្នពិការភាពប្រកបដោយអត្ថន័យនៅក្នុងគោលនយោបាយ កម្មវិធី និងគម្រោងនៅថ្នាក់ជាតិ ខេត្ត ស្រុក និងឃុំ នៅតែជាបញ្ហាប្រឈម។

ជនមានពិការភាពអាចត្រូវការសេវា និងឱកាសផ្សេងៗនៅពេលវេលាខុសៗគ្នាក្នុងឆាកជីវិតរបស់ពួកគេ។ អភិក្រមគ្រប់ជ្រុងជ្រោយ និងនិរន្តរភាពនៃលទ្ធភាពទទួលបានសេវា និងឱកាស ជួយលើកកម្ពស់សុខុមាលភាព។ កន្លងមក អ្នកពាក់ព័ន្ធសំខាន់ៗផ្តោតចំណាប់អារម្មណ៍លើការផ្តល់កិច្ចអន្តរាគមន៍ផ្នែកតាមពិការភាព ដូចជា តាមរយៈមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា (PRC) គម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈ សាលារៀនដែលត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងតម្រូវការរបស់កុមារមានពិការភាពជាក់លាក់ ការបកប្រែភាសាសញ្ញាកម្ពុជា (CSL) និងការបោះពុម្ពអក្សរប្រៃយ៍។

ដើម្បីសម្រេចចក្ខុវិស័យ និងបេសកកម្មនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០២៤-២០២៨ (NDSP 3) ចាំបាច់ត្រូវមានអភិក្រមទូទាំងរដ្ឋាភិបាលដែលទាក់ទិននឹងអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការណ៍នេះនឹងតម្រូវឱ្យមានទាំងការដាក់បញ្ចូលពិការភាពទៅក្នុងកម្មវិធី និងឱកាសសំខាន់ៗប្រកបដោយប្រសិទ្ធភាព និងការផ្លាស់ប្តូរផ្នត់គំនិតដែលចាត់ទុកពិការភាពជាបញ្ហាដាច់ដោយឡែក ដែលជាការទទួលខុសត្រូវរបស់ក្រសួងតែមួយ ឬស្ថាប័នដែលធ្វើការផ្នែកពិការភាព។។

ទិសដៅយុទ្ធសាស្ត្រទាំង ៧ (ប្រាំពីរ) ដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០២៤-២០២៨ ផ្តល់នូវក្របខណ្ឌសកម្មភាពដើម្បីពង្រឹងបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព តាមរយៈការបញ្ជ្រាបទៅក្នុងគោលនយោបាយ និងកម្មវិធីសំខាន់ៗ មានជាអាទិ៍ (១) ការងារ មុខរបរ និងសន្តិសុខផ្នែកសេដ្ឋកិច្ច (២) សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព (៣) ការអប់រំនិងការសិក្សាពេញមួយជីវិត (៤) ប្រព័ន្ធគាំពារសង្គមនិងជីវភាពរស់នៅសមស្រប (៥) សហគមន៍ដែលមានបរិយាបន្ន និងមានជាសុកវត្ត (៦) សមភាពយេនឌ័រ សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌ (៧) ស្ថានភាពហានិភ័យ គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ។

## ៣.១ ការងារមុខរបរ និងសន្តិសុខផ្នែកសេដ្ឋកិច្ច

### *ទិដ្ឋភាពទូទៅ*

ជនមានពិការភាព មានសិទ្ធិទទួលបានឱកាសការងារ និងមុខរបរសមរម្យដែលផ្តល់ប្រាក់ខែសមស្របទៅតាមគុណវុឌ្ឍិរបស់ពួកគេ ដើម្បីលើកកម្ពស់ការរស់នៅដោយឯករាជ្យ និងសន្តិសុខសេដ្ឋកិច្ចរបស់ពួកគេ ដោយស្មើភាពជាមួយអ្នកដទៃ។ ជាមួយនឹងលទ្ធភាពទទួលបានឱកាស ជនមានពិការភាពអាចជាអ្នករួមចំណែកប្រកបដោយ

[33] សម្រាប់ព័ត៌មានបន្ថែមស្តីពីភាគីពាក់ព័ន្ធ សូមមើលឧបសម្ព័ន្ធ ២។

ផលិតភាពដល់គ្រួសារ និងសហគមន៍របស់ពួកគេ។ *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា* មានបទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍការងារ និងមុខរបរ និងដើម្បីបង្កើនលទ្ធភាពទទួលបានសេវារកការងារឱ្យធ្វើ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ[34]។ ទោះយ៉ាងណា ជនមានពិការភាពជាច្រើនបានប្រឈមនឹងឧបសគ្គក្នុងការទទួលបានការងារប្រកបដោយអត្ថន័យ និងសន្តិសុខសេដ្ឋកិច្ច ដូចជា ការមាក់ងាយ ការរើសអើង និងគំនិតសន្មតជាមុនចំពោះសមត្ថភាពរបស់ជនមានពិការភាពក្នុងចំណោមនិយោជក មិត្តរួមការងារ គ្រូបង្រៀន និងអ្នកផ្តល់សេវាហិរញ្ញវត្ថុ កង្វះហេដ្ឋារចនាសម្ព័ន្ធដែលបង្កលក្ខណៈងាយស្រួល សម្ភារៈបណ្តុះបណ្តាល និងគោលវិធីបង្រៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ (VTC) និងកង្វះការយល់ដឹងក្នុងចំណោមជនមានពិការភាពអំពីឱកាសដែលមាន និងរបៀបតស៊ូមតិឱ្យគាំទ្រសិទ្ធិទទួលបានការងារ និងសន្តិសុខសេដ្ឋកិច្ចរបស់ពួកគេ។

ការសិក្សាថ្មីមួយស្តីពីការងារបែបបរិយាបន្នក្នុងវិស័យកាត់ដេរ ស្បែកជើង និងផលិតផលបំលាស់ទី ដែលជានិយោជកធំជាងគេ និងជាវិស័យនាំចេញចម្បងរបស់កម្ពុជា បានកំណត់ឧបសគ្គសំខាន់ៗមួយចំនួនដែលជាបញ្ហាប្រឈមរបស់ជនមានពិការភាពក្នុងវិស័យនេះ។ ឧបសគ្គទាំងនេះទំនងជាត្រូវបានឆ្លុះបញ្ចាំងក្នុងវិស័យផ្សេងទៀត ហើយនឹងទាមទារការផ្តោតការយកចិត្តទុកដាក់ ប្រសិនបើចង់សម្រេចបានសិទ្ធិរបស់ជនមានពិការភាពក្នុងការទទួលបានឱកាសការងារ និងមុខរបរសមរម្យ ៖ ជម្រើសធ្វើដំណើរនៅមានកម្រិតសម្រាប់ជនមានពិការភាព បរិយាកាសការងារមិនបង្កលក្ខណៈងាយស្រួល ដែលរឹតត្បិតចល័តភាព និងបង្កហានិភ័យសុវត្ថិភាព កម្រិតការយល់ដឹងទាបក្នុងចំណោមនិយោជកអំពីសិទ្ធិជនមានពិការភាព និងកាតព្វកិច្ចចំពោះពួកគេ និងអត្ថប្រយោជន៍នៃការជ្រើសរើសជនមានពិការភាព កង្វះតម្លាភាព និងគណនេយ្យភាពក្នុងអធិការកិច្ចរបស់រដ្ឋាភិបាល ក៏ដូចជាកង្វះការយល់ដឹងអំពីកម្សោយ ផ្សេងៗ និងផាសុកសមរម្យដែលចាំបាច់ដើម្បីផ្តល់ការងារសមរម្យដល់ជនមានពិការភាព ឱកាសផ្គូផ្គងការងារមាន កម្រិត លទ្ធភាពមានកម្រិតរបស់ជនមានពិការភាពក្នុងការទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ បទដ្ឋាន និងឥរិយាបថសង្គមបែបរើសអើងដែលបណ្តែតបណ្តោយឱ្យមានការរើសអើង និងកង្វះទិន្នន័យ និងឧទាហរណ៍នៃបរិយាបន្នជោគជ័យ ក៏ដូចជាកង្វះទិន្នន័យគ្រប់ជ្រុងជ្រោយស្តីពីឧបសគ្គ និងបញ្ហាប្រឈមរបស់ជនមានពិការភាព[35]។

ច្បាប់ និងផែនការដែលត្រូវបានបង្កើតឡើង អាចជួយបង្កើនលទ្ធផលការងារ និងសន្តិសុខសេដ្ឋកិច្ចសម្រាប់ជនមានពិការភាព ក៏ដូចជាលើកកម្ពស់បរិយាបន្ន និងការចូលរួមប្រកបដោយប្រសិទ្ធភាព។ ក្នុងឆ្នាំ ២០១០ អនុក្រឹត្យ លេខ ១០៨ អនក្រ.បក បានកំណត់អត្រាសម្រាប់ការជ្រើសរើសជនពិការចូលបម្រើការងារ។ សម្រាប់ក្រសួង និងស្ថាប័នរដ្ឋផ្សេងទៀតដែលមានមន្ត្រីរាជការច្រើនជាង ៥០ នាក់ មន្ត្រីរាជការ ២ ភាគរយដែលបានជ្រើសរើសចូលបម្រើការត្រូវតែជាជនមានពិការភាព។ សម្រាប់នីតិបុគ្គលផ្សេងទៀតដែលមានបុគ្គលិកច្រើនជាង ១០០ នាក់ ១ ភាគរយនៃបុគ្គលិកដែលបានជ្រើសរើសចូលបម្រើការ ត្រូវតែជាជនមានពិការភាព។ គ្រប់ស្ថាប័នទាំងអស់ត្រូវបានតម្រូវឱ្យដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការជ្រើសរើសជនមានពិការភាពចូលបម្រើការងារ។ ប្រសិនបើស្ថាប័នណា មួយមិនបំពេញតាមអត្រាការងារនេះទេ ស្ថាប័ននោះត្រូវធ្វើវិភាគទានទៅរដ្ឋាភិបាល[36]។

មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ការជ្រើសរើសជនមានពិការភាពចូលបម្រើការងារ អាចត្រូវការការកែសម្រួលបរិយាកាសការងារ។ តាមសេចក្តីរាយការណ៍ និយោជកមួយចំនួនបានជ្រើសរើសយកការធ្វើវិភាគទានជាជាងចំណាយលើការកែសម្រួល។ នៅឆ្នាំ ២០១២ សារាចរអន្តរក្រសួង (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) លេខ ០០៥ ស.អ.យ.សរណន បានផ្តល់ការណែនាំដើម្បីធានាផាសុកសមរម្យក្នុងការជ្រើសរើសជនមានពិការភាព ដែលមានគុណវុឌ្ឍិ និងសមត្ថភាពចាំបាច់ដើម្បីបំពេញ ភារកិច្ចក្នុងមុខតំណែងជាក់លាក់មួយ ដោយគ្មានការរើសអើង។ ផាសុកសមរម្យអាចទាមទារឱ្យមានការ

---

34 Political Platform of the Royal Government of Cambodia of the Seventh Legislature of the National Assembly for Nation Building and Defense 2023-2028, 21-22

35 សម្រាប់ព័ត៌មានបន្ថែម សូមមើល *Promoting the Inclusion of Persons with Disabilities in the GFT Sector: Sustainability Recommendations Paper*, GIZ-FABRIC, July 2024

36 សម្រាប់ព័ត៌មានបន្ថែម សូមមើល អនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១០ ស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ។

កែសម្រួល និងកែប្រែបរិក្ខារសង្ហារឹម និងបរិយាកាសការងារដើម្បីធានាការបង្កលក្ខណៈងាយស្រួលដើម្បីឱ្យបុគ្គលិកដែលមានពិការភាព គ្រប់ប្រភេទ អាចបំពេញការងាររបស់ពួកគេបាន ដូចជា ការដំឡើងជម្រាល ទ្វារធំទូលាយ បន្ទប់ទឹកដែលមានផាសុកវត្ថុ ជណ្តើរយន្តដែលមានប៊ូតុង និងស្លាកសញ្ញាជាអក្សរប្រៃយ៍ កុំព្យូទ័រដែលមានបច្ចេកវិទ្យាជំនួយ ឬការកែប្រែម៉ោងធ្វើការ[37]។



នាយកដ្ឋានសុខុមាលភាពជនពិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានប្រព័ន្ធ OAKAS ដើម្បីចុះឈ្មោះជនមានពិការភាពដែលកំពុងស្វែងរកការងារ។ ប្រព័ន្ធ OAKAS ត្រូវបានភ្ជាប់ជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បីសម្រួលឱ្យមានការផ្តល់ឱកាសកាន់តែច្រើនសម្រាប់ជនពិការក្នុងការទទួលបានការងារមានប្រាក់ខែ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងអនុវត្តផែនការ និងកម្មវិធីដែលអាចជួយលើកកម្ពស់ជីវភាព រស់នៅ និងសន្តិសុខសេដ្ឋកិច្ចរបស់ជនមានពិការភាព តាមរយៈលទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានឱកាសការងារ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ)។ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨* របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមបញ្ចូលគោលបំណងរួមចំណែកដល់ការបង្កើត ការថែរក្សា និងការបង្កើនការងារ និងអភិវឌ្ឍធនធានមនុស្ស ប្រកបដោយចំណេះដឹង និងជំនាញ។ ផែនការយុទ្ធសាស្ត្រនេះផ្តល់ឱកាសសម្រាប់ប្រជាជនមកពីគ្រួសារងាយរងគ្រោះ។

*ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ឆ្នាំ ២០២៣-២០៣៥* របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានបរិយាបន្នពិការភាព និងរួមបញ្ចូលការផ្តល់ឱកាសរៀនសូត្រពេញមួយជីវិតដើម្បីធានាថា ប្រជាពលរដ្ឋគ្រប់រូបមានជំនាញវិជ្ជាជីវៈយ៉ាងតិចមួយ។ ផ្នែកសំខាន់ៗនៃផែនទីបង្ហាញផ្លូវនេះ រួមមានការលើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធានាថា ជនមានពិការភាពអាចទទួលបានឱកាស[38]។

នៅទូទាំងប្រទេស មានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជាង ៣០។ ទោះយ៉ាងណា មិនមែនគ្រប់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទាំងអស់ សុទ្ធតែមានផាសុកវត្ថុផ្នែករូបវន្តសម្រាប់ជនមានពិការភាពនោះទេ ហើយសម្ភារៈបណ្តុះបណ្តាលមិនមានផ្តល់ក្នុងទម្រង់ដែលមានផាសុកវត្ថុ ចំណែកវគ្គសិក្សាដែលផ្តល់ ជូន មិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារនៅឡើយ។ លើសពីនេះ
ជនមានពិការភាព អាចមិនមានធនធានដើម្បីចំណាយលើថ្លៃអាហារ និងថ្លៃស្នាក់នៅពេលចូលរួមក្នុងការបណ្តុះបណ្តាល។ ដើម្បីបង្កើនលទ្ធភាពទទួលបាន នៅឆ្នាំ ២០២៣ មានការបណ្តុះបណ្តាលបុគ្គលិកនៅមជ្ឈមណ្ឌលបណ្តុះ បណ្តាលវិជ្ជាជីវៈមួយចំនួន ដោយប្រើប្រាស់*គោលការណ៍ណែនាំដែលទើបតែបង្កើតថ្មីស្តីពីការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ) បែបបរិយាបន្នសម្រាប់ជនមានពិការភាព*[39]។



ដើម្បីទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី អ.ប.វ និងឱកាសមុខរបរផ្សេងទៀត និងដើម្បីសម្រេចបានសន្តិសុខសេដ្ឋកិច្ច ជនមានពិការភាពក៏ត្រូវការសេវាហិរញ្ញវត្ថុ ដូចជា ប្រាក់កម្ចី និងគណនីសន្សំ ដូចជនគ្មានពិការភាព ដែរ។ ទោះយ៉ាងណា ពួកគេច្រើនតែត្រូវបាន

---

[37] សម្រាប់ព័ត៌មានបន្ថែម សូមមើលសារាចរអន្តរក្រសួង (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) លេខ ០០៥ ស.អ.យ.ស.រ.ណ.ន ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីផាសុកសមរម្យសម្រាប់ការជ្រើសរើសជនពិការចូលបម្រើការងារ។

[38] សម្រាប់ព័ត៌មានបន្ថែម សូមមើល [Cambodia Skills Development Roadmap 2023-2035]

[39] [Guide on Inclusive Technical and Vocational Education and Training (TVET) for People with Disabilities], People in Need and Agile, 2023

ផាត់ចេញពីសេវាហិរញ្ញវត្ថុ ដោយសារការមាក់ងាយ និងឥរិយាបថរើសអើង ដោយសារពួកគេខ្វះទ្រព្យបញ្ចាំ ដូចជាដីធ្លីដើម្បីធានាប្រាក់កម្ចី ឬដោយសារពួកគេខ្វះព័ត៌មានស្តីពីកម្មវិធីដែលមានផ្តល់ ឬជំនួយដែលបានផ្តល់ឱ្យដើម្បីគាំទ្រដល់ដំណើរការដាក់ពាក្យស្នើសុំកម្ចី។ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ ដូចជា ឥណទានខ្នាតតូច មីក្រូហិរញ្ញវត្ថុ និងប្រាក់សន្សំ ជំនួយឧបត្ថម្ភ និងក្រុមជួយខ្លួនឯង អាចបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ជនមានពិការភាពឱ្យចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងសកម្មភាពផ្សេងទៀត។ ជាពិសេស លទ្ធភាពទទួលបានប្រព័ន្ធហិរញ្ញវត្ថុអាចជួយឱ្យជនមានពិការភាពក្លាយជាអ្នករួមចំណែកប្រកបដោយផលិតភាពដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមក្នុងសហគមន៍របស់ពួកគេ។ ចាំបាច់ត្រូវមានការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនលើការបង្កើនលទ្ធភាពរបស់ជនមានពិការភាពក្នុងការទទួលបានសេវាហិរញ្ញវត្ថុ។

### *ឯកសារណែនាំដើម្បីពង្រឹងបរិយាបន្នពិការភាព*

ខាងក្រោមនេះជាឯកសារណែនាំ ដើម្បីបង្កើនលទ្ធភាពទទួលបានឱកាសការងារ និង អ.ប.វ និងសេវាហិរញ្ញវត្ថុបែបបរិយាបន្ន៖

- ***ជាសុកសមរម្យនៅកន្លែងធ្វើការ - គោលការណ៍ណែនាំ និងការអនុវត្តល្អ*** ផ្តល់ព័ត៌មាន ឧទាហរណ៍ជាក់ស្តែង និងឯកសារយោងដើម្បីជួយឱ្យនិយោជកបំពេញលក្ខខណ្ឌជាសុកសមរម្យ។ គោលការណ៍ណែនាំទាំងនេះដើរតួនាទីជាធនធានដ៏មានតម្លៃសម្រាប់ការកែសម្រួលការអនុវត្តនៅកន្លែងធ្វើការ ដើម្បីផ្តល់ការគាំទ្រកាន់តែប្រសើរដល់កម្លាំងពលកម្មទូទៅ និងដើម្បីបង្កើតបរិយាកាសការងារដែលកាន់តែមានបរិយាបន្ន និងជាសុកសម្រាប់បុគ្គលិកទាំងអស់ ដោយមិនគិតពីសមត្ថភាពរបស់ពួកគេ[40]។
- ***គោលការណ៍ណែនាំស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ) បែបបរិយាបន្នសម្រាប់ជនមានពិការភាព*** មានគោលបំណងផ្តល់ការណែនាំជាក់ស្តែង និងផ្អែកលើភស្តុតាងដល់គ្រឹះស្ថាន អ.ប.វ និងអ្នកពាក់ព័ន្ធ ដើម្បីលើកកម្ពស់ និងអនុវត្តគោលនយោបាយ និងការអនុវត្ត អ.ប.វ បែបបរិយាបន្ន។ គោលការណ៍ណែនាំនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធានាថាប្រជាពលរដ្ឋគ្រប់គ្នា រួមទាំងជនមានពិការភាព មានលទ្ធភាពស្មើគ្នាក្នុងការទទួលបានឱកាសអប់រំ និងការបណ្តុះបណ្តាលប្រកបដោយគុណភាពដែលអាចឱ្យពួកគេអភិវឌ្ឍជំនាញ និងសមត្ថភាពសម្រាប់ការងារសមរម្យ និងបរិយាបន្នសង្គម។ គោលការណ៍ណែនាំនេះសង្កត់ធ្ងន់លើតម្រូវការបង្កើតបរិស្ថានគាំទ្រសម្រាប់ជនមានពិការភាពដើម្បីចូលរួមពេញលេញក្នុងការបណ្តុះបណ្តាល និងការងារដែលនឹងរួមចំណែកដល់សេដ្ឋកិច្ចកម្ពុជា[41]។
- ***សេវាហិរញ្ញវត្ថុសម្រាប់ទាំងអស់គ្នា៖ មគ្គុទេសក៍អំពីការអនុវត្តបរិយាបន្នពិការភាពសម្រាប់អ្នកផ្តល់សេវាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា*** ផ្តល់ការណែនាំដល់អ្នកផ្តល់សេវាហិរញ្ញវត្ថុដើម្បីធ្វើឱ្យផលិតផល និងសេវារបស់ពួកគេបង្កលក្ខណៈងាយស្រួលដល់អតិថិជនទាំងអស់ រួមទាំងជនមានពិការភាព។ ខណៈដែលសៀវភៅណែនាំនេះផ្តល់ព័ត៌មានជាក់លាក់មួយចំនួនសម្រាប់កម្ពុជា វាត្រូវបានរៀបចំឡើងដើម្បីឱ្យមានភាពពាក់ព័ន្ធនឹងអ្នកផ្តល់សេវាហិរញ្ញវត្ថុនៅក្នុងប្រទេសណាមួយ នៅដំណាក់កាលណាមួយនៃដំណើរការបរិយាបន្នពិការភាពរបស់ពួកគេ។ ដំបូង សៀវភៅណែនាំនេះគូសបញ្ជាក់អំពីហេតុផលនៃសេវាហិរញ្ញវត្ថុដែលមានបរិយាបន្នពិការភាព បញ្ហាប្រឈមរបស់ជនមានពិការភាពក្នុងការទទួលបានសេវាហិរញ្ញវត្ថុ និងសារៈសំខាន់នៃអភិក្រមប្រព័ន្ធអេកូឡូស៊ីដើម្បីជម្នះបញ្ហាប្រឈមទាំងនេះ។ បន្ទាប់មក សៀវភៅណែនាំនេះផ្តល់ការណែនាំជាក់លាក់សម្រាប់ការអនុវត្តដោយអ្នកផ្តល់សេវាហិរញ្ញវត្ថុ រួមទាំងដំណើរការបីជំហានសម្រាប់បរិយាបន្នពិការភាព ការពិចារណាពីបរិយាបន្ននៅគ្រប់ដំណាក់កាលនៃវដ្តជីវិតអតិថិជន និងកញ្ចប់ឧបករណ៍សម្រាប់ជាសុកវត្ថុផ្នែករូបវន្ត លទ្ធភាពប្រើប្រាស់ប្រព័ន្ធឌីជីថល ទំនាក់ទំនងបែបបរិយាបន្ន និងព័ត៌មានដែលជាសុកវត្ថុ[42]។

---

40 Reasonable accommodation at work – Guidelines and good practices, Directorate-General for Employment, Social Affairs and Inclusion, European Commission, March 2024

41 Guide on Inclusive Technical and Vocational Education and Training (TVET) for People with Disabilities, People in Need and Agile, 2023

42 សម្រាប់ព័ត៌មានបន្ថែម សូមមើល Finance for All: A Practical Guide to Disability Inclusion for Financial Services Providers in Cambodia, Good Return and Chamroeun Microfinance, March 2023

## ៣.២ សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព

### *ទិដ្ឋភាពទូទៅ*

ប្រជាជនដែលមានពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យ នឹងត្រូវការលទ្ធភាពទទួលបានសេវាសុខភាពពេញមួយជីវិតរបស់ពួកគេ ប៉ុន្តែមនុស្សពេញវ័យ និងកុមារជាច្រើនដែលមានពិការភាព ប្រឈមនឹងឧបសគ្គក្នុងការទទួលបានការថែទាំសុខភាព ការស្តារលទ្ធភាពពលកម្ម និងសេវាផ្សេងទៀតដែលពួកគេត្រូវការដើម្បីបង្កើនសុខុមាលភាពផ្ទាល់ខ្លួនដោយសារបញ្ហានានា ដូចជា ការមាក់ងាយ និងការរើសអើង មូលដ្ឋានសុខាភិបាលមិនបង្កលក្ខណៈងាយស្រួលផ្នែករូបវន្ត ថ្លៃចំណាយលើការធ្វើដំណើរទៅរកសេវា និងការចំណាយប្រាក់ផ្ទាល់ខ្លួន អ្នកផ្តល់សេវាថែទាំសុខភាពអាចមិនមានជំនាញដើម្បីបំពេញការងារឱ្យបានសមស្របជាមួយជនមានពិការភាព និងកង្វះព័ត៌មានក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួល។

លើសពីនេះ ស្ត្រី និងក្មេងស្រីជាច្រើនដែលមានពិការភាព មិនសូវមានលទ្ធភាពទទួលបានព័ត៌មានសមស្របស្តីពីសិទ្ធិរបស់ពួកគេ និងសេវាទាក់ទងនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ដោយសារការមាក់ងាយ ផ្នត់គំនិត និងកង្វះការទទួលស្គាល់ថា ពួកគេក៏មានសិទ្ធិ និងតម្រូវការដូចស្ត្រី និងក្មេងស្រីដែលគ្មានពិការភាពដែរ។ បន្ថែមលើនេះ ស្ត្រី និងក្មេងស្រីដែលមានពិការភាព ងាយទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) ដែលបង្កផលវិបាកដល់លទ្ធភាពរបស់ពួកគេក្នុងការស្វែងរកជំនួយ និងទទួលបានសេវាសុខភាព។ កត្តាទាំងនេះរួមចំណែកធ្វើឱ្យមានភាពស្ទាក់ស្ទើរក្នុងការពិភាក្សាអំពីប្រធានបទទាក់ទងនឹងផ្លូវភេទ និងសុខភាពបន្តពូជ ដែលរឹតតែបន្ថយបង្អាក់មិនឱ្យមានការសន្ទនាដោយបើកចំហ និងលទ្ធភាពទទួលបានព័ត៌មាន និងសេវាចាំបាច់នានា។

*របាយការណ៍កម្រិតសកលស្តីពីសមធម៌សុខភាពសម្រាប់ជនមានពិការភាព* រកឃើញថា ការវិនិយោគលើលទ្ធភាពប្រកបដោយសមធម៌របស់ជនមានពិការភាពក្នុងការទទួលបានសេវាសុខភាព ផ្តល់ផលចំណេញខ្ពស់ដល់សេដ្ឋកិច្ច និងសង្គម។ ឧទាហរណ៍ អាចមានផលចំណេញជិត ១០ ដុល្លារអាមេរិកក្នុងការចំណាយ ១ ដុល្លារអាមេរិកលើការអនុវត្តការបង្ការ និងការថែទាំជំងឺមិនឆ្លង តាមបែបបរិយាបន្នពិការភាព[43]។



ក្រសួងសុខាភិបាលមានតួនាទីផ្តល់សេវាថែទាំសុខភាពដល់ប្រជាជន ទាំងអស់ រួមទាំងប្រជាជនដែលមានពិការភាព គ្រប់ប្រភេទ និងគ្រប់វ័យ។ ប្រព័ន្ធសុខាភិបាលសាធារណៈនៅកម្ពុជាចែកចេញជា ៣ កម្រិត៖

- កម្រិតជាតិ (ថ្នាក់កណ្តាល) ៖ នាយកដ្ឋានផ្សេងៗនៃក្រសួងសុខាភិបាល គ្រឹះស្ថានបណ្តុះបណ្តាល មជ្ឈមណ្ឌលជាតិ និងមន្ទីរពេទ្យជាតិ
- កម្រិតខេត្ត ៖ មន្ទីរសុខាភិបាលខេត្ត មជ្ឈមណ្ឌលបណ្តុះបណ្តាលភូមិភាគ និងមន្ទីរពេទ្យបង្អែកខេត្ត
- កម្រិតស្រុក ៖ ការិយាល័យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព។

គោលនយោបាយ និងផែនការរបស់ក្រសួងសុខាភិបាលដែលមានបរិយាបន្នពិការភាព *រួមមានផែនការយុទ្ធសាស្ត្រសុខាភិបាល ផែនការយុទ្ធសាស្ត្រសុខភាពផ្លូវចិត្ត ឆ្នាំ ២០២៣-២០៣២ សំណុំសកម្មភាពអប្បបរមាសម្រាប់មណ្ឌលសុខភាព (MPA) និងសំណុំសកម្មភាពបង្គ្រប់សម្រាប់មន្ទីរពេទ្យបង្អែក (CPA)*។ ទោះយ៉ាងណា ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល (HMIS) មិនទាន់បានប្រមូលទិន្នន័យស្តីពីពីជនមានពិការភាពទេ ដោយសារអតិថិជនដែលទទួលបានសេវា ត្រូវបានកំណត់អត្តសញ្ញាណតាមស្ថានភាពរោគវិនិច្ឆ័យ/រោគសាស្ត្រ ដូចជា ដាច់សរសៃឈាមខួរក្បាល ភាពទន់ខ្សោយ របួសខួរក្បាលធ្ងន់ធ្ងរ របួសដោយសារគ្រាប់មីន គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក។ល។ ហេតុនេះ មិនសូវមានទិន្នន័យបែបបរិមាណដើម្បីវាស់វែងសមិទ្ធផលនៃបរិយាបន្នពិការភាពនៅក្នុងយុទ្ធសាស្ត្រទាំងអស់នោះទេ។

*ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ ២០២៤-២០៣៥* ផ្តោតអាទិភាពលើការពង្រីកសេវាសុខភាពសំខាន់ៗ ដែលមានគុណភាពល្អ និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសសេវាថែទាំសុខភាពបឋមដោយផ្អែកលើអភិក្រមនៃការថែទាំចម្រុះដែលផ្តោតការយកចិត្តទុកដាក់លើមនុស្ស[44]។ មូលនិធិសមធម៌សុខាភិបាល (HEF) ដែលជាគម្រោងកិច្ចគាំពារសុខភាពសង្គមមួយ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគ្របដណ្តប់ការថែទាំសុខភាពដល់បុគ្គលមកពីគ្រួសារក្រីក្រ រួមទាំងគ្រួសារដែលមានសមាជិកជាជនមានពិការភាព តាមរយៈបណ្ណសមធម៌ ដើម្បីឱ្យពួកគេអាចទទួលបានទាំងអត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រនៅមូលដ្ឋានសុខាភិបាលសាធារណៈ និងអត្ថប្រយោជន៍មិនមែនវេជ្ជសាស្ត្រដែលរួមមានប្រាក់ឧបត្ថម្ភការធ្វើដំណើរ ប្រាក់ឧបត្ថម្ភថ្លៃអាហារសម្រាប់អ្នកថែទាំ និងប្រាក់ឧបត្ថម្ភបុណ្យសព។ គិតត្រឹមខែ ធ្នូ ឆ្នាំ ២០២៣ មូលនិធិសមធម៌សុខាភិបាលបានគ្របដណ្តប់លើប្រជាជនប្រមាណ ៧០៦.២៨០ គ្រួសារដែលមានបណ្ណសមធម៌ ស្មើនឹងប្រមាណ ៣ លាននាក់។ លទ្ធភាពទទួលបានសេវាថែទាំសុខភាពក្រោមមូលនិធិសមធម៌សុខាភិបាល ក៏ត្រូវបានពង្រីកទៅក្រុមប្រជាជនផ្សេងទៀតផងដែរ[45]។ ទោះយ៉ាងណា វាហាក់ដូចជាលទ្ធភាពទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃមិនមែនតែងតែមានសម្រាប់ជនមានពិការភាពដែលមានសិទ្ធិទទួលបាននោះទេ។




ការស្តារលទ្ធភាពពលកម្មគឺជាសេវាសុខភាពដ៏សំខាន់មួយនៃការគ្របដណ្តប់សុខភាពជាសកល (UHC) សម្រាប់បុគ្គលដែលមានបញ្ហាសុខភាព និងមាន ឬគ្មានពិការភាព ពេញមួយជីវិតរបស់ពួកគេ និងនៅក្នុងវដ្តនៃការថែទាំ។ ការស្តារលទ្ធភាពពលកម្មមានប្រសិទ្ធភាពក្នុងការពន្លឿនរយៈពេលជាសះស្បើយ បង្ការផលវិបាកដែលទាក់ទងនឹងស្ថានភាពស្រួចស្រាវ និងរ៉ាំរ៉ៃ និងបង្កើនការបំពេញមុខងារ ក៏ដូចជាសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត។ ការផ្តល់បច្ចេកវិទ្យាជំនួយសមស្រប អាចរួមចំណែកជួយកាត់បន្ថយឧបសគ្គរារាំងបរិយាបន្នប្រកបដោយប្រសិទ្ធភាពក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅប្រចាំថ្ងៃ។ ខណៈដែលសេវាស្តារលទ្ធភាពពលកម្ម ត្រូវបានផ្តល់ជូនក្នុងកម្រិតផ្សេងៗគ្នានៅក្នុងមន្ទីរពេទ្យ សេវាសម្រាប់ជនមានពិការភាពក៏ត្រូវបានផ្តល់ជូនផងដែរនៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា (PRC)។

ចំណុចផ្តោតសំខាន់មួយក្នុងចរន្តការងារស្តារលទ្ធភាពពលកម្មនៃកម្មវិធី ACCESS 2 គឺការគាំទ្រក្រសួងសុខាភិបាលក្នុងការពង្រឹងការស្តារលទ្ធភាពពលកម្មក្នុងប្រព័ន្ធសុខាភិបាល។ សម្រាប់ជាផ្នែកមួយនៃកម្មវិធីនេះ ឯកសារ "*ការពង្រឹងការស្តារលទ្ធភាពពលកម្មនៅកម្ពុជា៖ អាទិភាព និងឱកាស* ត្រូវបានបង្កើតឡើងជាធនធានមួយសម្រាប់រួមចំណែកដល់ការងាររបស់ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការពង្រឹងសេវាស្តារលទ្ធភាពពលកម្ម។ ធនធាននេះបានបង្កើតចក្ខុវិស័យសម្រាប់ពង្រឹងការរួមបញ្ចូលសេវាស្តារលទ្ធភាពពលកម្មទៅក្នុងការគ្របដណ្តប់សុខភាពជាសកល និងការថែទាំសុខភាពបឋម ហើយក្នុងពេលជាមួយគ្នានោះ បង្កើនសុខុមាលភាពជារួមរបស់ប្រជាពលរដ្ឋកម្ពុជាដែលមានបញ្ហាសុខភាព ឬមានរបួស និងជំងឺ រួមទាំងជនមានពិការភាព តាមរយៈលទ្ធភាពទទួលបានឱកាសបរិយាបន្នសង្គម និងសេដ្ឋកិច្ច។ ចំណុចផ្តោតសំខាន់របស់កម្មវិធី ACCESS 2 បន្ស៊ីគ្នានឹង *គំនិតផ្តួចផ្តើមស្តារលទ្ធភាពពលកម្ម ឆ្នាំ ២០៣០* របស់អង្គការសុខភាពពិភពលោក (WHO) និងច្បាមយកទិន្នន័យស្តីពីប្រជាជនដែលទើបតែមានកម្សោយ[46]។

ដើម្បីលើកកម្ពស់សុខភាព និងសុខុមាលភាពរបស់ជនមានពិការភាព ចាំបាច់ត្រូវពិចារណាលើ ៤ ចំណុច គឺការបង្កលក្ខណៈងាយស្រួល ភាពអាចរកបាន ភាពអាចទទួលយកបាន និងគុណភាពល្អ[47]។

---

[44] សម្រាប់ព័ត៌មានបន្ថែម សូមមើលផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ ២០២៤-២០៣៥ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម ខែ មេសា ឆ្នាំ ២០២៤ [តទៅនេះហៅថា ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល]។

[45] សម្រាប់ព័ត៌មានបន្ថែម សូមមើល ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល។

[46] សម្រាប់ព័ត៌មានបន្ថែម សូមមើល World Health Organization, *Rehabilitation 2030 Initiative*។ សូមមើលផងដែរ Strengthening Rehabilitation in Cambodia: priorities and opportunities, ACCESS 2 program, May 2024។

[47] Towards Universal Health Coverage, the role of disability inclusive social protection – a review, Background Paper #4, United Nations

| | |
|---|---|
| ការបង្កលក្ខណៈងាយស្រួល | មូលដ្ឋានសុខាភិបាល សម្ភារៈ និងសេវានានា ត្រូវតែបង្កលក្ខណៈងាយស្រួលផ្នែករូបវន្ត និងហិរញ្ញវត្ថុ និងគ្មានការរើសអើង។ ក្រៅពីនេះ ការបង្កលក្ខណៈងាយស្រួលមានន័យថាជាសិទ្ធិក្នុងការស្វែងរក ទទួលបាន និងចែកចាយព័ត៌មានដែលពាក់ព័ន្ធនឹងសុខភាពក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួលសម្រាប់ទាំងអស់គ្នា រួមទាំងជនមានពិការភាព ប៉ុន្តែមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការរក្សាទិន្នន័យសុខភាពផ្ទាល់ខ្លួនជាការសម្ងាត់។ |
| ភាពអាចរកបាន | មូលដ្ឋានសុខាភិបាល និងថែទាំសុខភាពសាធារណៈដែលកំពុងដំណើរការ សម្ភារៈ និងសេវានានា ត្រូវតែមានផ្តល់ក្នុងបរិមាណគ្រប់គ្រាន់  និងទាន់ពេលវេលា នៅក្នុងប្រទេសមួយ។ |
| ភាពអាចទទួលយកបាន | មូលដ្ឋានសុខាភិបាល សម្ភារៈ និងសេវានានា គួរតែអាចទទួលយកបានក្នុងផ្នែកវេជ្ជសាស្ត្រ និងវប្បធម៌។ |
| គុណភាពល្អ | មូលដ្ឋានសុខាភិបាល សម្ភារៈ និងសេវានានា ត្រូវតែមានភាពសមស្របផ្នែកវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ និងមានគុណភាពល្អ។ នេះទាមទារអ្នកជំនាញសុខាភិបាលដែលមានការបណ្តុះបណ្តាល ឱសថ និងបរិក្ខារមន្ទីរពេទ្យដែលមាន ការទទួលស្គាល់ផ្នែកវិទ្យាសាស្ត្រ និងមិនផុតកាលបរិច្ឆេទប្រើប្រាស់ ក៏ដូចជាបរិក្ខារអនាម័យគ្រប់គ្រាន់ និងទឹកពិសាដែលមានសុវត្ថិភាព។ល។ |

### *ឯកសារណែនាំដើម្បីពង្រឹងបរិយាបន្នពិការភាព*

អង្គការសុខភាពពិភពលោក បានបង្កើតឧបករណ៍មួយចំនួនដើម្បីពង្រឹងបរិយាបន្នពិការភាពក្នុងសេវាសុខាភិបាល និងផ្តល់ការណែនាំថាតើមូលដ្ឋានសុខាភិបាលអាចដោះស្រាយឧបសគ្គរូបវន្ត ឧបសគ្គឥរិយាបថ ឧបសគ្គព័ត៌មាន និងឧបសគ្គផ្សេងទៀតក្នុងការថែទាំសុខភាពដែលជាបញ្ហាប្រឈមរបស់ជនមានពិការភាពដោយរបៀបណា។ ឧបករណ៍ទាំងនោះមានដូចជា៖

- ***កញ្ចប់ឧបករណ៍សេវាសុខភាពដែលមានបរិយាបន្នពិការភាព*** គឺជាធនធានសម្រាប់មូលដ្ឋានសុខាភិបាលដើម្បីគាំទ្រសិទ្ធិរបស់ជនមានពិការភាព ក្នុងការទទួលបានសេវាសុខភាពដូចជនគ្មានពិការភាពដែរ។ កញ្ចប់ឧបករណ៍នេះផ្តល់ការណែនាំជាក់ស្តែងដល់អ្នកគ្រប់គ្រង  និងបុគ្គលិកមូលដ្ឋានសុខាភិបាល និងសេវាថែទាំសុខភាព អ្នកបង្កើតគោលនយោបាយសុខាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ស្តីពីការកំណត់រក និងដោះស្រាយឧបសគ្គរាំងដល់ការទទួលបានព័ត៌មាន និងសេវាសុខភាព។ កញ្ចប់ឧបករណ៍នេះមានផ្តល់ការពិត និងតួលេខសំខាន់ៗស្តីពីពិការភាព ការណែនាំជាក់ស្តែង និងឧទាហរណ៍នៃការអនុវត្តល្អសម្រាប់ដោះស្រាយឧបសគ្គផ្សេងៗដែលរាំងបរិយាបន្ន ក៏ដូចជាបញ្ជីត្រួតពិនិត្យដើម្បីវាយតម្លៃកម្រិតបរិយាបន្នពិការភាពនៃមូលដ្ឋានសុខាភិបាល។ កញ្ចប់ឧបករណ៍នេះគាំទ្រការសម្រេចបានការគ្របដណ្តប់សុខភាពជាសកល  តាមរយៈការធានាថា ប្រជាពលរដ្ឋគ្រប់រូបអាចទទួលបានព័ត៌មានសុខភាព និងអាចទទួលបានអត្ថប្រយោជន៍ស្មើគ្នាពីសេវាសុខភាព[48]។
- ***កញ្ចប់ការបណ្តុះបណ្តាលសេវាសុខភាពដែលមានបរិយាបន្នពិការភាព*** គឺជាឯកសារអមភ្ជាប់នឹងកញ្ចប់ឧបករណ៍ខាងលើ។ ឯកសារនេះអាចត្រូវបានប្រើប្រាស់ជាវគ្គសិក្សាដោយខ្លួនឯងដោយបុគ្គលិកថែទាំសុខភាពម្នាក់ៗ ឬដោយក្រុមបុគ្គលិកថែទាំសុខភាពនៅក្នុងក្រុមសិក្សា។ គោលបំណងនៃកញ្ចប់ការបណ្តុះបណ្តាលនេះគឺ

Partnership on the Rights of Persons with Disabilities (UNPRPD), January 2023, 6

[48] *Disability-Inclusive Health Services Toolkit: A Resource for Health Facilities in the Western Pacific Region*, WHO Regional Office for the Western Pacific, Manila, Philippines, 2020

គាំទ្រការសម្រេចបានការគ្របដណ្តប់សុខភាពជាសកល ដោយអ្នកផ្តល់សេវាថែទាំសុខភាព តាមរយៈការធានាលទ្ធភាពទទួលបានព័ត៌មាន និងសេវាសុខភាព លទ្ធផលដែលមានគុណភាពល្អបំផុត និងការលើកកម្ពស់គុណភាពជីវិតសម្រាប់ជនមានពិការភាពទាំងអស់។ ឯកសារនេះត្រូវបានបង្កើតឡើងដោយផ្អែកលើការអនុវត្តល្អបំផុតក្នុងផ្នែកបរិយាបន្នពិការភាពនាពេលបច្ចុប្បន្ន[49]។

- ***សមធម៌សុខភាពសម្រាប់ជនមានពិការភាព៖ គោលការណ៍ណែនាំសម្រាប់សកម្មភាព*** គឺជាឧបករណ៍ផែនការយុទ្ធសាស្ត្រដើម្បីគាំទ្រក្រសួងសុខាភិបាលក្នុងការរៀបចំផែនការសកម្មភាពសមស្របដើម្បីពង្រឹងបរិយាបន្នពិការភាពក្នុងវិស័យសុខាភិបាល និងដើម្បីបំពេញការប្តេជ្ញាចិត្តចំពោះស្តង់ដារសុខភាពខ្ពស់បំផុតដែលអាចសម្រេចបានសម្រាប់មនុស្សគ្រប់រូប ដូចការគូសបញ្ជាក់ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD)។ គោលការណ៍ណែនាំនេះគូសបញ្ជាក់អំពីវដ្តនៃដំណាក់កាល ៤ ដែលត្រួតគ្នា និងបន្តជាប់ ដែលអាចយកទៅអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ៖
    - ដំណាក់កាលទី ១ - ***ត្រៀមរៀបចំ*** ៖ បញ្ជាក់ពីតួនាទី ការទទួលខុសត្រូវ និងធនធាន រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីធ្វើបទបង្ហាញដល់អ្នកពាក់ព័ន្ធ បង្កើតក្រុមការងារមគ្គុទេសក៍សម្រាប់សកម្មភាពជនមានពិការភាព។
    - ដំណាក់កាលទី ២ - ***សិក្សាវាយតម្លៃ*** ៖ ប្រមូលទិន្នន័យ និងព័ត៌មាន វាយតម្លៃស្ថានភាពនៃបរិយាបន្នពិការភាព ក្នុងវិស័យសុខាភិបាល កត់ត្រាទុក និងផ្ទៀងផ្ទាត់លទ្ធផលរកឃើញ។
    - ដំណាក់កាលទី ៣ - ***រៀបចំ*** ៖ ផ្តោតអាទិភាពលើចំណុចចាប់ផ្តើម និងសកម្មភាព អមជាមួយនឹងការគណនា ថ្លៃចំណាយ បង្កើតក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ផ្ទៀងផ្ទាត់ សម្រេចបញ្ចប់ និងអនុម័តផែនការ។
    - ដំណាក់កាលទី ៤ - ***ការអនុវត្ត*** ៖ អនុវត្តផែនការសកម្មភាព សម្របសម្រួលអន្តរវិស័យ និងការរៀនសូត្ររួមគ្នា វិភាគ និងវាយការណ៍អំពីលទ្ធផលដើម្បីរួមចំណែកដល់ការរៀបចំផែនការយុទ្ធសាស្ត្រនាពេលអនាគត[50]។




គោលការណ៍ណែនាំនេះត្រូវបញ្ចប់នៅឆ្នាំ ២០២៤។

- ***កម្រងឯកសារអន្តរាគមន៍សម្រាប់ការស្តារលទ្ធភាពពលកម្ម*** គូសបញ្ជាក់អំពីអន្តរាគមន៍ស្តារលទ្ធភាពពលកម្មសំខាន់ៗបំផុតសម្រាប់ស្ថានភាពសុខភាពចំនួន ២០ ដែលមានប្រេវ៉ាឡង់ខ្ពស់ និងកម្រិតខ្ពស់នៃពិការភាពដែលពាក់ព័ន្ធ។ ឯកសារនេះក៏រួមបញ្ចូលព័ត៌មានអំពីតម្រូវការកម្លាំងពលកម្ម និងផលិតផលជំនួយ បរិក្ខារ និងសម្ភារៈប្រើប្រាស់ដែលត្រូវការចាំបាច់ដើម្បីផ្តល់អន្តរាគមន៍ទាំងនេះ។ ឯកសារនេះមានម៉ូឌុលចំនួន ៨ និងបង្ហាញពីធនធានសំខាន់ៗនៅពេលធ្វើផែនការ និងរៀបចំថវិកាសម្រាប់ការរួមបញ្ចូលសេវាស្តារលទ្ធភាពពលកម្មទៅក្នុងប្រព័ន្ធសុខាភិបាល[51]។

- ***កម្រងឯកសារមូលដ្ឋាននៃអន្តរាគមន៍សម្រាប់ការស្តារលទ្ធភាពពលកម្ម ៖ កញ្ចប់ឧបករណ៍សម្រាប់អ្នកជំនាញថែទាំសុខភាពបឋម*** មានកម្រងអន្តរាគមន៍រួមជាមួយនឹងធនធានគ្លីនិក សម្ភារៈបណ្តុះបណ្តាល

[49] *Disability-Inclusive Health Services Training Package: A Companion to the Disability-Inclusive Health Services Toolkit*, WHO Regional Office for the Western Pacific, Manila, Philippines, 2022

[50] Health equity for persons with disabilities: a guide for action, WHO Information sheet, 26 January 2024.

[51] *Package of interventions for rehabilitation*, WHO

និងគោលការណ៍ណែនាំការអនុវត្ត។ ឯកសារនេះគូសបញ្ជាក់អំពីសំណុំអន្តរាគមន៍អាទិភាពមួយចំនួនសម្រាប់ការស្តារលទ្ធភាព ពលកម្មដែលអាចផ្តល់ជូនក្នុងការថែទាំសុខភាពបឋម។ ឯកសារនេះមានផ្តល់ព័ត៌មានស្តីពីអន្តរាគមន៍ដែលមានតម្លៃទាប ផលជះខ្ពស់ និងផ្អែកលើភស្តុតាងសម្រាប់ការស្តារលទ្ធភាពពលកម្មដែលអាចផ្តល់ជូនយ៉ាងងាយស្រួល ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពដោយកម្លាំងសុខាភិបាលដែលមានស្រាប់នៅក្នុងមូលដ្ឋាន ថែទាំសុខភាពបឋម។ ការផ្តល់សំណុំអន្តរាគមន៍អាទិភាពមួយចំនួនសម្រាប់ការស្តារលទ្ធភាពពលកម្ម ដែលអាចផ្តល់ជូនដោយកម្លាំងថែទាំសុខភាពបឋមដែលមានស្រាប់ អាចគាំទ្រដល់គោលដៅនៃការគ្របដណ្តប់សុខភាពជាសកល។ សំណុំអន្តរាគមន៍នេះនឹងត្រូវចេញផ្សាយដោយអង្គការសុខភាពពិភពលោកនៅឆ្នាំ ២០២៥[52]។

ឯកសារណែនាំផ្សេងទៀតដែលពាក់ព័ន្ធនឹងសុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព រួមមាន៖

- ***ស្ត្រី និងជនមានពិការភាពវ័យក្មេង៖ គោលការណ៍ណែនាំសម្រាប់ការផ្តល់សេវាផ្អែកលើសិទ្ធិ និងឆ្លើយតបនឹងយេនឌ័រដើម្បីដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសិទ្ធិ និងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ*** ផ្តល់ការណែនាំជាក់ស្តែង និងជាក់លាក់អំពីការផ្តល់សេវាដែលមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួលដែលពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសិទ្ធិ និងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ (SRHR) សម្រាប់ស្ត្រី និងជនមានពិការភាពវ័យក្មេង។ គោលការណ៍ណែនាំសម្រាប់សកម្មភាព ជាពិសេសទាក់ទងនឹងសិទ្ធិ និងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ផ្អែកលើការពិចារណា ៤ ចំណុច គឺ ការបង្កលក្ខណៈងាយស្រួល ភាពអាចរកបាន ភាពអាចទទួលយកបាន និងគុណភាពល្អ។ ខណៈដែលក្រុមគោលដៅចម្បងគឺអ្នកផ្តល់សេវាដែលពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសិទ្ធិ និងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ គោលការណ៍ណែនាំនេះគឺជាធនធានដ៏មានតម្លៃសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ រួមទាំងអ្នកពាក់ព័ន្ធក្នុងរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធក្នុងការរចនា ការអភិវឌ្ឍ ការអនុវត្ត ឬការតស៊ូមតិឱ្យមានការផ្តល់សេវាសម្រាប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬសិទ្ធិ និងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសម្រាប់ស្ត្រី និងជនមានពិការភាពវ័យក្មេង[53]។

## ៣.៣ ការអប់រំ និងបំណិនជីវិត

### *ទិដ្ឋភាពទូទៅ*

សិទ្ធិរបស់មនុស្សពេញវ័យ យុវជន និងកុមារដែលមានពិការភាព ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត ព្រមទាំងលទ្ធភាពស្មើគ្នាក្នុងការទទួលបានឱកាសសិក្សាពេញមួយជីវិត ត្រូវបានកំណត់ក្រោមក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយដែលមានស្រាប់។ គោលដៅទី ៤ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) មានគោលបំណងធានាការអប់រំដែលមានគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ទោះយ៉ាងណា សម្រាប់ សិស្សមានពិការភាព លទ្ធភាពចូលរៀន និងលទ្ធភាពបន្តការសិក្សាគឺទាបជាងសិស្សគ្មានពិការភាព។




បំណិនជីវិតសំដៅលើសកម្មភាពរៀនសូត្រ ប្រកបដោយគោលបំណងទាំងអស់ ដែលត្រូវបានអនុវត្តជាប្រចាំពេញមួយ

[52] សម្រាប់ព័ត៌មានបន្ថែម សូមមើល *Basic Package of Interventions for Rehabilitation: A Toolkit for Primary Care Professionals*, Information Sheet, WHO, 22 August 2024។

[53] *Women and Young Persons with Disabilities: Guidelines for Providing Rights-Based and Gender-Responsive Services to Address Gender-Based Violence and Sexual and Reproductive Health and Rights*, UNFPA, November 2018

ជីវិតរបស់មនុស្សម្នាក់ៗ ដើម្បីបង្កើនចំណេះដឹង ជំនាញ និងសមត្ថភាព។ ឱកាសរៀនសូត្រ ពេញមួយជីវិត គួររួមបញ្ចូលលទ្ធភាពទទួលបានបំណិនជីវិត និងជំនាញអភិវឌ្ឍន៍សង្គមដែលនឹងអាចឱ្យប្រជាជនដែលមានពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យ ចូលរួមក្នុងសកម្មភាព សហគមន៍យ៉ាងពេញលេញ និងស្មើភាពគ្នា និងកាត់បន្ថយការផាត់ចេញពីសង្គម។ ឱកាសទាំងនេះអាចរួមបញ្ចូលការបណ្តុះបណ្តាលអក្ខរកម្ម និងលេខនព្វន្ត ឬការបណ្តុះបណ្តាលភាសាសញ្ញាសម្រាប់អ្នកដែលមានកម្សោយការស្តាប់ និងសមាជិកគ្រួសារ និងសមាជិកសហគមន៍របស់ពួកគេដើម្បីសម្រួលដល់ការប្រាស្រ័យទាក់ទង[54]។

ឧបសគ្គរារាំងលទ្ធភាពទទួលបាន ជាពិសេសនៅតំបន់ជនបទ រួមមានឥរិយាបថបង្កប់ផ្នត់គំនិតអវិជ្ជមាន ភាពមានកម្រិតនៃការបណ្តុះបណ្តាលមុនពេលចុះបង្រៀន ដែលធ្វើឱ្យគ្រូមិនអាចបង្រៀនសិស្សមានពិការភាពប្រកបដោយប្រសិទ្ធភាព វិធីសាស្ត្របង្រៀន និងសម្ភារៈឧបទេសមិនសូវសមស្រប ចំនួនសិស្សច្រើនក្នុងមួយថ្នាក់ (ជាធម្មតាប្រហែល ៥០ នាក់) ដែលនាំឱ្យគ្រូមិនសូវមានពេលផ្តល់ការគាំទ្របន្ថែមនៅពេលចាំបាច់ ថ្នាក់រៀន និងបង្គន់អនាម័យមិនបង្កលក្ខណៈងាយស្រួលផ្នែករូបវន្ត សាលារៀនច្រើនតែនៅឆ្ងាយពីផ្ទះរបស់សិស្ស និងគ្មានមធ្យោបាយធ្វើដំណើរ ពេលខ្លះ ឪពុកម្តាយមិនសូវចង់បញ្ជូនកូនមានពិការភាពទៅរៀន ឬបន្តឱ្យពួកគេបានសិក្សារៀនសូត្រ ដោយសារពួកគាត់អាចមិនយល់ពីតម្លៃនៃការអប់រំ ឬសមត្ថភាពរបស់កូនក្នុងការទទួលបានការអប់រំ ជាញឹកញាប់ ឪពុកម្តាយ និងអ្នកថែទាំកុមារដែលមានពិការកម្រិតធ្ងន់ធ្ងរមានអារម្មណ៍អស់សង្ឃឹមចំពោះឱកាសការងារនាពេលអនាគតរបស់កូន ឬសមត្ថភាពរបស់ពួកគេក្នុងការធ្វើការសម្រេចចិត្តដោយឯករាជ្យ ភាពមានកម្រិតនៃធនធានហិរញ្ញវត្ថុសម្រាប់ឱ្យកូនបន្តការសិក្សា និងឱកាសមានកម្រិតសម្រាប់ការរៀនសូត្រពេញមួយជីវិត។

ជំងឺរាតត្បាតកូវីដ-១៩ បានបង្កផលជះយ៉ាងខ្លាំងលើចំនួនសិស្សមានពិការភាពដែលចូលរួមក្នុងឱកាសអប់រំ រួមទាំងការសិក្សាតាមអនឡាញ។

ក្រសួងអប់រំ យុវជន និងកីឡា (អ.យ.ក) មានអាណត្តិក្នុងការផ្តល់ឱកាសសម្រាប់ការអប់រំ និងការរៀនសូត្រពេញមួយជីវិតដល់ប្រជាជន។ ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ និងដៃគូផ្សេងទៀត អ.យ.ក សម្រេចបានវឌ្ឍនភាពប្រកបដោយអត្ថន័យក្នុងការបង្កើនលទ្ធភាពទទួលបានការអប់រំសម្រាប់សិស្សមានពិការភាព តាមរយៈការផ្តល់ឱកាសសម្រាប់ការអប់រំបរិយាបន្ន ការអប់រំចម្រុះ ការអប់រំពិសេស និងការគាំទ្រឱ្យពួកគេបានបន្តការសិក្សារៀនសូត្រ។

ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) របស់ អ.យ.ក មានទិន្នន័យស្តីពីសិស្សមានពិការភាពដែលទទួលបានការអប់រំគ្រប់ប្រភេទ និងគ្រប់កម្រិត។

ដើម្បីលើកកម្ពស់បរិយាបន្ន អ.យ.ក បានបង្កើតស្ថាប័នទទួលខុសត្រូវលើការអប់រំពិសេស និងការអប់រំបរិយាបន្ន ដូចជា នាយកដ្ឋានអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស (NISE) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៧ ដើម្បីបង្កើនជំនាញគ្រូបង្រៀនក្នុងការអប់រំបរិយាបន្ន។ ទោះយ៉ាងណា យោងតាមអង្គការយូនីសេហ្វ ជាង ៥៧ ភាគរយនៃកុមារមានពិការភាពនៅកម្ពុជាគ្មានលទ្ធភាពទទួលបានការអប់រំ ធៀបនឹង ៧ ភាគរយនៃកុមារគ្មានពិការភាព[55]។

*ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ២០២៤-២០២៨* របស់ អ.យ.ក មានគោលបំណងធានាថា កុមារគ្រប់រូប រួមទាំងកុមារមានពិការភាព អាចទទួលបានការអប់រំប្រកបដោយគុណភាពដើម្បីលើកកម្ពស់សង្គមមួយដែលកាន់តែមានបរិយាបន្ន និងសមធម៌។ ផែនការនេះមានគោលបំណងសម្រេចបានគោលដៅសំខាន់ចំនួន ៣៖ ការផ្លាស់ប្តូរឥរិយាបថសង្គមដើម្បីលើកកម្ពស់បរិយាបន្ន និងទប់ស្កាត់ការមាក់ងាយ និងការរើសអើង ផ្តល់ឧបករណ៍ និងការគាំទ្រចាំបាច់ដោយធានាលទ្ធភាពទទួលបានបច្ចេកវិទ្យា និងសេវាជំនួយ និងកិច្ចសហការរវាងផ្នែកផ្សេងៗនៃរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើតបរិយាកាសដែលគ្រប់ជ្រុងជ្រោយ មានបរិយាបន្ន និងផ្តល់ការគាំទ្រដល់កុមារមានពិការភាព។

---

54 សម្រាប់ព័ត៌មានបន្ថែមស្តីពីការរៀនសូត្រពេញមួយជីវិត សូមមើល *What you need to know on lifelong learning*, UNESCO, 30 August 2024។

55 *Inclusive Education in Cambodia: Successes and Challenges*, UNICEF, 12 March 2024

លើសពីនេះ *ផែនទីបង្ហាញផ្លូវស្ដីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ២០២៣-២០៣៥* របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រួមបញ្ចូលការផ្ដល់ឱកាសរៀនសូត្រពេញមួយជីវិតដើម្បីធានាថា ប្រជាពលរដ្ឋគ្រប់រូបមានជំនាញវិជ្ជាជីវៈយ៉ាងតិចមួយ។ ផ្នែកសំខាន់ៗនៃផែនទីបង្ហាញផ្លូវរួមមានការលើកកម្ពស់ការអប់រំបរិយាបន្ន និងការធានាថា ជនមានពិការភាពមានលទ្ធភាពទទួលបានឱកាស[56]។

គោលនយោបាយពាក់ព័ន្ធផ្សេងទៀតរបស់ អ.យ.ក រួមមាន *គោលនយោបាយស្ដីពីការអប់រំបរិយាបន្នឆ្នាំ ២០១៨ គោលនយោបាយជាតិស្ដីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច* និង *ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ ២០៣០*។ លើសពីនេះ *ផែនការសកម្មភាពគោលនយោបាយស្ដីពីគ្រូបង្រៀន ២០២៤-២០៣០* របស់ អ.រ.យ.ក រួមបញ្ចូលសកម្មភាពដើម្បីដាក់បញ្ចូលការអប់រំបរិយាបន្នក្នុងកម្មវិធីសិក្សាសម្រាប់ការបណ្ដុះបណ្ដាលគ្រូបង្រៀន និងបង្កើនជំនាញគ្រូបង្រៀនក្នុងការបង្រៀនសិស្សដែលមានប្រភេទពិការភាពផ្សេងៗ។

អ.យ.ក ដំណើរការវិទ្យាល័យអប់រំពិសេសចំនួន ៦។ ក្នុងនោះ វិទ្យាល័យចំនួន ៥ (នៅវិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី និងនៅច្បារអំពៅ ខេត្តកំពង់ចាម សៀមរាប និងបាត់ដំបង) ផ្ដោតលើសិស្សដែលគថ្លង់ ឬពិការភ្នែក ខណៈដែលវិទ្យាល័យអប់រំពិសេសតាខ្មៅ មានឯកទេសក្នុងការគាំទ្រសិស្សដែលមានជំងឺអូទីស្សឹម និងពិការភាពសតិបញ្ញា។ យោងតាមទិន្នន័យ EMIS របស់ អ.យ.ក សម្រាប់ឆ្នាំ ២០២៤ ចនួនសិស្សនៅតាមសាលាអប់រំពិសេសបែងចែកតាមប្រភេទពិការភាព បង្ហាញថាមានសិស្ស ១៩៩ នាក់មានកម្សោយគំហើញ សិស្ស ១៨៤ នាក់មានពិការភាពសតិបញ្ញា និងសិស្ស ៦៣៥ នាក់មានកម្សោយការស្ដាប់[57]។

វេទិកាថ្នាក់ជាតិប្រចាំឆ្នាំស្ដីពីការអប់រំបរិយាបន្ន កៀរគរ អ.យ.ក អង្គការមិនមែនរដ្ឋាភិបាល អង្គការយូនីសេហ្វ និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលធ្វើការងារក្នុងវិស័យនេះ ឱ្យមករៀនសូត្រពីអ្នកជំនាញ និងចែករំលែកបទពិសោធន៍។

## *ឯកសារណែនាំដើម្បីពង្រឹងបរិយាបន្នពិការភាព*

ខាងក្រោមនេះជាឯកសារណែនាំដើម្បីពង្រឹងបរិយាបន្នក្នុងការអប់រំ និងការរៀនសូត្រពេញមួយជីវិត៖

- ***គោលការណ៍ណែនាំសម្រាប់ការធានាបរិយាបន្ន និងសមធម៌ក្នុងការអប់រំ*** មានគោលបំណងជួយដល់ប្រទេសនានាក្នុងការដាក់បញ្ចូលបរិយាបន្ន និងសមធម៌ទៅក្នុងគោលនយោបាយអប់រំ។ គោលបំណងចុងក្រោយគឺបង្កើតឱ្យមានការផ្លាស់ប្ដូរទូទាំងប្រព័ន្ធ ដើម្បីជម្នះឧបសគ្គរាំងលទ្ធភាពទទួលបានការអប់រំប្រកបដោយ



[56] សម្រាប់ព័ត៌មានបន្ថែម សូមមើល *Cambodia Skills Development Roadmap 2023-2035*

[57] *Inclusive Education in Cambodia: Successes and Challenges*, UNICEF, 12 March 2024

[58] *A guide for ensuring inclusion and equity in education*, Education 2030, UNESCO, 2017

- ***ការផ្លាស់ប្តូរការយល់ឃើញ - ការផ្តល់ភាពអង់អាចដល់គ្រូបង្រៀន៖ ទំនាក់ទំនងអន្តរបុគ្គល និងការចូលរួមរបស់សហគមន៍ដើម្បីគាំទ្រដល់ការអប់រំបរិយាបន្ន*** គឺជាកញ្ចប់ការបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀន និងអ្នកអប់រំ។ ឯកសារនេះដោះស្រាយប្រសិទ្ធភាពផ្ទាល់ខ្លួនរបស់បុគ្គលិកបង្រៀន ឥរិយាបថ ជំនឿ និងបទដ្ឋាននានា និងខិតខំលើកកម្ពស់ និងគាំទ្របរិយាបន្នកុមារគ្រប់រូប ដោយមិនគិតពីសាវតារសង្គម សាសនា វប្បធម៌ សេដ្ឋកិច្ច ភូមិសាស្ត្រ ជាតិពន្ធ និងពិការភាពរបស់ពួកគេ។ ការបណ្តុះបណ្តាលនឹងជួយឱ្យគ្រូបង្រៀនអភិវឌ្ឍសមត្ថភាព ជំនាញ និងទំនុកចិត្ត ដើម្បីក្លាយខ្លួនជាអ្នកអប់រំប្រកបដោយសមត្ថភាពផ្នែកវប្បធម៌ដែលប្រើប្រាស់ការអនុវត្តបែបបរិយាបន្ន សហការជាមួយសហគមន៍ចម្រុះរបស់ពួកគេ និងដើរតួនាទីជាអ្នកតស៊ូមតិឱ្យមានបរិយាបន្ននៅក្នុងសហគមន៍អប់រំ និងសង្គមរបស់ពួកគេ[59]។
- ***ការអប់រំបរិយាបន្ន - ការរួមបញ្ចូលកុមារមានពិការភាពក្នុងការរៀនសូត្រប្រកបដោយគុណភាព៖ តើត្រូវធ្វើអ្វីខ្លះ?*** ផ្តល់ការណែនាំស្តីពីអ្វីដែលរដ្ឋាភិបាលអាចធ្វើបាន ដើម្បីបង្កើតប្រព័ន្ធអប់រំបរិយាបន្ន[60]។
- ***ការធ្វើឱ្យការរៀនសូត្រពេញមួយជីវិតក្លាយជាការពិត៖ សៀវភៅណែនាំ*** មានគោលបំណងកសាងសមត្ថភាពក្នុងការអភិវឌ្ឍគោលនយោបាយស្តីពីការរៀនសូត្រពេញមួយជីវិត យុទ្ធសាស្ត្រ និងផែនការអនុវត្តន៍នៅក្នុងបរិបទថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ឯកសារនេះផ្តល់ភស្តុតាងពីគំនិតផ្តួចផ្តើមផ្សេងៗ និងពណ៌នាអំពីបញ្ហាសហសម័យមួយចំនួនដែលឆ្លើយតបដោយការរៀនសូត្រពេញមួយជីវិត រួមទាំងរបៀបដែលការរៀនសូត្រពេញមួយជីវិតជះឥទ្ធិពលលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព[61]។

## ៣.៤ កិច្ចគាំពារសង្គម និងកម្រិតជីវភាពសមរម្យ

### *ទិដ្ឋភាពទូទៅ*

ជនមានពិការភាព មានចំនួនច្រើនក្នុងចំណោមប្រជាជនក្រីក្របំផុតនៅកម្ពុជា។ នៅឆ្នាំ ២០២១ អត្រាភាពក្រីក្រថ្នាក់ជាតិសម្រាប់ជនគ្មានពិការភាពគឺ ១៧,៥ ភាគរយ ធៀបនឹងអត្រា ២១,១ ភាគរយក្នុងចំណោមជនមានពិការភាព[62]។ លើសពីនេះ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ២០១៩-២០ រកឃើញថា ជនមានពិការភាពចំនួន ២៦ ស្ថិតក្នុងបញ្ចភាគប្រជាជនក្រីក្របំផុត[63]។

សិទ្ធិរបស់ជនមានពិការភាពក្នុងការទទួលបានកិច្ចគាំពារសង្គម និងកម្រិតជីវភាពសមរម្យ ត្រូវបានការពារក្រោម *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១* និង *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ២០២៣-២០២៨*។ *យុទ្ធសាស្ត្របញ្ចកោណ* និងកម្មវិធីនយោបាយនេះ ផ្តល់ផែនទីបង្ហាញផ្លូវដើម្បីសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលក្នុងប្រែក្លាយកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០។ គោលបំណងមួយនៃ *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១* គឺ «ប្រជាជនកម្ពុជារស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុភមង្គល និងទទួលបានការគាំពារសង្គមប្រកបដោយសមធម៌ ស្មើសិទ្ធិ ស្មើឱកាស»។ *កម្មវិធីនយោបាយ* រួមបញ្ចូលបទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍប្រព័ន្ធកិច្ចគាំពារសង្គម[64]។

ទោះយ៉ាងណា ជនមានពិការភាពជាច្រើនប្រឈមនឹងឧបសគ្គរាំងលទ្ធភាពស្មើភាពក្នុងការទទួលបានប្រព័ន្ធគាំពារសង្គម និងកម្រិតជីវភាពសមរម្យ។ ឧបសគ្គទាំងនេះរួមមាន៖ ការមាក់ងាយ និងឥរិយាបថអវិជ្ជមានចំពោះជនមានពិការភាព កង្វះការយល់ដឹងអំពីសិទ្ធិរបស់ជនមានពិការភាពក្នុងការទទួលបានសេវា និងឱកាសក្នុងចំណោម

---

[59] Changing Perceptions – Empowering teachers: Interpersonal communication and community engagement to support inclusive education, UNICEF Europe and Central Asia Region, January 2023

[60] Inclusive Education – Including children with disabilities in quality learning: what needs to be done? UNICEF, September 2017

[61] Making lifelong learning a reality: a handbook, Education 2030, UNESCO, 2022 [accessed 4 September 2024]

[62] Cambodia Demographic and Health Survey 2021-2022

[63] Final Report on Cambodia Socio-Economic Survey 2019-20, National Institute of Statistics, 2020

[64] Political Platform of the Royal Government of Cambodia of the Seventh Legislature of the National Assembly for Nation Building and Defense 2023-2028, 22-23

អ្នកអនុវត្តន៍កម្មវិធី និងអ្នកផ្តល់សេវា កង្វះព័ត៌មានក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួលស្តីពីសេវា និងឱកាសដែលមាន និងចំណេះដឹងមានកម្រិតក្នុងចំណោមជនមានពិការភាព និងអង្គការតំណាងជនមានពិការភាពស្តីពីរបៀបទទួលបានសិទ្ធិរបស់ពួកគេ។

ប្រព័ន្ធគាំពារសង្គមរបស់កម្ពុជា ផ្អែកតាម*ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥* (NSPPF)។ NSPPF ផ្តោតលើសសរស្តម្ភ ២ គឺ ជំនួយសង្គម និងសន្តិសុខសង្គម។ ក្របខណ្ឌនេះកំណត់និយមន័យជំនួយសង្គមថាជាជំនួយសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ រួមទាំងជនមានពិការភាព។ ក្របខណ្ឌនេះផ្តល់ការការពារដល់ប្រជាពលរដ្ឋដែលរស់នៅក្រោម ឬជិតបន្ទាត់នៃភាពក្រីក្រ[65]។ រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើសេចក្តីព្រាងកំណែថ្មីនៃ NSPPF ដើម្បីពង្រីកការគ្របដណ្តប់ប្រកបដោយប្រសិទ្ធភាពនៃកិច្ចគាំពារសង្គម រួមទាំងការឆ្ពោះទៅសម្រេចបានការគ្របដណ្តប់សុខភាពជាសកល។

ក្នុងការអភិវឌ្ឍដ៏សំខាន់មួយ កម្មវិធីកញ្ចប់គ្រួសារដែលត្រូវបានបង្កើតឡើងក្រោម NSPPF បានចាប់ផ្តើមនៅខែមេសា ឆ្នាំ ២០២៤។ កម្មវិធីកញ្ចប់គ្រួសារច្របាច់បញ្ចូលគ្នានូវកម្មវិធីជំនួយសង្គមដែលមានស្រាប់ជាច្រើន រួមទាំងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងអំឡុងវិបត្តិកូវីដ-១៩។ កម្មវិធីកញ្ចប់គ្រួសារគឺជាក្របខណ្ឌជំនួយសង្គមរួមបញ្ចូលគ្នា និងអចិន្ត្រៃយ៍ ដែលត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ រួមទាំងគ្រួសារមានសមាជិកជាមនុស្សពេញវ័យ និងកុមារដែលមានពិការភាព ក្នុងគោលបំណងមិនទុកនរណាម្នាក់ចោល។ នេះជាកញ្ចប់អត្ថប្រយោជន៍ រួមបញ្ចូលគ្នាដែលនឹងដោះស្រាយហានិភ័យយ៉ាងទូលំទូលាយពេញមួយវដ្តជីវិតសម្រាប់គ្រួសារ និងកុមារក្រីក្រ និងងាយរងគ្រោះ រួមទាំងតាមរយៈការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ។ ជនមានពិការភាពដែលមានលក្ខណៈសម្បត្តិ នឹងទទួលបានប្រាក់ឧបត្ថម្ភ ៨០.០០០ រៀលក្នុងមួយខែ (ប្រហែល ២០ ដុល្លារអាមេរិក)។ ប្រព័ន្ធបញ្ជូនបន្តដ៏រឹងមាំមួយ នឹងភ្ជាប់ជំនួយសាច់ប្រាក់ទៅនឹងសេវានានា ដូចជា ការថែទាំសុខភាព ការអប់រំ និងសេវាសង្គមផ្សេងទៀត[66]។

កម្មវិធីកញ្ចប់គ្រួសារកំពុងត្រូវបានអនុវត្តដោយមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ) នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[67]។ ម.ជ.ជ បានបង្កើតការិយាល័យនៅគ្រប់ខេត្តទាំងអស់ និងមានតួនាទីសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នពិការភាពក្នុងកម្មវិធីកញ្ចប់គ្រួសារ។

ដើម្បីមានសិទ្ធិទទួលបានកញ្ចប់គ្រួសារ គ្រួសារងាយរងគ្រោះត្រូវមានបណ្ណសមធម៌។ *កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ* (IDPoor) របស់ក្រសួងផែនការ គឺជាចំណុចស្នូលនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់សមធម៌ ដោយកម្មវិធីនេះមាននាទីកំណត់អត្តសញ្ញាណជនក្រីក្រសម្រាប់ជាក្រុមគោលដៅនៃកម្មវិធីសុខាភិបាល និងកម្មវិធីសង្គមកិច្ចក្នុងវិស័យជាច្រើន។ អត្តសញ្ញាណកម្មគ្រួសារក្រីក្រជាការធ្វើតេស្តមធ្យមភាគតំណាង ដែលដឹកនាំដោយសហគមន៍ ដែលត្រូវបានអនុវត្តដោយក្រុមការងារឃុំ/សង្កាត់ទៅតាមការស្នើសុំ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ និងគ្រួសារដែលមានបញ្ហាក្នុងការរក្សារបរចិញ្ចឹមជីវិតដោយសារកាលៈទេសៈពិសេស។ ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ មានកាតព្វកិច្ចប្រើប្រាស់ទិន្នន័យទាំងនេះសម្រាប់អន្តរាគមន៍កាត់បន្ថយភាពក្រីក្រចំគោលដៅ។ នៅឆ្នាំ ២០២២ ក្រសួងផែនការបានធ្វើបច្ចុប្បន្នភាពនីតិវិធីត្រួតពិនិត្យ និងលក្ខណៈវិនិច្ឆ័យការជ្រើសរើស ដែលរួមបញ្ចូលព័ត៌មានស្តីពីពិការភាព សម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ[68]។

អ្នកកាន់បណ្ណសម្គាល់ជនមានពិការភាព ត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទៅនឹងសេវាកិច្ចគាំពារសង្គមដែលផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព (DMIS)។

---

[65] សម្រាប់ព័ត៌មានបន្ថែម សូមមើល National Social Protection Policy Framework 2016-2025, approved by the Council of Minister, 24 March 2017

[66] សម្រាប់ព័ត៌មានបន្ថែម សូមមើល Guidelines for National Social Assistance Programme Framework for Family Package (available in Khmer only)។ សូមមើលផងដែរ *Developing the Family Package in Cambodia: The Realization of Integrated Social Protection*, UNICEF, 2023។

[67] សម្រាប់ព័ត៌មានបន្ថែម សូមមើលអនុក្រឹត្យស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ សូមមើលផងដែរសេចក្តីសង្ខេបខ្លី ដែលមានបង្ហាញក្នុងឧបសម្ព័ន្ធ ២ ស្តីពីអ្នកពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្រោមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

[68] សម្រាប់ព័ត៌មានបន្ថែមស្តីពីនីតិវិធីនេះ សូមមើល Part 4 on Pathways to enhanced disability inclusion at the subnational level ។ សូមមើលផងដែរ *Manual for the Identification of Poor Households Procedure*, MoP, 2022; and, https://idpoor.gov.kh/en/about/។

### *ឯកសារណែនាំដើម្បីពង្រឹងបរិយាបន្នពិការភាព*

ខាងក្រោមនេះជាឯកសារណែនាំដើម្បីពង្រឹងបរិយាបន្នពិការភាពក្នុងយន្តការគាំពារសង្គម ៖

- ***កញ្ចប់ឧបករណ៍គាំពារសង្គមតាមអនឡាញ*** (SPOT) របស់ UNESCAP គឺជាវេទិកាមួយដើម្បីគាំទ្រដល់អ្នកបង្កើត គោលនយោបាយក្នុងការកសាងប្រព័ន្ធគាំពារសង្គមបែបបរិយាបន្ន តាមរយៈការចែករំលែកការអនុវត្តល្អ ធនធាន និងការណែនាំស្តីពីកិច្ចគាំពារសង្គម។ SPOT ផ្តល់ឧបករណ៍សម្រាប់ជួយដល់ប្រទេសនានា និងអ្នកពាក់ព័ន្ធ លុបបំបាត់គម្លាតក្នុងការគ្របដណ្តប់កិច្ចគាំពារសង្គមតាមរយៈការគ្រាប់តាមរបៀបដែលកិច្ចគាំពារសង្គមលើកកម្ពស់ការប្រើប្រាស់ និងកាត់បន្ថយភាពក្រីក្រ និងវិសមភាព ការពង្រឹងជំនាញស្តីពីរបៀបអនុវត្ត និងគ្រប់គ្រងប្រព័ន្ធគាំពារសង្គមតាមរយៈការបណ្តុះបណ្តាលតាមអនឡាញដោយខ្លួនឯងចំនួន ៥ និងការ ស្វែងរកភស្តុតាងបញ្ជាក់ពីអ្វីដែលមានប្រសិទ្ធភាព និងអ្វីដែលប្រទេសនានាកំពុងធ្វើ[69]។
- ***របៀបរៀបចំកិច្ចគាំពារសង្គមដែលប្រកបដោយបរិយាបន្នពិការភាព*** ពន្យល់ពីមូលហេតុដែលកិច្ចគាំពារសង្គមសំខាន់ចំពោះជនមានពិការភាព និងបង្ហាញពីទស្សនទានគន្លឹះ និងគម្រោងដែលចាំបាច់សម្រាប់កិច្ចគាំពារសង្គមដែលប្រកបដោយបរិយាបន្នពិការភាព[70]។

ការណែនាំផ្សេងទៀតកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍ រួមទាំង៖ គោលការណ៍ណែនាំសម្រាប់កិច្ចគាំពារសង្គមបរិយាបន្នពិការភាពរបស់អង្គការ UNDP និងឆ្ពោះទៅរកប្រព័ន្ធកិច្ចគាំពារសង្គមបរិយាបន្នដែលអាចឱ្យមានការចូលរួម និងបរិយាបន្នពិការភាពរបស់អង្គការ ILO និងអង្គការយូនីសេហ្វ។

## ៣.៥ សហគមន៍ដែលមានបរិយាបន្ន និងការបង្កលក្ខណៈងាយស្រួល

### *ទិដ្ឋភាពទូទៅ*

គោលដៅចុងក្រោយនៃបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព គឺមនុស្សគ្រប់វ័យ គ្រប់យេនឌ័រ និងពិការភាពគ្រប់ប្រភេទ បានចូលរួមយ៉ាងពេញលេញក្នុងជីវភាពសង្គម វប្បធម៌ សាសនា សេដ្ឋកិច្ច និងនយោបាយនៃសហគមន៍របស់ពួកគេ ដោយស្មើភាពជាមួយអ្នកដទៃ។ សហគមន៍ដែលមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួលជាទីកន្លែងដែលអាចប្រើប្រាស់បានដោយមនុស្សគ្រប់រូប និងជាទីកន្លែងដែលមនុស្សគ្រប់រូបអាចចូលរួមពេញលេញស្មើភាពគ្នា និងយ៉ាងឯករាជ្យដោយគ្មានឧបសគ្គអ្វីទាំងអស់។ ប្រសិនបើជនមានពិការភាព និងជនងាយរងគ្រោះផ្សេងទៀតមិនអាចទទួលបានហេដ្ឋារចនាសម្ព័ន្ធ សេវា និងឱកាសដែលមាននៅក្នុងសហគមន៍ពួកគេនឹងមិនត្រូវបានចូលរួមពេញលេញឡើយ។

ក្នុងសង្គមភាគច្រើន មានឧបសគ្គជាច្រើនដែលរារាំងការចូលរួម និងបរិយាបន្នពេញលេញ ដូចជា ការមាក់ងាយ និងការរើសអើង ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមិនបង្កលក្ខណៈងាយស្រួល កង្វះព័ត៌មាន និងការផ្សព្វផ្សាយក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួល កង្វះសេវាសមស្រប ឬមានតម្លៃសមរម្យ កង្វះការពិគ្រោះយោបល់ និងការចូលរួមរបស់ជនមានពិការភាពក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ការយល់ដឹងមានកម្រិតក្នុងចំណោមជនមានពិការភាពអំពីសិទ្ធិរបស់ពួកគេ និងរបៀបទាមទារសិទ្ធិរបស់ពួកគេ និងការយល់ដឹងមានកម្រិតក្នុងចំណោមអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវាអំពីសិទ្ធិរបស់ជនមានពិការភាព និងរបៀបធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយជនមានពិការភាព។ ពេលខ្លះ ជនមានពិការភាពត្រូវបានទុកឱ្យនៅផ្ទះដោយសារពួកគេអាចខ្វះលទ្ធភាពទទួលបានការថែទាំសុខភាព ឧបករណ៍ជំនួយ និងការគាំទ្រផ្សេងទៀតដែលនឹងសម្រួលដល់បរិយាបន្នកាន់តែប្រសើរនៅក្នុងជីវិតរស់នៅក្នុងសហគមន៍របស់ពួកគេ។

---

[69] សម្រាប់ព័ត៌មានបន្ថែមស្តីពីការងាររបស់ UNESCAP ពាក់ព័ន្ធនឹងកិច្ចគាំពារសង្គម និងដើម្បីទទួលបានការបណ្តុះបណ្តាល សូមចូលទៅកាន់ ៖ https://www.unescap.org/our-work/social-development/social-protection

[70] *How to Design Disability-Inclusive Social Protection*, UNESCAP, Bangkok, 2021

បុព្វកថានៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) ទទួលស្គាល់ «សារៈសំខាន់នៃការទទួលបាននូវការសម្រួលផ្នែកវប្បធម៌ សេដ្ឋកិច្ច សង្គមកិច្ច កាយសម្បទា សុខភាព ការអប់រំ និងព័ត៌មាន និងទំនាក់ទំនង ដើម្បីជួយឱ្យជនពិការអាចទទួលបានយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់»។ មាត្រា ៩ ផ្តោតលើការបង្កលក្ខណៈងាយស្រួល។ អនុសញ្ញានេះអំពាវនាវឱ្យប្រទេសកម្ពុជាក្នុងនាមជារដ្ឋភាគី «ជួយជនពិការឱ្យរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃជីវិត» ដោយចាត់ «វិធានការសមស្របដើម្បីធានា... ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ទទួលបាននូវបរិស្ថានជុំវិញ មធ្យោបាយធ្វើដំណើរ ព័ត៌មាន និងទំនាក់ទំនង រួមទាំងប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង គ្រឿងសម្រួល និងសេវាកម្មផ្សេងទៀតដែលបើកចំហ ឬផ្តល់ឱ្យប្រើប្រាស់ជាសាធារណៈ ទាំងនៅទីក្រុង ទាំងនៅតាមទីជនបទដាច់ស្រយាល» ដោយត្រូវរួមបញ្ចូលនូវ «អត្តសញ្ញាណ និងការលុបបំបាត់ឧបសគ្គ និងឧបសគ្គទាំងឡាយដល់ការទទួលបាននូវសិទ្ធិទាំងនេះ»។

### *ឧបសគ្គឥរិយាបថ*

របៀបនៃការប្រព្រឹត្តចំពោះមនុស្សពេញវ័យ យុវជន កុមារ និងជនចាស់ជរាដែលមានពិការភាពគ្រប់ប្រភេទ ដោយគ្រួសាររបស់ពួកគេ សហគមន៍របស់ពួកគេ និយោជករបស់ពួកគេ និងអ្នកផ្តល់សេវា សុទ្ធសឹងជាកត្តាសំខាន់ក្នុងការ សម្រេចបាន ឬកម្រិតបរិយាបន្នសង្គម។ ការយល់ខុស ផ្ទត់គំនិត ឥរិយាបថ និងជំនឿអវិជ្ជមាន និងកង្វះចំណេះដឹងស្តីពីពិការភាពក្នុងសហគមន៍ អាចប៉ះពាល់ដល់ទិដ្ឋភាពជាច្រើននៃជីវិតរស់នៅរបស់ជនមានពិការភាព និងលទ្ធភាព របស់ពួកគេក្នុងការទទួលបានសេវា និងឱកាស។ ពេលខ្លះ ការមាក់ងាយ និងការរើសអើងត្រូវបានធ្វើឱ្យក្លាយជារឿង ធម្មតា ឬត្រូវបានអត់ឱនដោយសង្គម។ ឥរិយាបថអវិជ្ជមានចំពោះជនមានពិការភាពក៏អាចធ្វើឱ្យប៉ះពាល់ផ្លូវចិត្តដែល នាំឱ្យមានតម្លៃផ្ទាល់ខ្លួនទាប និងភាពស្ទាក់ស្ទើរក្នុងការចូលរួមក្នុងសកម្មភាព និងឱកាសនានា។ ដូចក្នុងសង្គមជាច្រើន ដែរ ឥរិយាបថសហគមន៍ចំពោះបរិយាបន្នពិការភាព និងឥរិយាបថរបស់អ្នកផ្តល់សេវា និងអាជ្ញាធរមូលដ្ឋាន មួយចំនួន បង្ហាញថាការមាក់ងាយ និងការរើសអើង នៅតែកើតមានជាទូទៅ។

កង្វះការយល់ដឹងរបស់បុគ្គល និងសេវានៅក្នុងសហគមន៍អំពីសិទ្ធិ និងសមត្ថភាពរបស់ជនមានពិការភាពច្រើនតែនាំឱ្យមានការរើសអើង ការផាត់ចេញ និងការបង្កការលំបាកដល់ជនមានពិការភាព។ ការផ្លាស់ប្តូរឥរិយាបថអវិជ្ជមាន ចំពោះជនមានពិការភាព និងការប្រឈមមុខនឹងការមាក់ងាយ និងការរើសអើង អាចផ្តល់ការរួមចំណែកវិជ្ជមានឆ្ពោះ ទៅរកបរិយាបន្នកាន់ តែប្រសើរ។ សកម្មភាពនានា ដូចជា ព្រឹត្តិការណ៍ប៉ារ៉ាហ្គេម ឆ្នាំ ២០២៣ នៅទីក្រុងភ្នំពេញ និងការចូលរួម របស់ជន មានពិការភាពក្នុងសកម្មភាពវប្បធម៌ បានផ្តល់ ការរួម ចំណែកដ៏មានតម្លៃដល់ការផ្លាស់ប្តូរឥរិយាបថអវិជ្ជមាន។



គួរគប្បីពិចារណាពីយុទ្ធនាការដែលមានគោលបំណងបង្កើនការយល់ដឹង និងផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយាតាមរយៈមធ្យោបាយផ្សេងៗ ដូចជា ទូរទស្សន៍ វិទ្យុ សារព័ត៌មាន និងព្រឹត្តិការណ៍នានា ដោយផ្តោតសំខាន់លើបញ្ហាដូចជា ការពង្រឹងការយល់ដឹងអំពីពិការភាព និងសិទ្ធិរបស់មនុស្សដែលមានពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យ ការប្រឈមមុខជាមួយឥរិយាបថអវិជ្ជមានចំពោះជនមានពិការភាព និងបុរេនិច្ឆ័យចំពោះពិការភាព ការកំណត់រក និងដោះស្រាយឧបសគ្គរាំងបរិយាបន្នក្នុងគម្រោង សេវា និងហេដ្ឋារចនាសម្ព័ន្ធ ការបង្ហាញសមិទ្ធផលរបស់ស្ត្រី ក្មេងស្រី ក្មេងប្រុស និងបុរសដែលមានពិការភាព និងការកសាងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា ដើម្បីធានានូវអភិក្រមផ្អែកលើសិទ្ធិសម្រាប់ការរៀបចំផែនការ ការផ្តល់សេវា និងឱកាសផ្សេងទៀត[71]។

---

[71] សម្រាប់ការណែនាំស្តីពីការបង្កើនការយល់ដឹង សូមមើល Handbook for Trainers on Incorporating Disabilities into Government in Sub-

## *ផាសុកវត្ថុផ្នែករូបវន្ត ឬការបង្កលក្ខណៈងាយស្រួល*

នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ប្រកាសអន្តរក្រសួងលេខ ២៤៨ ស្តីពីការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MoLMUPC) និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ បទដ្ឋានបច្ចេកទេសទាក់ទងនឹងគម្រោងសាងសង់ និងការកែប្រែអគារហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលផ្តល់សេវាសាធារណៈ និងលំហសាធារណៈរួមទាំងបណ្តាញផ្លូវថ្នល់ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង សួនច្បារ ចំណតរថយន្ត ស្ថានីយរថភ្លើង អាកាសយានដ្ឋាន អគាររដ្ឋបាល សាលារៀន គ្រឹះស្ថានអប់រំ មន្ទីរពេទ្យ មណ្ឌលសុខភាព គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ បុរី អគារលំនៅដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន ផ្សារ រោងចក្រ និងអគារឯកជនផ្សេងទៀតដែលប្រើប្រាស់ដោយជនមានពិការភាព ដើម្បីធានាលទ្ធភាពចូលប្រើប្រាស់ដោយសុវត្ថិភាព និងគ្មានឧបសគ្គ[72]។

កម្មវិធី ACCESS បានគាំទ្រការផលិត និងការដាក់ឱ្យអនុវត្តនូវ*បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព* ដែលត្រូវបានរៀបចំឡើងក្រោមកិច្ចសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC-SG) និងអង្គការ អេច អាយ (HI)[73]។ កម្មវិធី ACCESS ក៏បានគាំទ្រផងដែរដល់ការអនុវត្តការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីបទដ្ឋានបច្ចេកទេសនេះទៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការផលិតវីដេអូគំនូរជីវចលចំនួន ៥ ដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃបទដ្ឋានរូបវន្តបង្កលក្ខណៈងាយស្រួល។

ទោះបីជាមានវឌ្ឍនភាពខ្លះក៏ដោយ ប៉ុន្តែចាំបាច់ត្រូវមានការផ្តោតការយកចិត្តបន្ថែមដើម្បីធានាការអនុវត្តបទដ្ឋានទាំងនេះក្នុងគម្រោងសាងសង់ថ្មីៗទាំងអស់ និងការបែងចែកធនធានហិរញ្ញវត្ថុសម្រាប់ការកែប្រែអគារហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលមានស្រាប់។

## *ព័ត៌មាន និងការផ្សព្វផ្សាយក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួល*



ព័ត៌មានក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួល ពាក់ព័ន្ធនឹងការរចនា និងការផ្គត់ផ្គង់ផលិតផល (ដូចជា កុំព្យូទ័រ និងទូរស័ព្ទ) និងសេវាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ទូរស័ព្ទ និងទូរទស្សន៍) រួមទាំងសេវាតាមវេបសាយ និងទូរស័ព្ទ ដោយផ្អែកលើតម្រូវការរបស់ជនដែលមានប្រភេទពិការភាពផ្សេងៗ។ ទម្រង់ដែលបង្កលក្ខណៈងាយស្រួល អាចរួមបញ្ចូលភាសាងាយស្រួលអាន អក្សរធំៗ អក្សរប្រៃយ៍ ឬការបកប្រែភាសាសញ្ញា។ ចំណុចនេះក៏ទាក់ទងនឹងបច្ចេកវិទ្យាផងដែរ ដូចជា សំឡេង រូបភាព និងភាសាដែលត្រូវបានផលិត និងផ្តល់ជូនដោយបច្ចេកវិទ្យា។ បញ្ហាប្រឈមក្នុងការទទួលបានព័ត៌មាន និងការផ្សព្វផ្សាយ រួមមានកង្វះចំណេះដឹងក្នុងចំណោមអ្នកផ្តល់សេវាអំពីទម្រង់ និងបច្ចេកវិទ្យាដែលបង្កលក្ខណៈងាយស្រួល កង្វះអ្នកបកប្រែភាសាសញ្ញា តម្លៃនៃបច្ចេកវិទ្យាសមស្របដើម្បីផលិតទម្រង់ដែលបង្កលក្ខណៈងាយស្រួល បច្ចេកវិទ្យាផ្ទាល់អាចមិនបង្កលក្ខណៈងាយស្រួល និងល្បឿននៃការផ្លាស់ប្តូរបច្ចេកវិទ្យាមិនបានគិតគូរពីតម្រូវការរបស់ជនមានពិការភាពឱ្យបានទាន់ពេលវេលា។

ប្រទេសកម្ពុជាគឺជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញា Marrakesh។ សន្ធិសញ្ញានេះជាលិខិតុបករណ៍ច្បាប់អន្តរជាតិមួយដែលមានគោលបំណងធ្វើឱ្យមានភាពងាយស្រួលសម្រាប់ជនមានពិការភាពភ្នែក ជនបាត់បង់សមត្ថភាពគំហើញ ក្នុងការប្រើប្រាស់ឯកសារផ្សេងៗសម្រាប់ការងារ ដែលឯកសារទាំងនោះត្រូវបានការពារដោយការរក្សាសិទ្ធិ។

---

National Administration, UNICEF and Ministry of Interior, 2016; see also Trainer's Manual ។

72 ប្រកាសអន្តរក្រសួងលេខ ២៤៨ ស្តីពីការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ (ការបកប្រែក្រៅផ្លូវការ)។

73 *Technical Standards on Physical Accessibility Infrastructure for Persons with Disabilities*, Disability Action Council Secretariat (DAC-SG), 2018 (ការបកប្រែក្រៅផ្លូវការ)។

អង្គការយូណេស្កូ កំពុងខិតខំពន្លឿនសិទ្ធិរបស់ជនមានពិការភាពក្នុងការទទួលបានព័ត៌មាន និងដោះស្រាយឧបសគ្គនានា ដូចជា តាមរយៈ *ការវាយតម្លៃតម្រូវការព័ត៌មានសម្រាប់ជនមានពិការភាពនៅកម្ពុជា* ដែលបានចេញផ្សាយនៅឆ្នាំ ២០២៤។ ក្រោមកិច្ចសហការជាមួយអង្គការជនពិការកម្ពុជា (អ.ព.ក) និងក្រសួងព័ត៌មាន អង្គការយូណេស្កូ បានផ្ដល់ការបណ្ដុះបណ្ដាលដល់មន្ត្រីមន្ទីរព័ត៌មានមកពី ២៤ ខេត្ត ដើម្បីកសាងការយល់ដឹង និងសមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបកាន់តែប្រសើរទៅនឹងតម្រូវការព័ត៌មានរបស់ជនមានពិការភាព សំដៅផ្ដល់សេវាសាធារណៈប្រកបដោយគុណភាព និងពង្រឹងការចូលរួមប្រកបដោយបរិយាបន្នរបស់ពួកគេក្នុងនាមជាពលរដ្ឋ ។ កម្មវិធីសិក្សាសម្រាប់ការបណ្ដុះបណ្ដាលនេះផ្ដោតសំខាន់លើការអភិវឌ្ឍបរិយាបន្នពិការភាព លទ្ធភាពទទួលបានព័ត៌មាន ក៏ដូចជាគោលនយោបាយ និងច្បាប់ដែលមានបរិយាបន្នពិការភាព រួមទាំង NDSP[74]។

### *ទឹកស្អាត និងអនាម័យ (WASH)*

សមាជិកទាំងអស់នៅក្នុងសហគមន៍ សុទ្ធតែត្រូវការហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ (WASH)។ ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ ផ្ដល់លទ្ធភាពទទួលបានទឹកពិសាដែលមានសុវត្ថិភាព បង្គន់អនាម័យកម្រិតមូលដ្ឋាន និងអនាម័យល្អ។ ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ ជាតម្រូវការចាំបាច់នៅក្នុងសាលារៀន មូលដ្ឋានសុខាភិបាល កន្លែងធ្វើការ និងនៅក្នុង ឬនៅជិតផ្ទះ។ លទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ មានសារៈសំខាន់សម្រាប់សុខភាព និងសុខុមាលភាពរបស់ជនមានពិការភាព។ ទោះយ៉ាងណាជនមានពិការភាពអាចប្រឈមនឹងឧបសគ្គក្នុងការទទួលបានហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ ដូចជា ការរចនាមិនល្អដោយសារតែជាញឹកញាប់ អ្នករៀបចំផែនការមិនបានគិតគូរពីពិការភាពនៅក្នុងការរចនាហេដ្ឋារចនាសម្ព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធស្ថិតនៅឆ្ងាយពីផ្ទះរបស់អ្នកដែលត្រូវការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ បរិស្ថានរូបវន្តជុំវិញហេដ្ឋារចនាសម្ព័ន្ធ ដូចជា កាំជណ្ដើរ ឬផ្ទៃដីគ្រើម អាចរារាំងការចូលប្រើប្រាស់ ឥរិយាបថរបស់សមាជិកផ្សេងទៀតនៅក្នុងសហគមន៍ចំពោះជនមានពិការភាព អាចជាឧបសគ្គរារាំងការចូលប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ និងអាចមានកង្វះការពិគ្រោះយោបល់ជាមួយជនមានពិការភាពអំពីអ្វីដែលជាតម្រូវការ និងអ្វីដែលសមស្រប។

### *ការរចនាប្លង់ជាសកល*



ដើម្បីបង្កើនលទ្ធភាពប្រើប្រាស់ មាត្រា ២ នៃអនុសញ្ញាស្ដីពីសិទ្ធិជនពិការ កំណត់និយមន័យនៃ «ការរចនាប្លង់ ជាសកល» ជា ការគូសប្លង់ផលិតផល បរិស្ថាន កម្មវិធី និងសេវាកម្មផ្សេងៗ ដែលមនុស្សគ្រប់រូបអាចប្រើប្រាស់បាន ដោយមិនទាមទារចំពោះការសម្របតាម ឬគម្រោងប្លង់ពិសេសផ្សេងទៀត ក្នុងវិសាលភាពធំបំផុតដែលអាចធ្វើទៅបាន។ ការរចនាប្លង់ជាសកលមិនមែនសម្រាប់តែជនមានពិការភាពទេ។ អ្នកដទៃក៏អាចទទួលបានផលប្រយោជន៍ដែរ ដូចជា ចាស់ជរា ស្ត្រីមានផ្ទៃពោះ អ្នកប្រើរទេះរុញកូនក្មេង ឬអ្នកដែលមានវ៉ាលិស ឬកាន់/យួរឥវ៉ាន់។ អនុសញ្ញានេះអំពាវនាវឱ្យរដ្ឋភាគីលើកកម្ពស់ការរចនាប្លង់ជាសកលក្នុងការអភិវឌ្ឍស្តង់ដា និងគោលការណ៍ណែនាំ។

ការរចនាប្លង់ជាសកលផ្អែកលើគោលការណ៍ចំនួន ៧៖

- គោលការណ៍ទី ១ ៖ ការប្រើប្រាស់ប្រកបដោយសមធម៌ - ការរចនាដែលមានប្រយោជន៍ និងអាចប្រើប្រាស់បានសម្រាប់មនុស្សដែលមានសមត្ថភាពចម្រុះ
- គោលការណ៍ទី ២ ៖ ភាពបត់បែនក្នុងការប្រើប្រាស់ - ការរចនាដែលសម្របទៅតាមចំណង់ចំណូលចិត្ត និងសមត្ថភាពផ្សេងៗរបស់បុគ្គល

---

[74] *Promoting Disability Inclusion and Information Accessibility in Cambodia*, UNESCO News, 5 April 2024

- គោលការណ៍ទី ៣ ៖ ការប្រើប្រាស់យ៉ាងសាមញ្ញ និងងាយស្រួល - ការរចនាដែលងាយស្រួលយល់ ដោយមិនគិតពីបទពិសោធន៍ ចំណេះដឹង ជំនាញភាសា ឬកម្រិតផ្ដោតអារម្មណ៍របស់អ្នកប្រើប្រាស់
- គោលការណ៍ទី ៤ ៖ ព័ត៌មានដែលអាចយល់បាន - ការរចនាដែលបង្ហាញព័ត៌មានចាំបាច់ប្រកបដោយប្រសិទ្ធភាពដល់អ្នកប្រើប្រាស់ ដោយមិនគិតពីលក្ខខណ្ឌជុំវិញ ឬសមត្ថភាពញ្ញាណដឹងរបស់អ្នកប្រើប្រាស់
- គោលការណ៍ទី ៥ ៖ ការកាត់បន្ថយកំហុសឆ្គង - ការរចនាដែលកាត់បន្ថយជាអតិបរមានូវមុខសញ្ញាគ្រោះថ្នាក់ និងផលវិបាកអវិជ្ជមាននៃសកម្មភាពដោយចៃដន្យ ឬដោយអចេតនា
- គោលការណ៍ទី ៦ ៖ ទាមទារការប្រើកម្លាំងកាយតិច - ការរចនាដែលអាចប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងផាសុកភាព និងបង្កការនឿយហត់តិចបំផុត
- គោលការណ៍ទី ៧ ៖ ទំហំ និងលំហសម្រាប់ការចូលទៅជិត និងប្រើប្រាស់ - ការរចនាដែលផ្ដល់ទំហំ និងលំហសមស្របសម្រាប់ការចូលទៅជិត ការឈោងដល់ ការចាត់ចែង/គ្រប់គ្រង និងការប្រើប្រាស់ ដោយមិនគិតពីទំហំរាងកាយ ឥរិយាបថ ឬចល័តភាពរបស់អ្នកប្រើប្រាស់[75]។

ការអនុវត្តគោលការណ៍នៃការរចនាប្លង់ជាសកល អាចឱ្យមនុស្សគ្រប់រូប ដោយមិនគិតពីអាយុ ឬសមត្ថភាព ប្រើប្រាស់អគារ មធ្យោបាយ ធ្វើដំណើរ ទីសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត។ អគារ និងលំហខាងក្រៅដែលមិនបង្កលក្ខណៈងាយស្រួល បានផាត់ចេញជនមានពិការភាពពីការចូលរួមក្នុងការងារ ការអប់រំ និងជីវភាពសង្គម និងវប្បធម៌។ ទោះយ៉ាងណា ការសំខាន់គឺត្រូវទទួលស្គាល់ថា ការអនុវត្តការរចនាប្លង់ជាសកលមិនគួរផាត់ចេញការផ្ដល់បច្ចេកវិទ្យាជំនួយសម្រាប់ក្រុមជនមានពិការភាពជាក់លាក់ ក្នុងករណីចាំបាច់នោះទេ។



## *ការណែនាំដើម្បីពង្រឹងបរិយាបន្នពិការភាព*

ការជម្នះឧបសគ្គរាំងការសម្រេចបានសហគមន៍ដែលមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួល ទាមទារឱ្យមានការអភិក្រមចម្រុះមួយ។ ចាំបាច់ត្រូវតែដោះស្រាយគ្រប់ទិដ្ឋភាពទាំងអស់ រួមទាំងឧបសគ្គឥរិយាបថ ឧបសគ្គរូបវន្ត និងឧបសគ្គរាំងការទទួលបានព័ត៌មាន។ ខាងក្រោមនេះជាជំហានដើម្បីសម្រេចបានបរិស្ថានអំណោយផល៖

- ការពិចារណាអំពីការបង្កលក្ខណៈងាយស្រួលតាំងពីដំណាក់កាលដំបូងនៃដំណើរការរៀបចំ ឬការពិនិត្យឡើងវិញលើគម្រោង និងកម្មវិធីនានា
- ការចូលរួមរបស់ជនមានពិការភាពក្នុងការរចនា និងការពិនិត្យឡើងវិញលើគម្រោង និងកម្មវិធីនានា
- ការដោះស្រាយគ្រប់ទិដ្ឋភាពនៃការបង្កលក្ខណៈងាយស្រួល
- ការអប់រំអ្នកបង្កើតគោលនយោបាយ និងអ្នករចនា
- វិភាជថវិកាគ្រប់គ្រាន់ដើម្បីធានាការបង្កលក្ខណៈងាយស្រួល
- ការប្រើប្រាស់ការរចនាប្លង់ជាសកលជាគោលការណ៍ណែនាំ។

ឯកសារណែនាំដើម្បីគាំទ្រសកម្មភាពបង្កើតសហគមន៍ដែលមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួល៖

- ***បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព*** ផ្ដល់ព័ត៌មានលម្អិតសម្រាប់ការរចនាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពគ្រប់ប្រភេទអាចចេញ-ចូល ឡើង-ចុះ និងប្រើប្រាស់បាន ដូចជា ច្រកផ្លូវដែលភ្ជាប់ផ្លូវមួយទៅផ្លូវមួយទៀត បន្ទះដែក គំនូសឆ្នូតដែលមានរំលេចពណ៌នៅតាមផ្លូវ ជម្រាល ផ្លូវដើរ បង្កាន់ដៃសុវត្ថិភាព កាំជណ្ដើរ ទ្វារ និងដៃ

[75] The Inclusion Imperative: Towards Disability-inclusive and Accessible Urban Development: Key Recommendations for an Inclusive Urban Agenda, CBM and Global Network on Disability Inclusive and Accessible Urban Development, 2016, 16

ទ្វារ ជណ្តើរ យោង និងទ្វារប៊ូតុងបញ្ជាជណ្តើរយន្ត ជណ្តើរយន្ត ជណ្តើររត់ដឹកអ្នកដំណើរ ឧបករណ៍ ប្រាប់ដំណឹងជាសូរសំឡេង ច្រកដើរខាងក្នុង ទំនប់ខណ្ឌមាត់ទ្វារ កន្លែងសម្រាក ស្លាកសញ្ញា ភ្លើងសញ្ញា បញ្ជរផ្តល់សេវា បង្គន់បែបទីក្រុង និងបែបជនបទ បង្គន់នោម កន្លែងសម្រាប់លាងដៃ (ឡាវ៉ាបូ) ប្រភពទឹកអណ្តូងស្នប់ និងអណ្តូងដៃ កន្លែងសម្រាប់ងូតទឹក សម្ភារបរិក្ខារនៅក្នុងថ្នាក់រៀន ឬសាលប្រជុំ និងបរិក្ខារជំនួយសុវត្ថិភាពផ្សេងៗ[76]។

- ***«ការទាមទារឱ្យមានបរិយាបន្ន ៖ ឆ្ពោះទៅរកការអភិវឌ្ឍទីក្រុងដែលមានបរិយាបន្នពិការភាព និងបង្កលក្ខណៈងាយស្រួល ៖ អនុសាសន៍សំខាន់ៗសម្រាប់ការរៀបចំទីក្រុងប្រកបដោយបរិយាបន្ន»*** គូសបញ្ជាក់ពីកត្តាសំខាន់ៗក្នុងផ្នែក រូបវន្ត សង្គម និងស្ថាប័ន ដែលដើរតួជាឧបសគ្គ ឬជាអ្នកសម្របសម្រួលដល់ការចូលរួមយ៉ាងពេញលេញ និងស្មើភាពរបស់ជនមានពិការភាព។ ឯកសារនេះបង្ហាញពីតួនាទីសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ សង្គមស៊ីវិល ស្ថាប័នសិក្សាស្រាវជ្រាវ មូលនិធិសប្បុរសធម៌ និងវិស័យឯកជនក្នុងការធានាថា ទីក្រុង នាពេលអនាគតមានបរិយាបន្ន បង្កលក្ខណៈងាយស្រួល និងគ្មានឧបសគ្គសម្រាប់ជនមានពិការភាព[77]។
- ***គោលការណ៍ណែនាំស្តីពីការបង្កលក្ខណៈងាយស្រួលរបស់ W3C (WCAG) ២.២*** ផ្តល់អនុសាសន៍ជាច្រើនសម្រាប់ធ្វើឱ្យមាតិកាវេបសាយបង្កលក្ខណៈងាយស្រួលកាន់តែច្រើនដល់អ្នកប្រើប្រាស់ ដែលមានពិការភាព។ គោលការណ៍ណែនាំនេះដោះស្រាយតម្រូវការជាច្រើនរបស់អ្នកប្រើប្រាស់ផ្សេងៗ ដូចជា អ្នកប្រើប្រាស់ដែលពិការភ្នែក ឬកម្សោយគំហើញ និងបញ្ហាផ្នែកចក្ខុទស្សន៍ផ្សេងទៀត អ្នកប្រើប្រាស់ដែលគថ្លង់ និងមានកម្សោយការស្តាប់ផ្សេងទៀត អ្នកប្រើប្រាស់ដែលពិបាកក្នុងការផ្លាស់ទី និងធ្វើកិច្ចការហត្ថកម្ម អ្នកប្រើប្រាស់ដែលមានពិការភាពការនិយាយស្តី អ្នកប្រើប្រាស់ដែលមានកម្សោយញ្ញាណដឹងផ្សេងទៀត អ្នកប្រើប្រាស់ដែលមានកម្សោយសតិបញ្ញា និងការលំបាកក្នុងការរៀនសូត្រ ឬរួមបញ្ចូលទាំងអស់នេះ។ គោលការណ៍ណែនាំនេះលើកឡើងពីការបង្កលក្ខណៈងាយស្រួលនៃមាតិកាវេបសាយនៅលើឧបករណ៍ និងប្រភេទមាតិកាវេបសាយទាំងអស់[78]។
- ***គេហទំព័រសម្រាប់ជនមានពិការភាព*** របស់រដ្ឋាភិបាលអូស្ត្រាលី ផ្តល់ការណែនាំអំពីការបង្កើតសម្ភារៈ ឬឯកសារដែលបង្កលក្ខណៈងាយស្រួល រួមទាំងឯកសារបោះពុម្ព និងឯកសារឌីជីថល និងតំណភ្ជាប់ទៅកាន់ធនធានដែលមាន[79]។
- ***ការចាត់វិធានការដើម្បីសម្រេចបានសេវាទឹកស្អាត និងអនាម័យដែលមានបរិយាបន្ន*** ជាវគ្គបណ្តុះបណ្តាលតាមអនឡាញសម្រាប់អ្នកអនុវត្តន៍កម្មវិធីទឹកស្អាត និងអនាម័យ រួមទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត និងសេវាអនាម័យ អ្នកផ្តល់សេវាសាធារណៈ និងឯកជន និយ័តករ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការតាមសហគមន៍។ តាមរយៈវគ្គសិក្សាបឋមតាមអនឡាញនេះ អ្នកសិក្សានឹងបង្កើនចំណេះដឹង និងការយល់ដឹងរបស់ពួកគេអំពីជនមានពិការភាព និងសេវាទឹកស្អាត និងអនាម័យ ដែលមានបរិយាបន្នពិការភាព យល់ដឹងអំពីបញ្ហាប្រឈមរបស់ជនមានពិការភាពក្នុងការទទួលបានសេវា និងផលិតផលទឹកស្អាត និងអនាម័យ និងរបៀបកំណត់រក និងដោះស្រាយបញ្ហាប្រឈមទាំងនេះ និងរៀនសូត្រពីរបៀបរៀបចំផែនការ អនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីទឹកស្អាត និងអនាម័យដែលមានបរិយាបន្នពិការភាពក្នុងបរិបទនៃការអភិវឌ្ឍ ឬមនុស្សធម៌[80]។

---

[76] *Technical Standards on Physical Accessibility Infrastructure for Persons with Disabilities*, Disability Action Council Secretariat (DAC-SG), 2018 (unofficial translation)

[77] *The Inclusion Imperative: Towards Disability-inclusive and Accessible Urban Development: Key Recommendations for an Inclusive Urban Agenda*, CBM and Global Network on Disability Inclusive and Accessible Urban Development, 2016

[78] *W3C Accessibility Guidelines (WCAG) 2.2*

[79] *Disability Gateway*

[80] *Taking action to achieve inclusive WASH*, Global Water and Sanitation Partnership

- ***ការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យដែលមានបរិយាបន្នពិការភាព៖ ការរួមបញ្ចូលជនមានពិការភាពក្នុងកម្មវិធីទឹកស្អាត និងអនាម័យរបស់អង្គការយូនីសេហ្វ*** មានគោលបំណងផ្តល់ឧបករណ៍អនុវត្តន៍ជាក់ស្តែង ដើម្បីពង្រឹងការរួមបញ្ចូល និងលទ្ធភាពរបស់កុមារ និងមនុស្សពេញវ័យដែលមានពិការភាពក្នុងការទទួលបានអន្តរាគមន៍ទឹកស្អាត និងអនាម័យរបស់អង្គការយូនីសេហ្វ។ ឯកសារណែនាំនេះក៏ផ្តល់តំណភ្ជាប់ទៅកាន់ធនធានទឹកស្អាត និងអនាម័យដែលពាក់ព័ន្ធផ្សេងទៀតផងដែរ[81]។

## ៣.៦ សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌

### *ទិដ្ឋភាពទូទៅ*

ស្ត្រី និងក្មេងស្រីដែលមានពិការភាព ងាយទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) រួមទាំងអំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវចិត្ត និងអំពើហិង្សាផ្លូវភេទ ច្រើនជាងស្ត្រី និងក្មេងស្រីដែលគ្មានពិការភាព ដល់ទៅ ៣ ដង ដោយសារទម្រង់ចម្រុះ និងប្រសព្វគ្នានៃការរើសអើងដែលពួកគេបានជួបប្រទះ។ ស្ត្រី និងក្មេងស្រីដែលមានពិការភាព ងាយទទួលរងអំពើហិង្សាផ្លូវភេទច្រើនជាងស្ត្រី និងក្មេងស្រីដែលគ្មានពិការភាព ដល់ទៅ ១០ ដង។ លើសពីនេះ ជនមានពិការភាពជាច្រើននៅកម្ពុជាប្រឈមនឹងឧបសគ្គក្នុងការទទួលបានសេវា និងការគាំទ្រផ្នែកយុត្តិធម៌។ ស្ថានភាពកាន់តែដុនដាបសម្រាប់អ្នកដែលគថ្លង់ ពិការភ្នែក ឬមានកម្សោយសតិបញ្ញា និងពិការភាពផ្លូវចិត្ត ជាពិសេសស្ត្រី។ ដោយសារគ្មានលទ្ធភាពទទួលបានយុត្តិធម៌ ជនមានពិការភាពមិនអាចអនុវត្តសិទ្ធិរបស់ពួកគេ ដេញដោលការរើសអើង ការបញ្ចេញមតិរបស់ពួកគេ ឬជម្រុញអោយអាជ្ញាធរបានទទួលខុសត្រូវលើភារៈកិច្ចរបស់ពួកគេឡើយ។

ជនមានពិការភាព ជាពិសេសស្ត្រី និងក្មេងស្រី មានសិទ្ធិទទួលបានការការពារពីគ្រប់ទម្រង់នៃការបៀតបៀន អំពើហិង្សា ការរំលោភបំពាន និងការរើសអើងក្នុងគ្រួសារ និងសហគមន៍ ហើយសិទ្ធិរបស់ពួកគេត្រូវបានគោរព លើកកម្ពស់ និងអនុវត្តប្រកបដោយសមធម៌។ ទោះយ៉ាងណា ជនមានពិការភាពជាច្រើនជួបប្រទះឧបសគ្គក្នុងការទទួលបានកម្មវិធីសំខាន់ៗស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងយុត្តិធម៌។ ឧបសគ្គទាំងនោះមានដូចជា ឧបសគ្គឥរិយាបថ ឧបសគ្គរូបវន្ត និងទំនាក់ទំនង កង្វះការយល់ដឹងក្នុងចំណោមជនមានពិការភាពអំពីសិទ្ធិរបស់ពួកគេ និងភាពមានកម្រិតនៃព័ត៌មានដែលបង្កលក្ខណៈងាយស្រួលស្តីពីសេវាដែលមានផ្តល់ កង្វះការយល់ដឹងអំពីសិទ្ធិរបស់ជនមានពិការភាព និងតម្រូវការជាសុកសមរម្យ ក្នុងចំណោមតួអង្គសំខាន់ៗនៅក្នុងវិស័យអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងយុត្តិធម៌[82]។

*ផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី ឆ្នាំ ២០២៤-២០២៨* (នារីរតនៈទី ៦) របស់ក្រសួងកិច្ចការនារី មានគោលបំណងលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី រួមទាំងស្ត្រី និងក្មេងស្រីដែលមានពិការភាព តាមរយៈការបញ្ជ្រាបយេនឌ័រ។ នារីរតនៈទី ៦ មានកម្មវិធីអាទិភាពចំនួន ៦៖ ១.ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ២.សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ៣.សុខុមាលភាពស្ត្រី និងក្មេងស្រី ៤.កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី ៥.ស្ត្រីក្នុងការដឹកនាំ និងអភិបាលកិច្ច និង ៦.ស្ត្រី និងការប្រែប្រួលអាកាសធាតុ[83]។ *ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០២៤-២០២៨* (NAPVAW4) របស់ក្រសួងកិច្ចការនារីក៏រួមបញ្ចូលស្ត្រី និងក្មេងស្រីមានពិការភាព និងមានគោលបំណងទប់ស្កាត់គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីផងដែរ[84]។

សកម្មភាពរបស់ដៃគូអនុវត្តន៍ជាយុទ្ធសាស្ត្រ ក្នុងចរន្តការងារស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៃកម្មវិធី ACCESS 2 រួមបញ្ចូលស្ត្រី និងក្មេងស្រីមានពិការភាព[85]។

---

[81] *Disability Inclusive WASH Practices: Including people with disabilities in UNICEF Water, Sanitation and Hygiene (WASH) Programming*, UNICEF

[82] សម្រាប់ព័ត៌មានបន្ថែម សូមមើល National Situational Analysis, 39-40

[83] សម្រាប់ព័ត៌មានបន្ថែម សូមមើល Five Year Strategic Plan For Strengthening Gender Mainstreaming and Women's Empowerment 2024-2028 (Neary Rattanak VI)

[84] សម្រាប់ព័ត៌មានបន្ថែម សូមមើល National Action Plan to Prevent Violence Against Women 2024-2028

[85] ដៃគូអនុវត្តន៍ជាយុទ្ធសាស្ត្រនៃចរន្តការងារស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័ររួមមាន UNFPA, UNWomen, CDPO, TPO និង Legal Aid Cambodia។

**ទិដ្ឋភាពទូទៅនៃចំណុចចាប់ផ្តើមសម្រាប់ការដាក់បញ្ចូលបរិយាបន្នពិការភាពទៅក្នុងកម្មវិធីស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ[86]**

### ការរៀបចំផែនការ

១. ពិនិត្យក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយស្តីពីពិការភាព និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ

២. ចាប់ដៃគូសហការជាមួយអង្គការសង្គមស៊ីវិលដែលមានបរិយាបន្នពិការភាព

៣. ធ្វើឱ្យរង្វាយតម្លៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការពិគ្រោះយោបល់មានបរិយាបន្នពិការភាព

### ការអនុវត្ត

១. ធ្វើឱ្យការសម្របសម្រួលអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងយន្តការបញ្ជូនមានបរិយាបន្នពិការភាព

២. កំណត់ស្តង់ដារស្តីពីលទ្ធភាពទទួលបាន និងបរិយាបន្ន សម្រាប់អ្នកផ្តល់សេវាពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ

៣. តស៊ូមតិ និងកសាងការយល់ដឹងស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងពិការភាព

៤. ដាក់បញ្ចូលពិការភាពទៅក្នុងកម្មវិធីសិក្សា និងការបណ្តុះបណ្តាលស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ

### ការពិនិត្យតាមដាន

១. ប្រមូល និងវិភាគទិន្នន័យបែងចែកតាមពិការភាព

២. កំណត់សូចនាករសម្រាប់កម្មវិធីស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលមានបរិយាបន្នពិការភាព និងការផ្តល់សេវា

៣. ធ្វើការស្រាវជ្រាវដើម្បីពង្រឹងការចែករំលែក និងការរៀនសូត្រជាបន្តបន្ទាប់

មាត្រា ១៣ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ អំពាវនាវឱ្យរដ្ឋភាគីធានាសិទ្ធិទទួលបានប្រព័ន្ធយុត្តិធម៌ដែលមានប្រសិទ្ធភាពសម្រាប់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ រួមទាំងតាមរយៈបទបញ្ញត្តិនៃដំណោះស្រាយសមស្របតាមអាយុ និងតាមនីតិវិធី ដើម្បីជួយសម្រួលតួនាទីដ៏មានប្រសិទ្ធភាពរបស់ពួកគេ ទោះក្នុងនាមជាអ្នកចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្តី រួមទាំងធ្វើជាសាក្សីនៅរាល់ចំណាត់ការរឿងក្តី។ ទោះយ៉ាងណា អង្គការ UNDP បានកត់សម្គាល់ថា ជនមានពិការភាពប្រឈមនឹងឧបសគ្គផ្សេងៗនៅពេលទទួលបានយុត្តិធម៌ និងជំនួយផ្លូវច្បាប់ ដោយកត់សម្គាល់ថា តួអង្គក្នុងប្រព័ន្ធយុត្តិធម៌មិនមានការយល់ដឹងគ្រប់គ្រាន់អំពីសិទ្ធិរបស់ជនមានពិការភាព និងមិនគិតគូរពីតម្រូវការជាក់លាក់របស់ពួកគេ។ អង្គការ UNDP បានកត់សម្គាល់បន្ថែមទៀតថា ជាញឹកញាប់ មន្ត្រីនគរបាលស្ទាក់ស្ទើរក្នុងការតាមដានបទចោទប្រកាន់ដោយផ្អែកលើចម្លើយរបស់ជនមានពិការភាព ដោយសារការយល់ឃើញមិនត្រឹមត្រូវចំពោះភាពគួរឱ្យជឿជាក់នៃចម្លើយទាំងនោះ។ ជារឿយៗ ឧបសគ្គរចនាសម្ព័ន្ធ ឧបសគ្គនីតិវិធី និងឧបសគ្គរូបវន្ត ធ្វើឱ្យប្រព័ន្ធទាំងមូលមិនបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព ទោះបីជាពួកគេចូលរួមក្នុងនាមជាភាគីរដ្ឋប្បវេណី ឬត្រូវបានពាក់ព័ន្ធក្នុងនាមជាបុគ្គលដែលមានទំនាស់ជាមួយច្បាប់ក៏ដោយ[87]។




*គោលនយោបាយជាតិស្តីពីជំនួយផ្លូវច្បាប់*ដែលមានបរិយាបន្នពិការភាព ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងយុត្តិធម៌ ដោយមានការគាំទ្រពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNOHCHR)។

CARE Cambodia ក៏កំពុងអនុវត្តសកម្មភាពស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលមានបរិយាបន្ន តាមរយៈចរន្តការងារបរិយាបន្នពិការភាពផងដែរ។

86 Disability Inclusion in Gender-Based Violence Programming: promising practices and innovative approaches from UNFPA Asia and the Pacific Country Office, UNFPA, July 2023, 25

87 Practical Guideline on Legal Aid for Persons with Disabilities in Criminal Justice, UNDP, 2020, 4

## *ឯកសារណែនាំដើម្បីពង្រឹងបរិយាបន្នពិការភាព*

ខាងក្រោមនេះជាឯកសារណែនាំ ដើម្បីពង្រឹងបរិយាបន្នពិការភាពក្នុងកម្មវិធីស្ដីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងយុត្តិធម៌៖

- ***បរិយាបន្នពិការភាពក្នុងកម្មវិធីស្ដីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ*** របស់អង្គការ UNFPA គូសបញ្ជាក់ពីការអនុវត្តជាវិជ្ជមាន និងអភិក្រមបែបច្នៃប្រឌិតចំនួន ៦ សម្រាប់បរិយាបន្នពិការភាពក្នុងកម្មវិធីស្ដីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ៖ ការអនុវត្តអភិក្រមផ្លូវភ្លោះ ការដោះស្រាយឥរិយាបថ ជំនឿ និងបទដ្ឋានអវិជ្ជមាន ការកំណត់ស្តង់ដាសម្រាប់បរិយាបន្នពិការភាព ការចូលរួមជាមួយអង្គការតំណាងជនមានពិការភាព ការប្រមូល និងវិភាគទិន្នន័យដែលបែងចែកជាប្រភេទ និងការពង្រឹងសមត្ថភាពរបស់អ្នកអនុវត្តន៍ក្នុងវិស័យអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីធ្វើការជាមួយជនរងគ្រោះដែលមានពិការភាព។ ឯកសារណែនាំនេះ មានសន្លឹកព័ត៌មានស្ដីពីបរិយាបន្នពិការភាពក្នុងកម្មវិធីស្ដីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ឯកសារណែនាំនេះក៏រួមបញ្ចូលផងដែរនូវ *ឧបករណ៍វាយតម្លៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងបរិយាបន្នពិការភាព*សម្រាប់ឱ្យអ្នកផ្ដល់សេវាក្នុងវិស័យអំពើហិង្សាទាក់ទងនឹងយេនឌ័រ ប្រើប្រាស់ដើម្បីប្រមូលព័ត៌មានស្ដីពីថាតើសេវារបស់ពួកគេបំពេញតាមស្តង់ដាស្ដីពីលទ្ធភាពទទួលបាន និងបរិយាបន្នស្ត្រី និងក្មេងស្រីមានពិការភាព ដោយរបៀបណា[88]។
- គោលការណ៍ និងគោលការណ៍ណែនាំដែលបានគូសបញ្ជាក់ក្នុង ***គោលការណ៍ និងគោលការណ៍ណែនាំអន្តរជាតិស្ដីពីលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ជនមានពិការភាព*** មានគោលបំណងជួយដល់រដ្ឋ និងតួអង្គផ្សេងទៀតក្នុងការរចនា អភិវឌ្ឍ កែប្រែ និងអនុវត្តប្រព័ន្ធយុត្តិធម៌ដែលផ្ដល់លទ្ធភាពស្មើភាពដល់ជនមានពិការភាពទាំងអស់ក្នុងការទទួលបានយុត្តិធម៌ ដោយមិនគិតពីតួនាទីរបស់ពួកគេនៅក្នុងដំណើរការនេះ[89]។
- ***គោលការណ៍ណែនាំការអនុវត្តស្ដីពីជំនួយផ្លូវច្បាប់សម្រាប់ជនមានពិការភាព ក្នុងយុត្តិធម៌ព្រហ្មទណ្ឌ*** ដែលបង្កើតឡើងដោយអង្គការ UNDP និងអង្គការជំនួយផ្លូវច្បាប់នៃកម្ពុជា គឺជាធនធានគ្រប់ជ្រុងជ្រោយមួយសម្រាប់ជនមានពិការភាព អង្គការតំណាងជនមានពិការភាព មេធាវី ក៏ដូចជាអ្នកផ្ដល់សេវា និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ។ គោលការណ៍ណែនាំនេះពន្យល់អំពីសិទ្ធិស្របច្បាប់ជាមូលដ្ឋានរបស់ជនមានពិការភាព ដំណើរការផ្លូវច្បាប់ និងតួអង្គក្នុងប្រព័ន្ធនេះ និងវិធីទទួលបានជំនួយផ្លូវច្បាប់ និងទំនាក់ទំនងជាមួយមេធាវី។ ឯកសារនេះក៏ផ្ដល់ផងដែរនូវគោលការណ៍ណែនាំចំនួន ៨ ចំណុចសម្រាប់មេធាវីក្នុងការផ្ដល់សេវាដែលមានបរិយាបន្ន និងគិតគូរពីជនមានពិការភាព ដោយផ្អែកលើការអនុវត្តល្អ និងស្តង់ដា[90]។

---

88 *Disability Inclusion in Gender-Based Violence Programming: promising practices and innovative approaches from UNFPA Asia and the Pacific Country Office*, UNFPA, July 2023

89 *International Principles and Guidelines on Access to Justice for Persons with Disabilities*, Special Rapporteur on the rights of persons with disabilities, Committee on the Rights of Persons with Disabilities and Special Envoy of the Secretary-General on Disability and Accessibility, Geneva, 2020

90 Practical Guideline on Legal Aid for Persons with Disabilities in Criminal Justice, UNDP, 2020 [available in English and Khmer]

## ៣.៧ ស្ថានភាពហានិភ័យ និងការប្រែប្រួលអាកាសធាតុ

### *ទិដ្ឋភាពទូទៅ*

កម្ពុជាងាយរងគ្រោះគ្រោះធម្មជាតិជាច្រើន ដូចជា ទឹកជំនន់ និងភ្លៀងមូសុង និងគ្រោះអាសន្ន ដូចជា ជំងឺរាតត្បាតកូវីដ-១៩។ គ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ និងគ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស ក៏មានការកើនឡើងផងដែរ ប៉ុន្តែជនមានពិការភាពច្រើនតែត្រូវបានគេមើលរំលង។ *របាយការណ៍អង្កេត សកលឆ្នាំ ២០២៣ ស្តីពីជនមានពិការភាព និងគ្រោះមហន្តរាយ* កត់សម្គាល់ថា គ្រោះមហន្តរាយបង្កផលប៉ះពាល់ដល់មនុស្សគ្រប់រូប ប៉ុន្តែមានផលប៉ះពាល់ខ្លាំងទៅលើជនមានពិការភាពដែលនៅតែប្រឈមនឹងឧបសគ្គរារាំងការ ចូលរួម និងការផាត់ចេញពីសង្គម[91]។




*ក្របខណ្ឌសេនដាយ (Sendai) សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៥-២០៣០* ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ប្ដេជ្ញាបង្កើនការចូលរួមរបស់ជនមានពិការភាពក្នុងការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយ (DRR) និងគាំទ្រការធ្វើសេចក្ដីសម្រេចបែបបរិយាបន្នដែលជនមានពិការភាពគឺជាភាគីពាក់ព័ន្ធសំខាន់ ក្នុងការកំណត់ផែនការ និងកម្មវិធីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលបង្កផលជះដល់ជីវិតរបស់យើងទាំងអស់គ្នា[92]។

មនុស្សដែលមានភាពចម្រុះ និងពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យ គួរត្រូវបានការពារក្នុងកម្រិតខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន ពីផលប៉ះពាល់នៃគ្រោះមហន្តរាយធម្មជាតិ គ្រោះអាសន្ន និងការប្រែប្រួលអាកាសធាតុដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយសមាជិកផ្សេងទៀតនៃសហគមន៍របស់ពួកគេដោយគ្មានការរើសអើង។ ទោះយ៉ាងណា ជនមានពិការភាពនៅតែប្រឈមនឹងឧបសគ្គរារាំងការរួមបញ្ចូលពួកគេទៅក្នុងដំណើរការរៀបចំផែនការ និងការអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ឧ. អាជ្ញាធរ និងអ្នកផ្ដល់សេវាដែលទទួលខុសត្រូវលើការទប់ស្កាត់ហានិភ័យគ្រោះមហន្តរាយ (DRR) ការត្រៀមបង្ការ ការឆ្លើយតប និងការស្តារឡើងវិញ មិនដឹងពីសិទ្ធិរបស់ជនមានពិការភាព ឬរបៀបធានាបទបញ្ញត្តិដែលមានអត្ថន័យសម្រាប់ជនមានពិការភាពក្នុងដំណើរការ DRR បញ្ហានៃការបង្កលក្ខណៈងាយស្រួល និងឧបសគ្គឥរិយាបថ កម្រិតការចូលរួមរបស់ជនមានពិការភាព និងអង្គការតំណាងជនមានពិការភាពក្នុងដំណើរការ DRR និងជនមានពិការភាពមិនបានដឹងអំពីផែនការ ឬដំណើរការដោយសារកង្វះព័ត៌មានដែលបង្កលក្ខណៈងាយស្រួល។

*ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយឆ្នាំ ២០១៥* របស់កម្ពុជាមានគោលដៅ ៖ ត្រៀមបង្ការ បន្សាំ កាត់បន្ថយគ្រោះថ្នាក់មុនពេលមានគ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិ ឬមនុស្ស ឆ្លើយតប សង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ និងស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) សម្របសម្រួលសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយទាំងអស់ជាមួយក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ វិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិលក្នុងការលើកកម្ពស់សុវត្ថិភាព និងភាពធន់នឹងគ្រោះ

---

[91] 2023 Global Survey Report on Persons with Disabilities and Disasters, United Nations Office for Disaster Risk Reduction

[92] Sendai Framework for Disaster Risk Reduction 2015-2030, 23; more information see Sendai Framework

មហន្តរាយ។ NCDM មានភារកិច្ចកៀរគរជំនួយមនុស្សធម៌។ ក្នុងចំណោមអាទិភាពផ្សេងទៀត មាត្រា ១៨ នៃច្បាប់នេះចែងថា ក្នុងករណីដែលមានព្រឹត្តិការណ៍ ឬឧបទ្ទវហេតុកើតឡើង អាជ្ញាធរមានសមត្ថកិច្ចដែលមានទីតាំងនៅតំបន់កើតហេតុ ត្រូវយកចិត្តទុកដាក់ខ្ពស់លើតម្រូវការរបស់ស្ត្រី កុមារ ចាស់ជរា និងជនពិការ និងជនបាត់បង់លទ្ធភាពពលកម្ម[93]។

*ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០២៤-២០២៨* (NAP-DRR) របស់កម្ពុជា ដែលត្រូវបានអនុម័តនៅខែ កក្កដា ឆ្នាំ ២០២៤ បន្សុីគ្នានឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ ក្របខណ្ឌសេនដាយ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ ផែនការនេះលើកឡើងពីគ្រោះមហន្តរាយជាច្រើនប្រភេទដែលបង្កដោយធម្មជាតិ និងមនុស្ស ដូចជា ទឹកជំនន់ ខ្យល់ព្យុះ គ្រាំងរាំងស្ងួត អគ្គីភ័យ និងការបាក់រលំអគារ ដែលគ្រោះមហន្តរាយភាគច្រើនមានកម្រិតកាន់តែធ្ងន់ធ្ងរដោយសារការប្រែប្រួលអាកាសធាតុ។ NAP-DRR គូសបញ្ជាក់ពីគោលដៅយុទ្ធសាស្ត្រចំនួន ៤ និងកម្មវិធីអាទិភាពចំនួន ១៨ ដែលត្រូវបានរៀបចំឡើងដើម្បីពង្រឹងភាពធន់នឹងគ្រោះមហន្តរាយនៅទូទាំងប្រទេសកម្ពុជា។ លទ្ធផលសំខាន់មួយក្នុងចំណោមលទ្ធផលសំខាន់ៗទាំង ៨ នៃផែនការនេះគឺការពង្រឹងការចូលរួមរបស់ភាគីពាក់ព័ន្ធ។

គ្រោះមហន្តរាយ និងគ្រោះអាសន្នផ្សេងទៀត អាចបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅ សន្តិសុខស្បៀង និងលទ្ធភាពទទួលបានសេវា ដោយបានរុញច្រានឱ្យប្រជាជនងាយរងគ្រោះធ្លាក់ចូលកាន់តែជ្រៅក្នុងភាពក្រីក្រ។ *គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន* (ខែ ធ្នូ ឆ្នាំ ២០២៣) មានគោលបំណងពង្រឹងការសម្របសម្រួល និងពង្រីកការគ្របដណ្តប់ដើម្បីគាំទ្រដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ រួមទាំងជនមានពិការភាព ដើម្បីបង្កើនភាពធន់ និងរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ គោលការណ៍ណែនាំនេះ បញ្ជាក់ឡើងវិញពីតួនាទីសំខាន់នៃយន្តការគាំពារសង្គមក្នុងការកាត់បន្ថយផលប៉ះពាល់នៃគ្រោះអាសន្នតាមរយៈការផ្តល់ការគាំទ្រទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។ ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពក្នុងទម្រង់ជាកិច្ចគាំពារសង្គម អាចបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងផ្សេងទៀតរបស់រដ្ឋាភិបាល កាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ និងទ្រទ្រង់ការស្តារឡើងវិញ និងការកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលវែង។ គោលបំណងនៃក្របខណ្ឌនេះគឺដើម្បីផ្តល់ការគាំទ្រជាប្រព័ន្ធ អាចព្យាករណ៍បាន និងមានប្រសិទ្ធភាពដល់គ្រួសារ និងជនក្រីក្រ និងងាយរងគ្រោះក្នុងពេលមានគ្រោះអាសន្ន ប្រើប្រាស់មូលដ្ឋានទិន្នន័យ និងយន្តការផ្តល់សេវាដែលមានស្រាប់ ដើម្បីផ្តល់ការគាំទ្រទាន់ពេលវេលា និងជួយបង្ការ និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធទាំងអស់ដើម្បីលុបបំបាត់គម្លាតប្រសិទ្ធភាព[94]។

## *ឯកសារណែនាំដើម្បីពង្រឹងបរិយាបន្នពិការភាព*

ដើម្បីសម្រេចបានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានបរិយាបន្នពិការភាព (DIDRR) ការចូលរួមរបស់សហគមន៍ទាំងមូល រួមទាំងជនមានពិការភាព គឺសំខាន់ណាស់។ មានលិខិតុបករណ៍អន្តរជាតិមួយចំនួនសម្រាប់ណែនាំដល់ការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាលើ DIDRR៖

- គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (UNESCAP) មានវគ្គសិក្សាអនឡាញចំនួន ២ ដើម្បីពង្រឹងការយល់ដឹងអំពីការដាក់បញ្ចូលទស្សនវិស័យពិការភាពទៅក្នុងគ្រប់

[93] សម្រាប់ព័ត៌មានបន្ថែម សូមមើល Law on Disaster Management, promulgated by Royal Decree NS/RKM/0715/007

[94] Guidelines for National Social Assistance Programme Framework for Emergency Response (available in Khmer only)

ដំណាក់កាលទាំងអស់នៃ DRR រួមទាំងការទប់ស្កាត់ ការត្រៀមបង្ការ ការឆ្លើយតប និងការស្តារឡើងវិញ៖ *ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយប្រកបដោយបរិយាបន្នពិការភាព (DIDRR)៖ វាជាការទទួលខុសត្រូវរបស់យើង* និង *ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយប្រកបដោយបរិយាបន្នពិការភាព (DIDRR)៖ វាជាការទទួលខុសត្រូវរបស់យើង - កម្រិតខ្ពស់*។ វគ្គសិក្សាទាំងនេះត្រូវបានរៀបចំឡើងសម្រាប់អ្នកបង្កើតគោលនយោបាយ និងអ្នកជំនាញ DRR ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ[95]។

- *សេចក្តីណែនាំស្តីពីការស្តារឡើងវិញពីគ្រោះមហន្តរាយប្រកបដោយបរិយាបន្នពិការភាព* ផ្តល់ការណែនាំផ្អែកលើសកម្មភាពសម្រាប់មន្ត្រីរដ្ឋាភិបាល និងអ្នកធ្វើសេចក្តីសម្រេចចិត្តដែលទទួលខុសត្រូវលើការស្តារឡើងវិញ និងការកសាងឡើងវិញក្រោយគ្រោះមហន្តរាយ។ ការណែនាំនេះនឹងជួយឱ្យមានការអភិវឌ្ឍផែនការ និងកម្មវិធីបរិយាបន្នពិការភាពក្នុងវិស័យនានា និងរដ្ឋាភិបាល[96]។
- *ការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយប្រកបដោយបរិយាបន្នពិការភាពទៅក្នុងការអភិវឌ្ឍសហគមន៍ ៖ ការណែនាំសម្រាប់ការរៀបចំផែនការ និងការអនុវត្ត* គូសបញ្ជាក់ពីចំណុចសកម្មភាពចំនួន ២០ សម្រាប់អ្នកអនុវត្តន៍ស្តីពីរបៀបធ្វើឱ្យគំនិតផ្តួចផ្តើមតាមសហគមន៍កាន់តែផ្អែកតាមព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយស្តីពីគ្រោះមហន្តរាយ និងចាប់ផ្តើមបញ្ជ្រាប DIDRR។ ឯកសារណែនាំនេះមានគោលបំណងជំរុញការឆ្លុះបញ្ចាំងនៅដំណាក់កាលជាច្រើន ចាប់ពីការរៀបចំផែនការគម្រោងរហូតដល់ការអនុវត្ត និងការពិនិត្យតាមដាន ដើម្បីធានាថា DIDRR ក្លាយជាផ្នែកសំខាន់មួយនៃកម្មវិធីតាមសហគមន៍ ប្រកបដោយប្រសិទ្ធភាព ការគិតគូរ និងការឆ្លើយតបនឹងតម្រូវការ[97]។

---

[95] *Disability-inclusive Disaster Risk Reduction (DIDRR): It is Our Responsibility* and *Disability-Inclusive Disaster Risk Reduction (DIDRR): It Is Our Responsibility – Advanced*, UNESCAP

[96] *Disability inclusive disaster recovery: Guidance note*, Global Facility for Disaster Reduction and Recovery, 2020

[97] *Mainstreaming Disability Inclusive Disaster Risk Reduction in Community Development: Guidance for Planning and Practice*, CBM, 2023

# ផ្នែកទី ៤ ផ្លូវឆ្ពោះទៅរកការពង្រឹងបរិយាបន្នពិការភាពនៅថ្នាក់ក្រោមជាតិ

ជាមួយនឹងការធ្វើវិមជ្ឈការមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) រួមទាំងក្រុមប្រឹក្សាឃុំ/សង្កាត់ ចាំបាច់ត្រូវធានាថាអង្គភាពទាំងនេះមានគណនេយ្យភាព និងបរិយាបន្ន ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ រួមទាំងជនមានពិការភាព។ ផ្នែកនេះផ្តល់ទិដ្ឋភាពទូទៅនៃផ្លូវឆ្ពោះទៅរកការពង្រឹងបរិយាបន្នពិការភាព តាមរយៈយន្តការសំខាន់ៗ ចំនួន ៨ គឺ ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត (PDAC), ក្រុមប្រឹក្សាឃុំ/សង្កាត់, ដំណើរការកំណត់អត្តសញ្ញាណជនភាពពិការភាព, កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor), កម្មវិធីវិនិយោគឃុំ/សង្កាត់ (CIP), គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់, ការិយាល័យច្រកចេញចូលតែមួយ (One Window Service Offices ) និង បន្ទប់ផ្តល់សេវាចម្រុះ (One-Stop Service Units)។

## ៤.១ ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត

មាត្រា ១៤ នៃអនុក្រឹត្យលេខ ២១៦ ឆ្នាំ ២០១៣ អំពាវនាវឱ្យក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) បង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការនៅគ្រប់រាជធានី/ខេត្តទាំងអស់ (PDAC)។ បន្ទាប់មក ប្រកាសរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ លេខ ០០២ កសជ.ប្រក ចុះថ្ងៃទី ៩ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការនៅថ្នាក់រាជធានី/ខេត្ត រៀបរាប់ពីសមាសភាព និងតួនាទី និងការទទួលខុសត្រូវរបស់ PDAC ដោយបញ្ជាក់ថា PDAC គឺជាយន្តការសម្របសម្រួល និងផ្តល់យោបល់លើបញ្ហាពិការភាពនៅថ្នាក់រាជធានី/ខេត្ត។ សមាជិកភាព PDAC យកលំនាំតាមសមាជិកភាព DAC នៅថ្នាក់ជាតិ ដោយមានតំណាងមកពីមន្ទីរនានា និងរួមបញ្ចូលតំណាងមកពីសង្គមស៊ីវិល អង្គការតំណាងជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាល និងជនមានពិការភាព។ អភិបាលនៃគណៈអភិបាល ?គឺជាប្រធានកិត្តិយស ដោយមានអភិបាលរងជាប្រធាន។ សមាជិកជាក់ស្តែងត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់សាលាក្រុង/សាលាខេត្ត។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត (PoSVY) ដើរតួនាទីសំខាន់ក្នុងនាមជាលេខាធិការដ្ឋាននៅក្នុងសាលាក្រុង/សាលាខេត្ត ដើម្បីគាំទ្រការងាររបស់ PDAC។ ចំណាយរបស់ PDAC ត្រូវបានដាក់បញ្ចូលក្នុងផែនការថវិការបស់សាលាក្រុង/សាលាខេត្ត និងទទួលបានការគាំទ្រពីថវិកាជាតិ។ ការសាកល្បង PDAC ថ្នាក់ស្រុក (DDAC) ត្រូវបានអនុវត្តនៅខេត្តកំពង់ចាម ដោយ DDAC ផ្សេងទៀតនឹងត្រូវបានបង្កើតឡើងនៅគ្រប់ខេត្តទាំងអស់ បន្ទាប់ពីវិសោធនកម្មច្បាប់នៅឆ្នាំ ២០២៥។

តួនាទី និងការទទួលខុសត្រូវចម្បងរបស់ PDAC មានដូចជា ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្មនៅថ្នាក់រាជធានី/ខេត្ត ជួយជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាព និងរៀបចំរបាយការណ៍ស្តីពីស្ថានភាពជនពិការនៅថ្នាក់រាជធានី/ខេត្ត ជូនក្រុមប្រឹក្សាសកម្មភាពជនពិការ។

តាមរយៈអាណត្តិផ្តល់ការពិគ្រោះយោបល់ជំនាញ PDAC ដើរតួនាទីសំខាន់ក្នុងការធានាថាគោលនយោបាយ កម្មវិធី និងសេវាដែលអនុវត្តដោយអង្គភាពរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀតនៅក្នុងខេត្ត មានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។ វគ្គបណ្តុះបណ្តាលជាច្រើនត្រូវបានធ្វើឡើងដើម្បីកសាងសមត្ថភាពរបស់សមាជិក PDAC ក្នុងការបំពេញអាណត្តិរបស់ខ្លួន ប៉ុន្តែបញ្ហាប្រឈមដ៏សំខាន់មួយ គឺមានការផ្លាស់ប្តូរសមាជិកជាញឹកញាប់ ជូនកាលរៀងរាល់ ៦ ខែ ឬរៀងរាល់ឆ្នាំ ដែលនាំឱ្យបាត់បង់សមត្ថភាពក្នុងការផ្តល់ដំបូន្មានសមស្រប នៅពេលចាំបាច់។

អង្គការតំណាងជនមានពិការភាព រួមទាំងវេទិកាស្ត្រីពិការ (WWDFs) អាចរួមចំណែកពង្រឹងបរិយាបន្នពិការភាព តាមរយៈសកម្មភាពលើកកម្ពស់ការយល់ដឹង និងតស៊ូមតិ ដើម្បីធានាថា សមាជិក PDAC យល់ដឹងអំពីសិទ្ធិ និងស្ថានភាព របស់ប្រជាជនដែលមានពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យនៅក្នុងខេត្ត។ បន្ទាប់ពីបានកំណត់រកឧបសគ្គដែលរារាំង ការទទួលបានសេវា និងឱកាសដោយស្មើភាព អង្គការតំណាងជនមានពិការភាពអាចស្នើដំណោះស្រាយ និងជំរុញឱ្យ PDAC ចាត់វិធានការបង្កើនការបង្កលក្ខណៈងាយស្រួល និងបរិយាបន្ន។

## ៤.២ ក្រុមប្រឹក្សាឃុំ/សង្កាត់

ក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវបានបង្កើតឡើងក្រោម *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់*។ ក្រសួងមហាផ្ទៃ (MoI) មានតួនាទីត្រួតពិនិត្យ ទោះបីជាមួយភាគធំ ការទទួលខុសត្រូវនេះត្រូវបានផ្ទេរទៅអភិបាលរាជធានី/ខេត្តក៏ដោយ។ ក្រុមប្រឹក្សាឃុំ/សង្កាត់គឺជាស្ថាប័នដែលត្រូវបានជ្រើសតាំងដើម្បីតំណាង និងបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងឃុំ/សង្កាត់។ នេះជាស្ថាប័នរដ្ឋបាលមូលដ្ឋានចម្បងដែលទទួលខុសត្រូវលើការអនុវត្តគោលនយោបាយ និងកម្មវិធីបែបបរិយាបន្ន ត្រួតពិនិត្យគម្រោងក្នុងមូលដ្ឋាន សម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការតំណាងជនមានពិការភាព និងធានាការចូលរួមរបស់សហគមន៍ រួមទាំងការចូលរួមរបស់ជនមានពិការភាព។ ឃុំ/សង្កាត់សរុបមានចំនួន ១.៦២១ នៅទូទាំងប្រទេសកម្ពុជា។

តួនាទីរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់គឺត្រូវមានគណនេយ្យភាព និងឆ្លើយតបទៅនឹងបញ្ហា និងតម្រូវការរបស់ប្រជាជនគ្រប់រូប ជាពិសេសប្រជាជនដែលងាយរងគ្រោះបំផុត។ ក្រុមប្រឹក្សាឃុំ/សង្កាត់ មួយចំនួនមានជនមានពិការភាពម្នាក់ជាសមាជិកក្រុមប្រឹក្សាដែលត្រូវបានជ្រើសតាំង។

ជនមានពិការភាព និងអង្គការតំណាងជនមានពិការភាព ដើរតួនាទីសំខាន់ក្នុងការធានាថាក្រុមប្រឹក្សាឃុំ/សង្កាត់បានដឹង និងឆ្លើយតបនឹងសិទ្ធិ និងស្ថានភាពរបស់ជនមានពិការភាពនៅក្នុងឃុំ។

## ៤.៣ ដំណើរការកំណត់អត្តសញ្ញាណជនមានពិការភាព

ជនមានពិការភាពអាចបង្កើនលទ្ធភាពផ្ទាល់ខ្លួនក្នុងការទទួលបានសេវា និងឱកាស តាមរយៈការទទួលបានបណ្ណសម្គាល់ជនមានពិការភាព (Disability ID card) ដូចការកំណត់ដោយអនុក្រឹត្យលេខ ២០២ ស្តីពីអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០២៣។

អ្នកដែលមានបណ្ណសម្គាល់ជនមានពិការភាព មានសិទ្ធិទទួលបានសេវា និងការគាំទ្រក្នុងទម្រង់ជាកិច្ចគាំពារសង្គមដោយស្មើភាព ដូចការកំណត់ក្នុងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណពិការភាព។ អត្ថប្រយោជន៍រួមមាន អត្ថប្រយោជន៍គោលនយោបាយដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការកំណត់អត្តសញ្ញាណពិការភាព និងកម្រិតភាពក្រីក្រ អាទិភាពការងារដោយផ្អែកលើប្រព័ន្ធកូតា ឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ ការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈដោយឥតគិតថ្លៃ ការចូលរៀននៅសាលារដ្ឋគ្រប់កម្រិតដោយឥតគិតថ្លៃ ការចេញចូលទីកន្លែងសាធារណៈ ដូចជា រមណីយដ្ឋាន ដោយឥតគិតថ្លៃ ការពិនិត្យសុខភាព និងសេវាស្តារលទ្ធភាពពលកម្មនៅមូលដ្ឋានសុខាភិបាលសាធារណៈដោយឥតគិតថ្លៃ ការចូលរួមក្នុងសកម្មភាពសិល្បៈ កីឡា និងវប្បធម៌ថ្នាក់ជាតិ និងអន្តរជាតិ ការលើកលែងពន្ធអនុលោមតាមច្បាប់ ការសម្រួលដល់ការធ្វើដំណើរទាំងក្នុង និងក្រៅប្រទេស និងការទទួលបានសេវាផ្សេងទៀតដែលអាចមានផ្តល់[98]។

អង្គការតំណាងជនមានពិការភាព ដើរតួនាទីសំខាន់ក្នុងការធានាថា ជនមានពិការភាពនៅក្នុងតំបន់គោលដៅរបស់ពួកគេយល់ដឹងអំពីដំណើរការ ភាគីពាក់ព័ន្ធសំខាន់ៗ និងអត្ថប្រយោជន៍នៃការទទួលបានបណ្ណសម្គាល់ជនមានពិការភាព។ ដំណើរការនេះមាន ៧ ជំហាន៖

១. **ការរៀបចំផែនការប្រមូលទិន្នន័យកំណត់អត្តសញ្ញាណពិការភាព៖** កិច្ចប្រជុំរវាងមេឃុំ/ចៅសង្កាត់ និងមេភូមិ ដើម្បីណែនាំអំពីដំណើរការ។

[98] សម្រាប់ព័ត៌មានបន្ថែម សូមមើល Guideline on Social and Rights-Based Disability Identification, August 2020

២. **ការរៀបចំទិន្នន័យពិការភាពទូទៅ៖** មេភូមិប្រមូល ឬធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីជនមានពិការភាព។
៣. **បទសម្ភាសន៍ដែលធ្វើឡើងដោយជនបង្គោលឃុំ/សង្កាត់៖** ទិន្នន័យត្រូវបានប្រមូល និងបញ្ចូលទៅក្នុងកម្មវិធីទូរស័ព្ទចល័ត ដោយប្រើកម្រងសំណួរស្តង់ដារ។
៤. **ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់ដោយមេឃុំ/ចៅសង្កាត់ និងបញ្ជូនទៅមន្ទីររាជធានី/ខេត្ត៖** ទិន្នន័យត្រូវបានពិនិត្យឡើងវិញ និងផ្ទៀងផ្ទាត់។
៥. **ការកំណត់អត្តសញ្ញាណពិការភាពដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ក្រសួងដំណើរការទិន្នន័យ និងវាយតម្លៃកម្រិតពិការភាព។
៦. **ការផ្តល់បណ្ណសម្គាល់ជនពិការមានភាព៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បោះពុម្ព និងចែកបណ្ណសម្គាល់ជនមានពិការភាពទៅថ្នាក់ក្រោមជាតិ។
៧. **ការចែកបណ្ណសម្គាល់ជនមានពិការភាព៖** បណ្ណសម្គាល់ត្រូវបានចែកជូនដោយរដ្ឋបាលឃុំ/សង្កាត់។

**ដំណើរការកំណត់អត្តសញ្ញាណជនមានពិការភាព**



ភាគីពាក់ព័ន្ធសំខាន់ៗដែលចូលរួមក្នុងដំណើរការកំណត់អត្តសញ្ញាណពិការភាព រួមមាន៖

- ក្រសួង ស.អ.យ ដែលត្រួតពិនិត្យដំណើរការកំណត់អត្តសញ្ញាណពិការភាពទាំងមូល និងទទួលខុសត្រូវលើការផ្តល់បណ្ណសម្គាល់ជនមានពិការភាព
- ក្រុមការងារបច្ចេកទេសអន្តរក្រសួង ដែលមានសមាសភាពតំណាងមកពីក្រសួង ស.អ.យ (ប្រធាន) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រុមប្រឹក្សាជាតិគាំពារសង្គម (NSPC) និង DAC ដើម្បីផ្តល់ការណែនាំគោលនយោបាយ ពិនិត្យតាមដាន និងដោះស្រាយបញ្ហាប្រឈមក្នុងការកំណត់អត្តសញ្ញាណពិការភាព
- រដ្ឋបាលរាជធានី/ខេត្ត ដែលសម្របសម្រួលជាមួយមន្ទីរតាមខេត្ត និងគាំទ្រដំណើរការកំណត់អត្តសញ្ញាណពិការភាពនៅថ្នាក់មូលដ្ឋាន និងផ្តល់ការគាំទ្របច្ចេកទេសដល់ជនបង្គោល និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី/ខេត្ត ដែលចាត់តាំងជនបង្គោលសម្រាប់ដំណើរការកំណត់អត្តសញ្ញាណពិការភាព និងផ្ទៀងផ្ទាត់ និងអនុម័តទិន្នន័យពិការភាព និងគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាពិការភាពនៅថ្នាក់ខេត្ត
- រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ដែលគាំទ្រការអនុវត្តការកំណត់អត្តសញ្ញាណពិការភាពនៅថ្នាក់ស្រុក ផ្តល់ការកសាងសមត្ថភាពដល់ជនបង្គោលឃុំ/សង្កាត់ និងតាមដានវឌ្ឍនភាព
- រដ្ឋបាលឃុំ/សង្កាត់ ដែលទទួលខុសត្រូវលើការប្រមូលទិន្នន័យពិការភាពនៅថ្នាក់ភូមិ និងរៀបចំការប្រមូលទិន្នន័យ ការសម្ភាសន៍ជនមានពិការភាព និងការបញ្ជូនទិន្នន័យទៅថ្នាក់លើ
- មេភូមិ ដែលជួយដល់ការប្រមូលទិន្នន័យពិការភាពទូទៅ និងសម្របសម្រួលបទសម្ភាសន៍ជាមួយជនមានពិការភាព
- ជនមានពិការភាព និងគ្រួសារ/អាណាព្យាបាលរបស់ពួកគេ ដែលចូលរួមក្នុងការប្រមូលទិន្នន័យ និងដំណើរការកំណត់អត្តសញ្ញាណ ដើម្បីធានាការបង្ហាញព័ត៌មានត្រឹមត្រូវ។

## ៤.៤ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ព័ត៌មានដែល *កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor)* របស់ក្រសួងផែនការប្រមូល ស្តីពីគ្រួសារក្រីក្រ ដើរតួនាទីជាប្រភពទិន្នន័យចម្បងសម្រាប់អន្តរាគមន៍ជំនួយសង្គមជាច្រើននៅកម្ពុជា រួមទាំងកម្មវិធីកញ្ចប់គ្រួសារ។ នីតិវិធីអនុវត្តន៍កម្មវិធី IDPoor រួមមានការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ការធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីគ្រួសារក្រីក្រដោយដកគ្រួសារចេញពីបញ្ជីគ្រួសារក្រីក្រ ឬការកែប្រែព័ត៌មានស្តីពីគ្រួសារមានបណ្ណសមធម៌ដែលមានសុពលភាព។ យន្តការដើម្បីអនុវត្តកម្មវិធីនេះត្រូវបានបង្កើតឡើងនៅថ្នាក់ខេត្ត ឃុំ/សង្កាត់ និងភូមិ[99]។

គណៈកម្មាធិការខេត្តសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ត្រូវបានបង្កើតឡើងដើម្បីសម្រួល និងគាំទ្រដល់ការអនុវត្តនីតិវិធីកំណត់អត្តសញ្ញាណដោយជោគជ័យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អភិបាលខេត្តគឺជាប្រធាន ដោយមានប្រធានមន្ទីរពាក់ព័ន្ធ និងអភិបាលស្រុក/ខណ្ឌជាសមាជិក។ តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល អាចស្ម័គ្រចិត្តចូលរួមក្នុងការងាររបស់គណៈកម្មាធិការនេះ។ គណៈកម្មាធិការនីមួយៗមានលេខាធិការដ្ឋានមួយ។

ក្រុមការងារឃុំ/សង្កាត់សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងជនងាយរងគ្រោះ (C/SWG) មានសមាសភាពមេឃុំ/ចៅសង្កាត់ និងសមាជិកក្រុមប្រឹក្សា ២-៣ នាក់ អាស្រ័យលើចំនួនភូមិក្នុងឃុំ/សង្កាត់។ C/SWGs គាំទ្រដោយអ្នកសម្របសម្រួលបច្ចេកទេស។ ក្នុងចំណោមការទទួលខុសត្រូវផ្សេងទៀត តួនាទីរបស់ C/SWGs រួមមាន ៖

- ជួយក្រុមប្រឹក្សាឃុំ/សង្កាត់ អនុវត្តកម្មវិធីនៅក្នុងឃុំ/សង្កាត់
- ដំណើរការសំណើសុំបទសម្ភាសន៍ដែលបានទទួល បន្ទាប់មកសម្រេចថាតើគ្រួសារណាដែលគួរត្រូវបានសម្ភាស

[99] សម្រាប់ព័ត៌មានបន្ថែម សូមមើល *Manual for the Identification of Poor Households Procedure*, MoP, 2022។ សូមមើលផងដែរ *https://idpoor.gov.kh/en/about/*។

- ចុះសម្ភាសគ្រួសារតាមទីលំនៅ
- បង្ហាញលទ្ធផលដែលបានពីការសម្ភាសន៍គ្រួសារជូនអង្គប្រជុំក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីពិនិត្យ និងអនុម័តចំណាត់ថ្នាក់គ្រួសារក្រីក្រ
- សម្របសម្រួលជាមួយមេភូមិដើម្បីចែកបណ្ណសមធម៌។

ក្រុមការងារភូមិ (VWG) ដែលរួមមានមេភូមិ មេភូមិរង និងជំនួយការភូមិ គាំទ្រការងាររបស់ C/SWG។ ក្នុងចំណោមការទទួលខុសត្រូវផ្សេងទៀត តួនាទីរបស់ VWGs រួមមាន ៖

- លើកកម្ពស់ការយល់ដឹងក្នុងសហគមន៍អំពីដំណើរការនេះ
- ជួយគ្រួសារក្នុងការបំពេញពាក្យស្នើសុំសម្ភាសន៍ បន្ទាប់មកបញ្ជូនសំណើទៅ C/SWG
- ផ្តល់ព័ត៌មានដល់ C/SWG អំពីគ្រួសារដែលសង្ស័យថាក្រីក្រ ប៉ុន្តែមិនមានឈ្មោះនៅក្នុងបញ្ជីគ្រួសារក្រីក្រ
- ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីផ្តល់ព័ត៌មានអំពីស្ថានភាពរស់នៅរបស់គ្រួសារដែលបានដាក់ពាក្យស្នើសុំសម្ភាសន៍
- ជួយដល់ C/SWG ក្នុងការរៀបចំការសម្ភាសន៍គ្រួសារនៅក្នុងភូមិ
- ផ្តល់ដំបូន្មានដល់គ្រួសារអំពីលទ្ធផលនៃសំណើរបស់ពួកគេ
- ចែកបណ្ណសមធម៌ដល់គ្រួសារក្រីក្រដែលមានសិទ្ធិទទួលបាន។

គ្រួសារដែលគិតថា ពួកគេជាគ្រួសារក្រីក្រ មានជម្រើស ៣ សម្រាប់ការដាក់ពាក្យស្នើសុំការសម្ភាសន៍៖ ដាក់សំណើដោយផ្ទាល់ទៅ C/SWG ដាក់សំណើដោយផ្ទាល់ទៅមេភូមិ ឬតួអង្គផ្សេងទៀតដែលនឹងដាក់សំណើទាំងនេះទៅ C/SWG ឬដាក់សំណើតាមរយៈកម្មវិធី IDPoor។ កម្មវិធី IDPoor គឺជាកម្មវិធីក្នុងទូរស័ព្ទចល័តដែលអាចរកបានជាសាធារណៈ ដែលនរណាក៏អាចទាញយក និងដំឡើងនៅលើឧបករណ៍ Android របស់ពួកគេ។

**សេចក្តីសង្ខេបនៃនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor)**[100]

**ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ**

**ដំណើរការផ្តល់បណ្ណសមធម៌**
- **ជំហានទី១៖** ការដាក់ពាក្យ និងទទួលពាក្យស្នើសុំសម្ភាសន៍
- **ជំហានទី២៖** ក្រុមការងារឃុំ សង្កាត់ពិនិត្យ និងសម្រេចលើពាក្យស្នើសុំសម្ភាសន៍
- **ជំហានទី៣៖** ក្រុមការងារឃុំ សង្កាត់ចុះសម្ភាសន៍គ្រួសារដោយប្រើឧបករណ៍ថាប្លែត
- **ជំហានទី៤៖** ក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័តចំណាត់ថ្នាក់គ្រួសារក្រីក្រ
- **ជំហានទី៥៖** ការផលិត បោះពុម្ព និង ផ្តល់បណ្ណសមធម៌

**ការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ**

**ការដកគ្រួសារចេញពីបញ្ជី**
- **ជំហានទី១៖** ការដាក់ពាក្យ និងទទួលពាក្យ ស្នើសុំដកគ្រួសារ
- **ជំហានទី២៖** ក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និង សម្រេចលើពាក្យស្នើសុំដកគ្រួសារ
- ដកគ្រួសារចេញតាមសំណើ ធ្វើការសម្ភាសន៍ ឡើងវិញ ឬបដិសេធពាក្យស្នើសុំដកគ្រួសារ
- **ករណីសម្ភាសន៍ឡើងវិញ៖** ត្រូវអនុវត្តន៍ដូចជំហាន ទី៣ និងទី៤ ក្នុងដំណើរផ្តល់បណ្ណសមធម៌

**ការកែសម្រួលព័ត៌មានលម្អិត**
- **ជំហានទី១៖** ការដាក់ពាក្យ និងទទួលពាក្យស្នើសុំកែសម្រួលព័ត៌មាន
- **ជំហានទី២៖** ក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និង សម្រេចលើពាក្យស្នើសុំកែសម្រួលព័ត៌មាន
- **ករណីកែសម្រួលព័ត៌មានមេគ្រួសារ៖** ត្រូវប្តូរបណ្ណសមធម៌ថ្មី

[100] Manual for the Identification of Poor Households Procedure, 17

អង្គការតំណាងជនមានពិការភាព ដើរតួនាទីសំខាន់ក្នុងការធានាថា C/SWGs និង VWGs ដឹងអំពីស្ថានភាពរបស់ជនមានពិការភាព និងគ្រួសាររបស់ពួកគេ និងសិទ្ធិរបស់គ្រួសារដែលមានសិទ្ធិទទួលបានជំនួយសង្គម ធានាថាជនមានពិការភាព និងគ្រួសាររបស់ពួកគេដែលមានសិទ្ធិទទួលមានបណ្ណសមធម៌ លើកកម្ពស់ការយល់ដឹងក្នុងចំណោមសមាជិកស្តីពីកម្មវិធីកញ្ចប់គ្រួសារ និងបញ្ជូនជនមានពិការភាពទៅការិយាល័យ ម.ជ.ជ (NSAF) ដើម្បីទាមទារសិទ្ធិរបស់ពួកគេក្នុងការទទួលបានកិច្ចគាំពារសង្គម។

## ៤.៥ កម្មវិធីវិនិយោគឃុំ/សង្កាត់

ដំណើរការកសាងកម្មវិធីវិនិយោគឃុំ/សង្កាត់ (CIP) ផ្តល់មធ្យោបាយមួយសម្រាប់ការពង្រឹងបរិយាបន្នពិការភាពនៅថ្នាក់ក្រោមជាតិ។ រាជរដ្ឋាភិបាលកម្ពុជាវិភាជថវិកាជាតិ ១ ភាគរយទៅឱ្យឃុំ/សង្កាត់នីមួយៗជារៀងរាល់ឆ្នាំដោយផ្អែកលើ*ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់*[101]។ វិភាជថវិកាជាតិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងរាជធានី ខេត្ត/ក្រុង ខណ្ឌ/ស្រុក និងឃុំ/សង្កាត់ មានការកើនឡើងជាលំដាប់ ដោយកើនពី ១៣ ភាគរយនៅឆ្នាំ ២០២៣ ដល់ ១៩ ភាគរយនៅឆ្នាំ ២០២៤។ ទោះយ៉ាងណា ចំណែកភាគរយនៃថវិកាជាតិនៅតែទាបខ្លាំងបើធៀបនឹងចំណាយរបស់រដ្ឋាភិបាលថ្នាក់កណ្តាល ដែលស្មើនឹង ៨១ ភាគរយនៃចំណាយនៅឆ្នាំ ២០២៤[102]។ ចំណាយរបស់ឃុំ/សង្កាត់នៅឆ្នាំ ២០២៤ ស្មើនឹង ៣,១០ ភាគរយនៃថវិកាជាតិ។

**% ចំណាយសម្រាប់រដ្ឋបាលខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ក្នុងឆ្នាំ ២០២៤**




មានមូលនិធិឃុំ/សង្កាត់ ២ ប្រភេទដើម្បីគាំទ្រប្រតិបត្តិការ គឺមូលនិធិរដ្ឋបាល និងមូលនិធិអភិវឌ្ឍន៍។ មូលនិធិអភិវឌ្ឍន៍ត្រូវបានប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងកម្មវិធីវិនិយោគឃុំ/សង្កាត់ (CIP) ៣ ឆ្នាំរំកិល។ ជាមធ្យម មូលនិធិ CIP មានចំនួន ៤០.០០០.០០០ រៀល (ប្រហែល ១០.០០០ ដុល្លារអាមេរិក) ក្នុងមួយឆ្នាំសម្រាប់ឃុំនីមួយៗ។ CIP មានសមាសភាព ៤ គឺសេដ្ឋកិច្ច សង្គមកិច្ច រដ្ឋបាល និងសន្តិសុខ និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។

ដំណើរការប្រចាំឆ្នាំនៃការរៀបចំ CIP មាន ៥ ដំណាក់កាលសំខាន់ៗ គឺការកំណត់បញ្ហា/តម្រូវការ ការរៀបចំគម្រោង/កម្មវិធី ការកៀរគរធនធានតាមរយៈសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ការអនុម័ត និងការឯកភាពលើ CIP និងការអនុវត្ត/ការពិនិត្យតាមដាន និងវាយតម្លៃ។ ដំណាក់កាលទីមួយ និងទីពីរ (ការកំណត់បញ្ហា/តម្រូវការ និងការរៀបចំគម្រោង) គឺជាចំណុចចាប់ផ្តើមដ៏សំខាន់សម្រាប់ការបញ្ចូលបរិយាបន្នពិការភាពទៅក្នុងសមាសភាគសង្គមកិច្ចរបស់ CIP។

---

101 *Law on the Administration and Management of Communes/Sangkats*

102 Optimizing Financial Management and Budget Planning for the Next Fiscal Year, Transparency International Cambodia, 2024; see also, https://www.cambodianbudget.org/

អង្គការតំណាងជនមានពិការភាព វេទិកាស្ត្រីពិការ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដើរតួនាទីសំខាន់ក្នុងការកំណត់រកបញ្ហាពិការភាព និងតស៊ូមតិឱ្យមានផ្តល់ធនធានឃុំ/សង្កាត់ដើម្បីគាំទ្រសកម្មភាពដោះស្រាយបញ្ហាប្រឈមៗ។ ប្រសិនបើដំណាក់កាលទាំងនេះត្រូវបានខកខាន ការចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកនឹងផ្តល់ឱកាសមួយទៀតសម្រាប់ការពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍លើការដាក់បញ្ចូលបញ្ហាពិការភាពទៅក្នុងអាទិភាពឃុំដែលបានស្នើឡើង។ គម្រោងជាច្រើនដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល ប្រើប្រាស់ដំណើរការ CIP ជាចំណុចចាប់ផ្តើមដើម្បីដាក់បញ្ចូលសកម្មភាពរបស់ពួកគេទៅក្នុងដំណើរការរៀបចំផែនការ និងថវិកានៅមូលដ្ឋាន។ ការបង្កើនបរិយាបន្នពិការភាពប្រកបដោយប្រព័ន្ធ និងប្រសិទ្ធភាព ទាមទារការទាញយកប្រយោជន៍ពី CIP សម្រាប់ជាផ្នែកមួយនៃកម្មវិធីហិរញ្ញប្បទាន ដែលមានន័យថាជាការផ្លាស់ប្តូរការយល់ឃើញ និងឥរិយាបថជាទូទៅចំពោះពិការភាពនៅក្នុងដំណើរការ CIP។




ដំណើរការ CIP ដែលមានបរិយាបន្ននឹងធានាថា គម្រោងដែលមានស្រាប់នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ (CDP) និងកម្មវិធីវិនិយោគរួមបញ្ចូលជនមានពិការភាព អ្នកធ្វើសេចក្តីសម្រេចយល់ពីសារៈសំខាន់នៃបរិយាបន្នពិការភាពក្នុងការរៀបចំផែនការឃុំ/សង្កាត់ ពិចារណាលើការលុបបំបាត់ឧបសគ្គរាំងការបរិយាបន្ន ហើយជនមានពិការភាពចូលរួមក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការអភិវឌ្ឍ ការអនុវត្ត និងការពិនិត្យតាមដានគម្រោងឃុំ/សង្កាត់ទាំងអស់។

ការណែនាំសេចក្តីលម្អិតអំពីបរិយាបន្នពិការភាពក្នុងដំណើរការ CIP មានបង្ហាញក្នុង *សៀវភៅណែនាំសម្រាប់គ្រូបង្គោលស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៦* ដែលមានគោលបំណងអប់រំមេឃុំ/ចៅសង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ស្មៀន គណៈកម្មការ និងមេភូមិអំពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចតាមមូលដ្ឋាន[103]។ សៀវភៅណែនាំនេះគ្របដណ្តប់លើប្រធានបទ ដូចជា ការយល់ដឹងអំពីពិការភាព ការគោរព និងសេចក្តីថ្លៃថ្នូរ ទំនាក់ទំនង ជំហានអនុវត្តន៍សម្រាប់ការបង្កើតបរិស្ថានគ្មានឧបសគ្គ ការធានាការចូលរួមយ៉ាងសកម្មរបស់ជនមានពិការភាព និងការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការរៀបចំផែនការ។

[103] Handbook for Trainers on Incorporating Disabilities into Government in Sub-National Administration, UNICEF and Ministry of Interior, 2016

ក្រៅពីនេះ ក៏មានការណែនាំនៅក្នុង*ឯកសារស្ដីពីការរៀបចំ និងបង្កើតផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់សម្រាប់ទាំងអស់គ្នាឆ្នាំ ២០២០* ដែលមានគោលបំណងផ្ដល់ទិសដៅដល់អង្គការតំណាងជនមានពិការភាព និងក្រុមប្រឹក្សាឃុំ/សង្កាត់អំពីដំណើរការនៃការរៀបចំ CDP និង CIP ប្រកបដោយបរិយាបន្ន និងសមធម៌[104]។ ឯកសារណែនាំនេះអាចជួយលើកកម្ពស់អភិបាលកិច្ចល្អ និងគណនេយ្យភាព និងផ្ដល់ឱកាសឱ្យជនមានពិការភាពចូលរួមក្នុងដំណើរការអភិវឌ្ឍន៍សង្គម។

## ៤.៦ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (CCWC) គឺជានិតិបុគ្គលផ្លូវការតែមួយគត់នៅថ្នាក់ឃុំ/សង្កាត់ ដែលទទួលខុសត្រូវលើសេវាសង្គមសម្រាប់ស្ត្រី និងកុមារ។ CCWCs ដើរតួនាទីសំខាន់ក្នុងអភិបាលកិច្ចមូលដ្ឋាន និងធ្វើប្រតិបត្តិការក្នុងក្របខណ្ឌទូលំទូលាយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់កម្ពុជា ដែលមានគោលបំណងផ្ដល់សិទ្ធិអំណាចដល់អាជ្ញាធរមូលដ្ឋានក្នុងការបំពេញតម្រូវការជាក់លាក់របស់សហគមន៍ពួកគេ។ CCWCs ដើរតួនាទីសំខាន់ក្នុងការតស៊ូមតិដើម្បីសិទ្ធិ និងតម្រូវការរបស់ស្ត្រី និងកុមារ និងការគាំទ្រការអនុវត្តផែនការសកម្មភាពដែលមានគោលបំណងបង្កើនសមភាពយេនឌ័រ និងការគាំទ្រដល់កុមារ។

នៅខែ កញ្ញា ឆ្នាំ ២០២០ ក្រសួងមហាផ្ទៃបានចេញប្រកាសលេខ ៣៨៤០ ដើម្បីកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់ CCWCs។ ប្រកាសនេះបានពង្រីកអាណត្តិរបស់ CCWCs តាមរយៈការពង្រីកសមាជិកភាព និងការពង្រឹងសិទ្ធិអំណាចផ្ដល់យោបល់របស់ពួកគេ ដោយធ្វើឱ្យពួកគេទទួលខុសត្រូវលើសេវាសង្គមជាច្រើនប្រភេទ។ រចនាសម្ព័ន្ធថ្មីនេះរួមបញ្ចូលតំណាងដែលមានជំនាញលើបញ្ហាទាក់ទងនឹងស្ត្រី កុមារ ការអប់រំ សុខភាព អាហារូបត្ថម្ភ យុវជន កិច្ចគាំពារសង្គម ពិការភាព និងបញ្ហាជនជាតិដើមភាគតិច។ ប្រកាសនេះបានចែងថា សមាជិក CCWC ត្រូវមានស្ត្រីមានពិការភាពម្នាក់[105]។

ការទទួលខុសត្រូវរបស់ CCWCs រួមមានការតស៊ូមតិ និងការអនុវត្តគោលនយោបាយ និងការធានាថាសំឡេងរបស់ស្ត្រី និងកុមារត្រូវបានដាក់បញ្ចូលក្នុងសេចក្ដីសម្រេចលើអភិបាលកិច្ចតាមមូលដ្ឋាន។ CCWCs ក៏ទទួលខុសត្រូវផងដែរលើការត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពទាក់ទងនឹងសុខុមាលភាពស្ត្រី និងកុមារនៅថ្នាក់ឃុំ ដែលគ្របដណ្ដប់លើវិស័យនានា ដូចជា សុខភាព ការអប់រំ និងកិច្ចគាំពារសង្គម[106]។




សមាជិក CCWC ចុះសួរសុខទុក្ខគ្រួសារដើម្បីកំណត់រកបញ្ហាប្រឈម/តម្រូវការក្នុងសហគមន៍។ CCWCs ក៏ផ្ដោតលើការកសាងសមត្ថភាព និងការបង្កើនភាពអង់អាច ដោយរៀបចំវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាដើម្បីពង្រឹងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ អ្នកនាំសហគមន៍ និងអ្នកផ្ដល់សេវាមូលដ្ឋានលើបញ្ហាទាក់ទងនឹងស្ត្រី និងកុមារផងដែរ[107]។ សមាជិក CCWC ចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំផែនការ CDP និង CIP ដើម្បីធានាការតម្កល់តម្រូវការរបស់ស្ត្រី និងកុមារជាអាទិភាព។

---

104 Preparation and Development of Commune Development Plans for All, CDPO and LFTW, December 2020

105 សម្រាប់ព័ត៌មានបន្ថែម សូមមើល Ministry of Interior Prakas #3840 prk, Amendment of Structure, Roles, and Responsibilities of CCWC, 22 September 2020

106 សម្រាប់ព័ត៌មានបន្ថែម សូមមើល Support for Decentralization and Deconcentration Reforms in Cambodia, UNDP, 2019

107 Capacity Building for Local Governance in Cambodia, World Bank, 2020

ប្រភព៖ សៀវភៅណែនាំសម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (CCWC)

CCWCs ជាចំណុចចាប់ផ្តើមដ៏សំខាន់មួយសម្រាប់វេទិកាស្ត្រីពិការ និងអង្គការតំណាងជនមានពិការភាពផ្សេងទៀត និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយ និងដើម្បីជនមានពិការភាព ដើម្បីសហការ និងលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងស្ត្រី និងកុមារមានពិការភាព សម្រាប់ការពិចារណាក្នុងការងាររបស់ CCWC ការអភិវឌ្ឍ CIP និងវេទិកាផ្សេងទៀត និងដើម្បីពង្រឹងបរិយាបន្នពិការភាព។

## ៤.៧ ការិយាល័យច្រកចេញចូលតែមួយ

គំនិតផ្តួចផ្តើមការិយាល័យច្រកចេញចូលតែមួយ (OWSO) ត្រូវបានដាក់ចេញជាលើកដំបូងនៅកម្ពុជាក្នុងឆ្នាំ ២០០៣។ ចាប់តាំងពីពេលនោះមកក៏មានការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅគ្រប់ខេត្តទាំងអស់ ហើយក៏កំពុងត្រូវបានសាកល្បងនៅថ្នាក់ស្រុក និងឃុំផងដែរ។ OWSO គឺជា ប្រព័ន្ធផ្តល់សេវារដ្ឋបាលបែបវិមជ្ឈការ ដែលត្រូវបានរៀបចំឡើង ដើម្បីឱ្យសេវារដ្ឋាភិបាលកាន់តែខិតជិតប្រជាពលរដ្ឋ តាមរយៈ ការធ្វើឱ្យដំណើរការរដ្ឋបាលមានភាពសាមញ្ញ។ OWSO មានគោលបំណងបង្កើនតម្លាភាព និងការបង្កលក្ខណៈងាយស្រួល តាមរយៈ ការផ្តល់សេវាស្តង់ដារ ក្នុងបរិយាកាសដែលបង្កភាពងាយស្រួល។ OWSO ផ្តល់នូវចំណុចទំនាក់ទំនងតែមួយ សម្រាប់សេវាសាធារណៈផ្សេងៗដែលពាក់ព័ន្ធនឹងជនមានពិការភាព ដូចជា ការសម្រួលដល់ការដាក់ពាក្យស្នើសុំអត្ថប្រយោជន៍សង្គម និងកម្មវិធីសុខុមាលភាព និងការចេញឯកសារទាក់ទងនឹងសុខភាព[108]។




ដើម្បីធានាថាសេវាបង្កលក្ខណៈងាយស្រួល និងមានបរិយាបន្ន ចាំបាច់ត្រូវផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកអំពីសិទ្ធិរបស់ជនមានពិការភាព និងកសាងសមត្ថភាពក្នុងការធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយអ្នកដែលមានប្រភេទពិការភាពផ្សេងៗ។

## ៤.៨ បន្ទប់ផ្តល់សេវាចម្រុះ

ក្រោមកិច្ចសហការជាមួយក្រសួងសុខាភិបាល ក្រសួងកិច្ចការនារីកំពុងដំណើរការបង្កើត និងអនុវត្តសាកល្បងបន្ទប់ផ្តល់សេវាចម្រុះ (OSSU) សម្រាប់ជនរងគ្រោះដោយសារពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងស្ត្រី និងកុមារមានពិការភាព[109]។ ការសាកល្បង OSSU ត្រូវបានបង្កើតឡើងក្នុងមន្ទីរពេទ្យបង្អែកនៅខេត្តបាត់ដំបង កំពង់ចាម រាជធានីភ្នំពេញ ព្រះវិហារ ស្ទឹងត្រែង និងត្បូងឃ្មុំ។ OSSU បំពេញបន្ថែមលើក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលមានស្រាប់នៅតាមខេត្តមួយចំនួន ដើម្បីធានាការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាដល់ជនរងគ្រោះដោយសារពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ មន្ទីរកិច្ចការ នារីខេត្ត និងទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធផ្សេងទៀត ដើរតួនាទីសំខាន់ក្នុងការសម្រួលដល់ការទទួលបានសេវា ក៏ដូចជាភាពរលូននៃប្រតិបត្តិការរបស់ OSSU។ បន្ថែមលើការព្យាបាលវេជ្ជសាស្ត្រ ជនរងគ្រោះដោយសារពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបញ្ជូនទៅរកសេវាចាំបាច់ផ្សេងទៀត រួមទាំងការប្រឹក្សាយោបល់មូលដ្ឋាន ជម្រកសុវត្ថិភាពបណ្តោះអាសន្ន សេវានគរបាល និងតុលាការ ប្រសិនបើចាំបាច់[110]។

---

[108] សម្រាប់ព័ត៌មានបន្ថែម សូមមើល https://www.owso.gov.kh/en/ (Khmer only)

[109] បន្ទប់ផ្តល់សេវាចម្រុះ ត្រូវបានស្នើឡើងក្នុង NAPVAW ២០១៩-២០២៣។

[110] សម្រាប់ព័ត៌មានបន្ថែម សូមមើល Guideline on the process of establishing One-Stop Service Center for survivors of gender-based violence,

OSSU ផ្តល់ឱកាសឱ្យវេទិកាស្ត្រីពិការ និងអង្គការតំណាងជនមានពិការភាពផ្សេងទៀតលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ស្ត្រី និងក្មេងស្រីមានពិការភាព ដែលទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងតស៊ូមតិឱ្យមានការរួមបញ្ចូលពួកគេទៅក្នុងសេវា និងការបញ្ជូនដែលមានផ្តល់ ដោយស្មើភាពជាមួយអ្នកដទៃ។ បរិយាបន្នប្រកបដោយប្រសិទ្ធភាព អាចទាមទារឱ្យមានការផ្តល់ការបណ្តុះបណ្តាលដល់អ្នកផ្តល់សេវាពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងរបៀបទំនាក់ទំនងជាមួយស្ត្រី និងក្មេងស្រីមានពិការភាព ដើម្បីធានាថាពួកគេត្រូវបានប្រព្រឹត្តចំពោះប្រកបដោយសេចក្តីថ្លៃថ្នូរ និងការគោរព។

**សេវាបញ្ជូនដែលមានផ្តល់នៅ OSSU ក្រោមការសម្របសម្រួលពីអ្នកគ្រប់គ្រងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ**




MoWA, 2022

# ផ្នែកទី ៥ សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់

## ៥.១ សេចក្តីសន្និដ្ឋាន

ទន្ទឹមនឹងវឌ្ឍនភាពដែលយើងទទួលបាន ជនមានពិការភាពគ្រប់ប្រភេទ និងគ្រប់វ័យ នៅតែប្រឈមនឹងឧបសគ្គជាច្រើនក្នុងការទទួលបានសេវា និងឱកាសដែលនឹងលើកកម្ពស់សុខុមាលភាព និងសមត្ថភាពរបស់ពួកគេក្នុងការចូលរួមយ៉ាងពេញលេញក្នុងសហគមន៍របស់ពួកគេ។ ឧបសគ្គទាំងនេះរួមមាន៖

- ជនមានពិការភាពច្រើនតែប្រឈមនឹងការមាក់ងាយ និងការរើសអើងដោយសារការយល់ឃើញអវិជ្ជមានចំពោះពិការភាព
- ឧបសគ្គរូបវន្ត ឧបសគ្គទំនាក់ទំនង ឧបសគ្គហិរញ្ញវត្ថុ និងឥរិយាបថដែលកម្រិតលទ្ធភាពទទួលបានសេវា និងឱកាស
- ការយល់ដឹងមានកម្រិតអំពីអត្ថន័យនៃបរិយាបន្នពិការភាព ឬរបៀបសម្រេចបានបរិយាបន្នប្រកបដោយអត្ថន័យ និងលទ្ធភាពស្មើភាពក្នុងការទទួលបានសេវា និងឱកាសនៅក្នុងផែនការការងារ ថវិកា និងសកម្មភាពទូលំទូលាយ
- កង្វះការយល់ដឹងអំពីអត្ថន័យនៃអភិក្រមផ្អែកលើសិទ្ធិ និងបរិយាបន្នពិការភាពក្នុងចំណោមគ្រួសារជនមានពិការភាព សហគមន៍របស់ពួកគេ អ្នកផ្តល់សេវា និងអាជ្ញាធរមូលដ្ឋាន
- កង្វះវិភាជថវិកាជាតិដើម្បីអនុវត្តអភិក្រមផ្អែកលើសិទ្ធិក្នុងការពង្រឹងបរិយាបន្នពិការភាព និងលទ្ធភាពទទួលបានសេវា និងឱកាសដោយស្មើភាព និង
- ជនមានពិការភាពជាច្រើន អាចមិនយល់ច្បាស់អំពីសិទ្ធិរបស់ពួកគេ ឬរបៀបទាមទារសិទ្ធិរបស់ពួកគេ។

កម្ពុជាមានក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយដែលនៅពេលអនុវត្តបានពេញលេញ អាចជួយលើកកម្ពស់បរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព។ វគ្គបណ្តុះបណ្តាលជាច្រើនត្រូវបានធ្វើឡើងនៅគ្រប់កម្រិតស្តីពីសិទ្ធិជនមានពិការភាព និងបរិយាបន្ន ក្រោមកិច្ចសហការរវាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC-SG) កម្មវិធី ACCESS ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជនពិការកម្ពុជា (CDPO) និងដៃគូផ្សេងទៀត។ វគ្គបណ្តុះបណ្តាលមួយចំនួនមានគោលបំណងកសាងសមត្ថភាពសមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត (PDAC) ក្រុមការងារសកម្មភាពជនពិការ (DAWG) និងរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) ផ្សេងទៀត។ ទោះយ៉ាងណា នៅតែមានបញ្ហាប្រឈមដោយសារអត្រាខ្ពស់នៃការផ្លាស់ចេញចូលសមាជិក និងបុគ្គលិកដែលបានចាត់តាំង ព្រោះអ្នកថ្មីអាចមិនមានការយល់ដឹងអំពីសិទ្ធិជនមានពិការភាព ឬបរិយាបន្នពិការភាព ហើយវិភាជថវិកាដើម្បីអនុវត្តសកម្មភាពនៅមានកម្រិត។

ក្រសួង និងស្ថាប័នជំនាញទាំងអស់មាននាទីលើកកម្ពស់សុខុមាលភាពរបស់ជនមានពិការភាព និងសមត្ថភាពរបស់ពួកគេក្នុងការចូលរួមយ៉ាងពេញលេញក្នុងសហគមន៍។ ទោះយ៉ាងណា សកម្មភាពដើម្បីពង្រឹងបរិយាបន្នពិការភាពក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅប្រចាំថ្ងៃ នឹងទាមទារឱ្យមានអភិក្រមពហុមុខព្រួញ និងជាប្រព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីជម្នះឧបសគ្គនានា។ *ការលើកកម្ពស់បរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាពនៅកម្ពុជា* គូសបញ្ជាក់ពីក្របខណ្ឌ និងឯកសារណែនាំដែលមានសម្រាប់ក្រសួង និងអ្នកពាក់ព័ន្ធផ្សេងទៀតដើម្បីចាត់វិធានការ និងអនុវត្តទិសដៅយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP3) ដូចជា ការងារ

និងសន្តិសុខសេដ្ឋកិច្ច សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព ការអប់រំ និងការរៀនសូត្រពេញមួយជីវិត កិច្ចគាំពារសង្គម និងកម្រិតជីវភាពសមរម្យ សហគមន៍ដែលមានបរិយាបន្ន និងបង្គុលក្ខណៈងាយស្រួល សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌ និងស្ថានភាពហានិភ័យ និងការប្រែប្រួលអាកាសធាតុ។ ក្រៅពីនេះ ក៏មានការបង្ហាញចំណុចសំខាន់ៗដើម្បីសម្រេចបានបរិយាបន្នពិការភាពប្រកបដោយប្រសិទ្ធភាព តាមរយៈលទ្ធភាពស្មើភាពក្នុងការទទួលបានសេវា និងឱកាស និងការគោរពសិទ្ធិផងដែរ រួមជាមួយនឹងឯកសារណែនាំដែលមាន។ ចំណុចសំខាន់ៗទាំងនេះរួមមានក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយបែបបរិយាបន្ន អភិក្រមផ្លូវភ្លោះ ការផ្លាស់ប្តូរសង្គម និងឥរិយាបថ ភាសាបែបបរិយាបន្ន ការរៀបចំផែនការបែបបរិយាបន្ន ការធ្វើសេចក្តីសម្រេច និងការរៀបចំថវិកា ការប្រមូលទិន្នន័យ និងការពិនិត្យតាមដាន និងវាយតម្លៃ និងការអភិវឌ្ឍដែលមានបរិយាបន្នពិការភាព។

ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើអភិក្រមផ្លូវភ្លោះ ជាពិសេសការដាក់បញ្ចូលពិការភាពទៅក្នុងកម្មវិធី សកម្មភាព និងឱកាសទាំងអស់ តាមរយៈការលុបបំបាត់ឧបសគ្គនានាដើម្បីសម្រួលឱ្យជនមានពិការភាពបានចូលរួមដោយស្មើភាព។

## ៥.២ ជំហានបន្ទាប់

ជាមួយនឹងអភិក្រមទូទាំងរដ្ឋាភិបាល និងធនធានគ្រប់គ្រាន់ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP3) ឱ្យបានពេញលេញ គេអាចពន្លឿនការសម្រេចបានចក្ខុវិស័យ និងបេសកកម្មរបស់ផែនការយុទ្ធសាស្ត្រនេះ ៖ ជនមានពិការភាពនឹងចូលរួមពេញលេញ និងស្មើភាពគ្នាក្នុងសង្គមមួយដែលគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងភាពចម្រុះរបស់ពួកគេ ហើយបរិយាបន្នពិការភាពក្នុងការងារ និងថវិការបស់ក្រសួង និងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនឹងស្តែងឡើងយ៉ាងច្បាស់។ ទោះយ៉ាងណា គួរមានការអនុវត្តសកម្មភាពបន្ថែមដែលផ្តោតលើការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធគ្រប់កម្រិត លើបញ្ហាដែលបានលើកឡើងដើម្បីសម្រេចបានបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាពប្រកបដោយប្រសិទ្ធភាព នៅក្នុងទិសដៅយុទ្ធសាស្ត្រនីមួយៗនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP3)។ ខាងក្រោមនេះជាអនុសាសន៍ចំនួន ៦ ដែលបានស្នើឡើង៖

**អនុសាសន៍ទី ១៖** ***អភិវឌ្ឍធនធានបណ្តុះបណ្តាលដោយផ្ទាល់ និងតាមអនឡាញស្តីពីបរិយាបន្នពិការភាព សម្រាប់សមាជិកក្រុមការងារសកម្មភាពជនពិការ (DAWG) ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត (PDAC) និងក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់ស្រុក (DDAC)***

ជាអនុសាសន៍ ក្រៅពីការបណ្តុះបណ្តាលដោយផ្ទាល់ដែលបានអភិវឌ្ឍរួចមកហើយនោះ គួរបង្កើតឱ្យមានម៉ូឌុលបណ្តុះបណ្តាលតាមអនឡាញដែលបង្គុលក្ខណៈងាយស្រួល ស្តីពីបញ្ហានានា ដូចជា ការយល់ដឹងអំពីពិការភាព និងសិទ្ធិជនមានពិការភាព ក្របខណ្ឌច្បាប់ និងគោលនយោបាយ និងរបៀបសម្រេចបានបរិយាបន្នប្រកបដោយអត្ថន័យ និងលទ្ធភាពស្មើភាពក្នុងការទទួលបានសេវា និងឱកាសនៅក្នុងផែនការការងារ ថវិកា និងសកម្មភាពទូលំទូលាយ។ ក្រៅពីនេះ គេក៏អាចបង្កើតម៉ូឌុលជាក់លាក់សម្រាប់ក្រសួង ឬស្ថាប័ននីមួយៗផងដែរ។ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល សមាជិកនឹងមានសមត្ថភាពផ្តល់ដំបូន្មាននៅគ្រប់កម្រិតស្តីពីពិការភាព និងបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព។ លទ្ធភាពទទួលបានការបណ្តុះបណ្តាលតាមអនឡាញក៏នឹងធានាផងដែរថា សមាជិកថ្មីអាចទទួលបានចំណេះដឹងសមស្របក្នុងការបំពេញតួនាទីរបស់ពួកគេ។ ការបណ្តុះបណ្តាលអាចមាននៅលើគេហទំព័ររបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC)។

**អនុសាសន៍ទី ២៖** ***អភិវឌ្ឍធនធានបណ្តុះបណ្តាលសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈកម្មាធិការមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) ផ្សេងទៀត***

គួរមានធនធានបណ្តុះបណ្តាល រួមទាំងម៉ូឌុលបណ្តុះបណ្តាលតាមអនឡាញដែលបង្គុលក្ខណៈងាយស្រួល ស្តីពីបញ្ហានានា ដូចជា ការយល់ដឹងអំពីពិការភាព និងសិទ្ធិជនមានពិការភាព ក្របខណ្ឌច្បាប់ និងគោលនយោបាយ

ការរៀបចំវេទិកាដែលមានបរិយាបន្នពិការភាព កិច្ចគាំពារសង្គមដែលមានបរិយាបន្នពិការភាព និងការលុបបំបាត់ឧបសគ្គរាំងបរិយាបន្ន និងការចូលរួម។ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈកម្មាធិការ និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត នឹងមានសមត្ថភាពផ្តល់ដំបូន្មានស្តីពីពិការភាព និងបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព ក៏ដូចជាបង្កើនលទ្ធភាពស្មើភាពរបស់ជនមានពិការភាពក្នុងការទទួលបានសេវា និងឱកាស។ លទ្ធភាពទទួលបានការបណ្តុះបណ្តាលតាមអនឡាញក៏នឹងធានាផងដែរថា សមាជិក និងបុគ្គលិកថ្មីអាចទទួលបានចំណេះដឹងសមស្របក្នុងការបំពេញតួនាទីរបស់ពួកគេ។ ការបណ្តុះបណ្តាលអាចមាននៅលើគេហទំព័ររបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ឬក្រសួងមហាផ្ទៃ។

**អនុសាសន៍ទី ៣ ៖** ***អភិវឌ្ឍធនធានបណ្តុះបណ្តាលតាមអនឡាញស្តីពីការយល់ដឹងអំពីពិការភាព សម្រាប់មន្ត្រីរាជការ បុគ្គលិកកិច្ចសន្យា និងអ្នកផ្តល់សេវា***

គួរបង្កើតម៉ូឌុលតែមួយដើម្បីពង្រឹងការយល់ដឹងរបស់មន្ត្រីរាជការ បុគ្គលិកកិច្ចសន្យា និងអ្នកផ្តល់សេវាអំពីពិការភាព និងសិទ្ធិជនមានពិការភាព ក្នុងគោលបំណងកែលម្អឥរិយាបថ និងអាកប្បកិរិយាចំពោះជនមានពិការភាព។ ធនធានតាមអនឡាញអាចត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃដំណើរការណែនាំបុគ្គលិកថ្មី និងជាផ្នែកមួយនៃការបណ្តុះបណ្តាលបំប៉នសម្រាប់បុគ្គលិកចាស់។ ការបណ្តុះបណ្តាលអាចមាននៅលើគេហទំព័ររបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ ឬជាសំណៅឯកសារចែកជូន។

**អនុសាសន៍ទី ៤៖** ***បន្តកសាងសមត្ថភាព និងបង្កើនភាពអង់អាចដល់អង្គការតំណាងជនមានពិការភាព (OPD) រួមទាំងវេទិកាស្ត្រីពិការ (WWDF) នៅថ្នាក់ក្រោមជាតិ តាមរយៈការបណ្តុះបណ្តាល ការណែនាំ/ការបង្វឹកបង្ហាត់ និងការផ្តល់សម្ភារៈគាំទ្រសមស្រប***

ជាអនុសាសន៍ គួរបន្ត និងពង្រីកសកម្មភាពបច្ចុប្បន្នក្នុងការកសាងសមត្ថភាពរបស់អង្គការតំណាងជនមានពិការភាព និងវេទិកាស្ត្រីពិការ ដូចជា តាមរយៈការបណ្តុះបណ្តាលតាមអនឡាញ ដើម្បីធានាការចូលរួមប្រកប ដោយអត្ថន័យរបស់អាជ្ញាធរមូលដ្ឋាន តាមរយៈមាគ៌ាឆ្ពោះទៅរកបរិយាបន្ននៅថ្នាក់ក្រោមជាតិដែលមានបង្ហាញក្នុងផ្នែកទី ៤។ ក្រៅពីនេះ ចាំបាច់ត្រូវមានការបង្កើនសមត្ថភាពក្នុងការកៀរគរមូលនិធិ និងការលើកកម្ពស់ការយល់ដឹងក្នុងចំណោមជនមានពិការភាពក្នុងតំបន់គោលដៅរបស់អង្គការតំណាងជនមានពិការភាព ស្តីពីសិទ្ធិរបស់ពួកគេ និងរបៀបទាមទារសិទ្ធិទាំងនោះ។ សម្ភារៈគាំទ្រអាចមានដូចជា បដា សំណៅឯកសារសម្រាប់ចែកជូន និងធនធានផ្សេងទៀតស្តីពីបញ្ហាសំខាន់ៗដែលអាចចែករំលែកជាមួយសមាជិក និងអាជ្ញាធរមូលដ្ឋាន។

**អនុសាសន៍ទី ៥៖** ***ពង្រឹងយន្តការនានាដើម្បីបង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់អង្គការតំណាងជនមានពិការភាព/ជនមានពិការភាពនៅក្នុងគណៈកម្មាធិការ និងក្រុមការងារថ្នាក់ក្រោមជាតិទាំងអស់***

គួរបង្កើតឱ្យមាន ឬពង្រឹងយន្តការនានាដើម្បីបង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់អង្គការតំណាងជនមានពិការភាព និងជនមានពិការភាព ក្នុងក្រុមការងារ និងគណៈកម្មាធិការថ្នាក់ក្រោមជាតិដែលមានស្រាប់ទាំងអស់ ដើម្បីលើកកម្ពស់បរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព។

**អនុសាសន៍ទី ៦៖** ***បង្កើនការយល់ដឹងជាសាធារណៈអំពីសិទ្ធិ និងការរួមចំណែករបស់ជនមានពិការភាពដល់សង្គមមួយប្រកបដោយបរិយាបន្ន***

គួរបង្កើនសកម្មភាពក្នុងបង្កើត និងចែកផ្សាយសម្ភារៈផ្សព្វផ្សាយព័ត៌មាន អប់រំ និងទំនាក់ទំនង (IEC) ដើម្បីជំរុញការផ្លាស់ប្តូរឥរិយាបថ ដោយប្រើប្រាស់មធ្យោបាយផ្សេងៗ ដូចជា វិទ្យុ ទូរទស្សន៍ សារព័ត៌មាន បណ្តាញសង្គម បដា ឬព្រឹត្តិការណ៍នានា ដើម្បីកាត់បន្ថយការមាក់ងាយ និងការរើសអើងជនមានពិការភាព និងបង្ហាញពីការរួមចំណែករបស់ជនមានពិការភាពដល់សង្គម។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១ ៖ និយមន័យពាក្យគន្លឹះដើម្បីពង្រឹងការយល់ដឹង

**បច្ចេកវិទ្យា/ឧបករណ៍ជំនួយ (Assistive technology/device)** ៖ ឧបករណ៍ខាងក្រៅដែលត្រូវបានរចនា ផលិត ឬកែសម្រួលដើម្បីជួយឱ្យជនមានពិការភាពបានចូលរួមយ៉ាងសកម្មភាព និងប្រកបដោយផលិតភាពក្នុងជីវិតសហគមន៍ និងមានដូចជា បច្ចេកវិទ្យា/ឧបករណ៍ជំនួយចល័តភាព (រទេះរុញ ឧបករណ៍ជំនួយការដើរ ឈើច្រត់ ឈើឆ្កាម (crutches) ឧបករណ៍អវយវៈសិប្បនិម្មិត និងរណប) ឧបករណ៍ជំនួយការស្តាប់សម្រាប់ជួយឱ្យមនុស្សស្តាប់លឺ ឬស្តាប់លឺកាន់តែច្បាស់ ឧបករណ៍ជំនួយញាណដឹង (cognitive aids) និងសុហ្វវែរ និងហាដវែរកុំព្យូទ័រ (ដូចជា កម្មវិធីសម្គាល់សំឡេង កម្មវិធី screen reader និងកម្មវិធីពង្រីកអក្សរនៅលើScreen) ដើម្បីជួយដល់អ្នកមានកម្សោយចលនា និងញាណដឹងក្នុងការប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍ចល័ត។

**ឧបសគ្គ (Barriers)** - កត្តានានានៅក្នុងបរិស្ថានរបស់បុគ្គលម្នាក់ ដែលការមាន ឬគ្មានកត្តាទាំងនោះ កម្រិតការបំពេញមុខងារ និងបង្កើតជាពិការភាព ដូចជា បរិស្ថានរូបវន្តដែលមិនបង្កលក្ខណៈងាយស្រួល កង្វះឧបករណ៍ជំនួយសមស្រប និងឥរិយាបថអវិជ្ជមានចំពោះពិការភាព។

**កម្សោយញាណដឹង (Cognitive impairment)** ៖ ស្ថានភាពជាច្រើនដែលរួមបញ្ចូលកម្សោយសតិបញ្ញា ជនមានអូទីស្សឹម ជំងឺផ្លូវចិត្តធ្ងន់ធ្ងរ និងយូរអង្វែង របួសខួរក្បាល ជំងឺដាច់សរសៃឈាមក្នុងខួរក្បាល និងជំងឺវង្វេងវង្វាន់ និងភាពវិកលចរិតផ្សេងទៀត។

**ការអភិវឌ្ឍសហគមន៍តាមបែបបរិយាបន្ន (CBID)** ៖ ផ្តោតលើការបង្កើតសង្គមបរិយាបន្នដែលជនមានពិការភាព អាចទទួលបានអត្ថប្រយោជន៍ពីសង្គម និងការអភិវឌ្ឍ ដោយស្មើភាពជាមួយអ្នកដទៃ នៅក្នុងសហគមន៍របស់ពួកគេ។

**ការស្តារលទ្ធភាពពលកម្មតាមសហគមន៍ (Community Based Rehabilitation)** ៖ យុទ្ធសាស្ត្រមួយក្នុងការអភិវឌ្ឍសហគមន៍ទូទៅសម្រាប់ការស្តារលទ្ធភាពពលកម្ម ការធ្វើឱ្យមានសមភាពនៃឱកាស និងបរិយាបន្នសង្គមសម្រាប់ជនមានពិការភាពទាំងអស់ ដែលបច្ចុប្បន្ន ជាផ្នែកមួយនៃការអភិវឌ្ឍសហគមន៍តាមបែបបរិយាបន្ន។

**បរិយាបន្នពិការភាព (Disability inclusion)** ៖ ការចូលរួមពេញលេញរបស់ជនមានពិការភាពក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅតាមរយៈការលើកកម្ពស់សិទ្ធិ និងការគោរពទស្សនៈរបស់ពួកគេ ស្របតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ។

**ការអភិវឌ្ឍដែលមានបរិយាបន្នពិការភាព (Disability inclusive development)** ៖ គ្រប់ដំណាក់កាលនៃដំណើរការអភិវឌ្ឍន៍ មានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ដោយមនុស្សគ្រប់រូបមានលទ្ធភាពស្មើភាពគ្នាក្នុងការទទួលបានការអប់រំ សេវាថែទាំសុខភាព ការងារ និងកិច្ចគាំពារសង្គម។ល។

**អង្គការជនពិការ (Disability organization)** ៖ អង្គការដែលផ្តល់សេវា ឬតស៊ូមតិសម្រាប់ជនមានពិការភាព ប៉ុន្តែមិនចាំបាច់ដឹកនាំដោយជនមានពិការភាពទេ។

**ភាពចម្រុះ (Diversity)** – ទទួលស្គាល់ទិដ្ឋភាពទាំងអស់នៃការស្តែងឡើង និងបទពិសោធន៍របស់មនុស្ស ដូចជា ដើមកំណើតជាតិ ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច សាវតារអប់រំ ជាតិពន្ធុ អត្តសញ្ញាណយេនឌ័រ និន្នាការផ្លូវភេទ សាសនា ពិការភាព និងបេតិកភណ្ឌវប្បធម៌។

**អ្នកមានកាតព្វកិច្ច (Duty bearer)** ៖ តួអង្គទាំងអស់ រួមទាំងតួអង្គរដ្ឋាភិបាល តួអង្គមិនមែនរដ្ឋាភិបាល និងតួអង្គអន្តរជាតិ ដែលមានកាតព្វកិច្ចគោរព ការពារ លើកកម្ពស់ និងបំពេញសិទ្ធិរបស់ជនមានពិការភាព (អ្នកមានសិទ្ធិ)។

**សមភាព (Equality)** ៖ ទទួលស្គាល់ថា មនុស្សគ្រប់រូបមានតម្លៃដូចគ្នា សិទ្ធិដូចគ្នា គួរទទួលបានការគោរពក្នុងកម្រិតដូចគ្នា និងមានលទ្ធភាពទទួលបានសេវា និងឱកាសដូចគ្នា។

**សមធម៌ (Equity)** ៖ មានគោលបំណងលើកកម្ពស់យុត្តិធម៌ ភាពត្រឹមត្រូវ និងភាពមិនលម្អៀងក្នុងរបៀបបំពេញកិច្ចការ និងការបែងចែកធនធាន ដើម្បីធានាសមភាពនៃការប្រព្រឹត្តចំពោះ លទ្ធភាពទទួលបានឱកាស និងវឌ្ឍនភាព សម្រាប់មនុស្សគ្រប់រូប តាមរយៈការកំណត់រក និងលុបបំបាត់ឧបសគ្គរាំងក្រុមមួយចំនួន រួមទាំងជនមានពិការភាព មិនឱ្យចូលរួមពេញលេញក្នុងសង្គម។

**កម្សោយ (Impairment)** ៖ ការបាត់បង់ ឬភាពមិនប្រក្រតីណាមួយនៃរចនាសម្ព័ន្ធ ឬមុខងារផ្លូវចិត្ត សរីរៈ ឬរូបរាងកាយ។

**ការអប់រំបរិយាបន្ន (Inclusive education)** ៖ សិទ្ធិរបស់កុមារ និងយុវជនគ្រប់រូបក្នុងការរួមបញ្ចូលទៅក្នុងការអប់រំចំណេះទូទៅ ដែលពាក់ព័ន្ធនឹងការសម្របសម្រួលបរិយាកាស និងគោលវិធីបង្រៀនដើម្បីធានាការចូលរួមពេញលេញ និងមានតម្លៃពិតប្រាកដរបស់កុមារ និងយុវជនទាំងអស់។

**ការអប់រំចម្រុះ (Integrated education)** ៖ ដំណើរការមួយដែលសិស្សមានតម្រូវការពិសេសត្រូវបានបញ្ចូលទៅក្នុងការអប់រំទូទៅ និងរៀនសូត្រជាមួយសិស្សផ្សេងទៀតដែលគ្មានពិការភាព។

**អង្គការតំណាងជនមានពិការភាព (Organisation of persons with disabilities)** ៖ សមាគមមួយដែលត្រូវបានបង្កើតឡើង និងដឹកនាំដោយជនមានពិការភាពដើម្បីលើកស្ទួយ និងការពារសិទ្ធិ សុខុមាលភាព និងសេចក្តីថ្លៃថ្នូររបស់ជនមានពិការភាព ដែលសមាជិកលើស ៥០ ភាគរយ ជាជនមានពិការភាព។

**ជនមានពិការភាព (Persons with disabilities)** ៖ ជនដែលមានការពិបាកយូរអង្វែងផ្នែករាងកាយ ផ្លូវចិត្ត បញ្ញា ឬញាណដឹង ដែលអន្តរកម្មរបស់គាត់ជាមួយនឹងឧបសគ្គនានា អាចធ្វើឱ្យរារាំងដល់ការចូលរួមក្នុងសង្គមយ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធភាព និងដោយស្មើភាពជាមួយអ្នកដទៃ។

**ការគាំទ្រផ្ទាល់ខ្លួន (Personal support)** ៖ ពាក់ព័ន្ធនឹងការជួយដល់សកម្មភាពផ្ទាល់ខ្លួនប្រចាំថ្ងៃ ដូចជា ការជួយជ្រោមជ្រែង ឬការត្រួតពិនិត្យកិច្ចការផ្ទាល់ខ្លួនក្នុងជីវិតប្រចាំថ្ងៃ។

**ជាសុកសមរម្យ (Reasonable accommodation)** ៖ សំដៅលើការកែប្រែ និងការកែសម្រួលចាំបាច់ និងសមស្របដើម្បីធានាថា ជនមានពិការភាពអាចទទួលបានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់។

**ការស្តារលទ្ធភាពពលកម្ម (Rehabilitation)** ៖ កម្រងវិធានការសម្រាប់ជួយដល់បុគ្គលដែលទទួលរង ឬងាយនឹងទទួលរងពិការភាព ដើម្បីសម្រេចបាន និងរក្សាការបំពេញមុខងាររាងកាយ វិញ្ញាណ សតិបញ្ញា ផ្លូវចិត្ត និងសង្គម ឱ្យបានជាអតិបរមា នៅក្នុងអន្តរកម្មរបស់ពួកគេជាមួយបរិស្ថានជុំវិញខ្លួន។

**អ្នកមានសិទ្ធិ (Rights holder)** ៖ ជនមានពិការភាព ឬក្រុមតំណាងរបស់ពួកគេដែលមានសិទ្ធិជាក់លាក់ទាក់ទងនឹងអ្នកមានកាតព្វកិច្ច។

**ក្រុមជួយខ្លួនឯង (Self Help Group)** – ក្រុមដែលត្រូវបានបង្កើតឡើងនៅកម្រិតមូលដ្ឋានដោយជនមានពិការភាពដើម្បីផ្តល់ការគាំទ្រក្នុងសង្គម សន្សំប្រាក់ កសាងការយល់ដឹង និងឥស្សរិយមតិ និងចែករំលែកបទពិសោធន៍។

**កិច្ចគាំពារសង្គម (Social protection)** ៖ កម្រងគោលនយោបាយ និងកម្មវិធីដែលមានគោលបំណងទប់ស្កាត់ ឬការពារមនុស្សគ្រប់រូប រួមទាំងជនមានពិការភាព ពីភាពក្រីក្រ ភាពងាយរងគ្រោះ និងការផាត់ចេញពីសង្គម ក្នុងជីវិតរស់នៅរបស់ពួកគេ។

**ការអប់រំពិសេស (Special education)** ៖ ប្រព័ន្ធអប់រំដែលឆ្លើយតបនឹងកុមារដែលមានតម្រូវការជាក់លាក់នៅក្រៅការអប់រំទូទៅ។

**ការព្យាបាលការនិយាយ (Speech therapy)** ៖ ការវាយតម្លៃ និងការព្យាបាលបញ្ហាទំនាក់ទំនង វិបត្តិក្នុងការនិយាយស្តី និងបញ្ហាលេបអាហារ។

**ការរចនាប្លង់ជាសកល (Universal design)** ៖ ការគូសប្លង់ផលិតផល បរិស្ថាន កម្មវិធី និងសេវាកម្មផ្សេងៗដែលមនុស្សគ្រប់រូបអាចប្រើប្រាស់បាន ដោយមិនទាមទារចំពោះការសម្របតាម ឬគម្រោងប្លង់ពិសេសផ្សេងទៀត ក្នុងវិសាលភាពធំបំផុតដែលអាចធ្វើទៅបាន។

**ការគ្របដណ្តប់សុខភាពជាសកល (Universal health coverage)** ៖ ការធានាថា មនុស្សគ្រប់រូបអាចប្រើប្រាស់សេវាសុខភាពសម្រាប់ការលើកកម្ពស់ បង្ការ ព្យាបាល ស្តារលទ្ធភាពពលកម្ម និងសេវាសុខភាពបណ្តោះអាសន្នដែលពួកគេត្រូវការចាំបាច់ ដែលមានគុណភាពគ្រប់គ្រាន់ដើម្បីឱ្យមានប្រសិទ្ធភាព ក៏ដូចជាធានាថា ការប្រើប្រាស់សេវាទាំងនេះមិនធ្វើឱ្យអ្នកប្រើប្រាស់មានការលំបាកផ្នែកហិរញ្ញវត្ថុ។

**ការបណ្តុះបណ្តាលវិជ្ជាជីវៈ (Vocational training)** ៖ ការអប់រំមួយប្រភេទដែលផ្តោតលើការបង្រៀនជំនាញ និងចំណេះដឹងដែលត្រូវការចាំបាច់សម្រាប់ការបំពេញការងារ និងអាជីវកម្មជាក់លាក់ណាមួយ។

## ឧបសម្ព័ន្ធ ២ ៖ អ្នកពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ទន្ទឹមនឹងការទទួលស្គាល់ថា មនុស្សគ្រប់រូបមានតួនាទីក្នុងការលើកកម្ពស់បរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព ការវិភាគនេះផ្តោតលើអ្នកពាក់ព័ន្ធ និងរចនាសម្ព័ន្ធសំខាន់ៗដែលកំពុងធ្វើការជាមួយ និងដើម្បីជនមានពិការភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការវិភាគនេះមានគោលបំណងផ្តល់ធនធានដល់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងការកំណត់ដៃគូដែលមានសក្តានុពល ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងពង្រឹងបរិយាបន្នពិការភាពនៅក្នុងគោល នយោបាយ និងកម្មវិធីរបស់ពួកគេ។ ការវិភាគបែងចែកអ្នកពាក់ព័ន្ធជា ៥ ក្រុម គឺក្រសួង ទីភ្នាក់ងារ និងរចនាសម្ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ អាជ្ញាធរ និងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ អង្គការតំណាងជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ។

*ក្រសួង ទីភ្នាក់ងារ និងរចនាសម្ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ*

ក្រសួង និងទីភ្នាក់ងារទាំងអស់មានតួនាទីក្នុងការពង្រឹងបរិយាបន្នពិការភាព រួមទាំងតាមរយៈ ប៉ុន្តែមិនកំណត់ត្រឹម ការជួលឱ្យជនមានពិការភាពធ្វើការ និងការបង្កើនលទ្ធភាពទទួលបានសេវា និងឱកាស។ ក្រសួង ទីភ្នាក់ងារ និងរចនាសម្ព័ន្ធសំខាន់ៗមួយចំនួនដែលមានតួនាទីច្បាស់លាស់ក្នុងការពង្រឹងបរិយាបន្នពិការភាពរួមមាន ក្រុមប្រឹក្សា សកម្មភាពជនពិការ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងផែនការ ក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិគាំពារសង្គម។

**ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC)** ៖ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការឆ្នាំ ២០០៩ បានបង្កើត DAC ជា "យន្តការសម្របសម្រួល និងផ្តល់យោបល់ថ្នាក់ជាតិស្តីពីពិការភាព"។ ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សានេះ ត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ២១៦ អនក្រ.បក ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ។ DAC មានសមាជិក ៥៨ រូប។ នាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស ដោយមាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន និងរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងតំណាងអង្គការតំណាងជនមានពិការភាព ជាអនុប្រធាន ហើយអនុរដ្ឋលេខាធិការនៃក្រសួងផ្សេងទៀតជាសមាជិក។ សមាជិកផ្សេងទៀតរួមមាន អគ្គលេខាធិការរងនៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (CMAA) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) តំណាងកាកបាទក្រហមកម្ពុជា តំណាង ៤ រូបនៃអង្គការតំណាងជនមានពិការភាព (ស្រី ២ នាក់ ប្រុស ២ នាក់) តំណាងម្នាក់មកពីអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យពិការភាព តំណាងម្នាក់មកពីវិស័យឯកជន អភិបាលរងរាជធានី/ខេត្តនីមួយៗ និងអគ្គលេខាធិការ DAC-SG។

ក្រុមប្រឹក្សាសកម្មភាពជនពិការ គាំទ្រដោយ**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC-SG)** ដែលជាអង្គភាពប្រតិបត្តិចំណុះឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ តួនាទី និងភារកិច្ចរបស់ DAC-SG រួមមាន ការផ្តល់ការណែនាំបច្ចេកទេសស្តីពីពិការភាព និងការស្តារលទ្ធភាពពលកម្ម និងការសម្របសម្រួល ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការបង្កើតគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រទាក់ទងនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម។ តួនាទីសំខាន់មួយរបស់អង្គភាពបរិយាបន្នជនមានពិការភាពនៃ DAC-SG គឺត្រូវសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើតគោលនយោបាយ និងផែនការសកម្មភាពដែលមានបរិយាបន្នពិការភាព។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY)** ៖ ជាក្រសួងឈានមុខដែលទទួលខុសត្រូវលើពិការភាព។ តួនាទី និងភារកិច្ចបច្ចុប្បន្នរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានគូសបញ្ជាក់ក្នុងអនុក្រឹត្យលេខ ៩៤ ឆ្នាំ ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[111]។ អង្គភាពរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែលមានភាពពាក់ព័ន្ធបំផុតក្នុងការលើកកម្ពស់បរិយាបន្នពិការភាពនៅថ្នាក់ជាតិគឺនាយកដ្ឋានសុខុមាលភាពជនពិការ មូលនិធិជនពិការ មូលនិធិជាតិជំនួយសង្គម និងអគ្គនាយកដ្ឋានគោលនយោបាយសង្គមកិច្ច។

[111] សម្រាប់ព័ត៌មានបន្ថែម សូមមើលអនុក្រឹត្យលេខ ៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២២ ការបកប្រែក្រៅផ្លូវការ

- តួនាទី និងភារកិច្ចរបស់***នាយកដ្ឋានសុខុមាលភាពជនពិការ***ដែលចំណុះឱ្យអគ្គនាយកដ្ឋានស្តារសម្បទា មានដូចជា អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ឯកសារច្បាប់ និងគោលការណ៍ណែនាំទាក់ទងនឹងពិការភាព ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍកម្មវិធីអត្តសញ្ញាណកម្មជនមានពិការភាព និងគ្រប់គ្រងទិន្នន័យជនមានពិការភាព ត្រួតពិនិត្យ ការងារពិការភាពនៅក្រសួង ស្ថាប័ន និងវិស័យឯកជនដើម្បីអនុវត្តភារកិច្ចដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ សហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធដើម្បីអភិវឌ្ឍ និងធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត មធ្យោបាយធ្វើដំណើរ ទំនាក់ទំនងឌីជីថល និងជំនួយផ្ទាល់ខ្លួនបង្កលក្ខណៈងាយស្រួល និងសហការជាមួយ ក្រសួង/ស្ថាប័នពាក់ព័ន្ធដើម្បីអភិវឌ្ឍសិល្បៈ និងកីឡាសម្រាប់ជនមានពិការភាព[112]។
- មូលនិធិជនពិការ (PWDF) ត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការឆ្នាំ ២០០៩។ អនុក្រឹត្យលេខ ១១៨ អនក្រ.បក ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ បានបង្កើត មូលនិធិជនពិការជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មាត្រា ៣ បានពង្រីកគោលបំណងរបស់មូលនិធិជនពិការ និងប្រគល់តួនាទី និងភារកិច្ចបន្ថែម ដូចជា ផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ គ្រប់គ្រងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មជូនជនពិការ ធ្វើសមាហរណកម្មជនពិការទៅក្នុងសហគមន៍ និងរៀបចំគោលនយោបាយផ្គត់ផ្គង់ និងឧបត្ថម្ភដល់ជនពិការ។
- **មូលនិធិជាតិជំនួយសង្គម (NSAF)** ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២ និងត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៣[113]។ មូលនិធិជាតិជំនួយ សង្គមស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មូលនិធិ ជាតិជំនួយសង្គម ត្រូវបានបង្កើតឡើងដើម្បីរួមបញ្ចូលកម្មវិធីជំនួយសង្គមទាំងអស់ឱ្យស្ថិតក្រោមស្ថាប័នតែមួយ ប៉ុន្តែស្ថិតក្រោម ការណែនាំ និងការតម្រង់ទិសគោលនយោបាយរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។ មូលនិធិ ជាតិជំនួយសង្គម មានតួនាទីសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នពិការភាពក្នុងកម្មវិធីកញ្ចប់គ្រួសារ។
- **អគ្គនាយកដ្ឋានគោលនយោបាយសង្គមកិច្ច (GDSAP)** មានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអភិវឌ្ឍ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រទាក់ទងនឹងអាណត្តិរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវ នីតិសម្បទា ដែលរួមបញ្ចូលពិការភាព។ ជាពិសេស នាយកដ្ឋានអភិវឌ្ឍន៍គោលនយោបាយ អាចធានាការរួម បញ្ចូលជនមានពិការភាពទៅក្នុងគោលនយោបាយ ផែនការ និងសេវាទាំងអស់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[114]។

**ក្រសួងអប់រំ យុវជន និងកីឡា (MoEYS)** ដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នពិការភាពតាមរយៈការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយ និងផែនការបរិយាបន្នដើម្បីលើកកម្ពស់ការអប់រំរបស់កុមារ និងមនុស្សពេញវ័យដែល មានពិការភាព។ ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ធនធាន និងការបណ្តុះបណ្តាលដល់គ្រូបង្រៀនដើម្បីគាំទ្រសិស្ស មានពិការភាព និងធានាថា សាលារៀនបង្កលក្ខណៈងាយស្រួលផ្នែករូបវន្ត និងមានជាសុកចាំបាច់។ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតនាយកដ្ឋានអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស។

**ក្រសួងសុខាភិបាល (MoH)** មានអាណត្តិផ្តល់សេវាថែទាំសុខភាពដល់ប្រជាជនទាំងអស់ រួមទាំងមនុស្សពេញវ័យ និងកុមារដែលមានពិការភាពគ្រប់ប្រភេទ។ ក្រសួងសុខាភិបាលដើរតួនាទីសំខាន់ក្នុងការធានាថា មូលដ្ឋានសុខាភិបាល សាធារណៈគ្រប់កម្រិតបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ហើយបុគ្គលិកសុខាភិបាលទទួលបានការ បណ្តុះបណ្តាលស្តីពីការថែទាំសុខភាពដែលមានបរិយាបន្នពិការភាព។

---

[112] សម្រាប់ព័ត៌មានបន្ថែម សូមមើលមាត្រា ២៥ នៃអនុក្រឹត្យលេខ ៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវ នីតិសម្បទា ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២២ ការបកប្រែក្រៅផ្លូវការ

[113] សម្រាប់ព័ត៌មានបន្ថែម សូមមើលមាត្រា ៥ និង ៦ ជំពូក ២ នៃអនុក្រឹត្យស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

[114] សម្រាប់ព័ត៌មានបន្ថែម សូមមើលមាត្រា ១៣ និង ១៤ ជំពូក ៥ នៃអនុក្រឹត្យលេខ ៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២២ ការបកប្រែក្រៅផ្លូវការ

**ក្រសួងព័ត៌មាន (MoInf)** ទទួលខុសត្រូវលើការអនុវត្តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន និងដើរតួនាទីសំខាន់ក្នុងការធានាថា មន្ត្រីព័ត៌មាន និងបុគ្គលិកពាក់ព័ន្ធនៅទូទាំងរាជរដ្ឋាភិបាលកម្ពុជាមានសមត្ថភាព និងមធ្យោបាយផ្តល់ព័ត៌មានដែលបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព។

**ក្រសួងមហាផ្ទៃ (MoI)** មានតួនាទីពិសេសក្នុងការជះឥទ្ធិពលដល់ការអភិវឌ្ឍ និងដំណើរការធ្វើសេចក្តីសម្រេចដែលមានបរិយាបន្នពិការភាពនៅថ្នាក់ក្រោមជាតិ ព្រោះក្រសួងទទួលបានអាណត្តិពីរាជរដ្ឋាភិបាលកម្ពុជាក្នុងការដឹកនាំ និងសម្របសម្រួលកំណែទម្រង់វិមជ្ឈការ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃគឺជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) ដែលជាយន្តការអន្តរក្រសួងកម្រិតខ្ពស់សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍប្រជាធិបតេយ្យតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅទូទាំងប្រទេសកម្ពុជា។

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)** ផ្តល់ឱកាសការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ប្រជាជនទាំងអស់ និងបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជាង ៣០ កន្លែង ដើម្បីផ្តល់ការប្រឹក្សាយោបល់ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើរតួនាទីសំខាន់ក្នុងការធានាថាការបណ្តុះបណ្តាល និងឱកាសផ្សេងទៀតមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ធ្វើការជាមួយនិយោជកដើម្បីបង្កើតកន្លែងការងារបែបបរិយាបន្ន និងអនុវត្តគោលនយោបាយដើម្បីលើកកម្ពស់ឱកាសការងារស្មើភាពផងដែរ។

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MoLMUPC)** ដើរតួនាទីសំខាន់ក្នុងការធានានូវហេដ្ឋារចនាសម្ព័ន្ធ និងអគារដែលបង្កលក្ខណៈងាយស្រួល។ ការទទួលខុសត្រូវរួមមានការអភិវឌ្ឍ និងការអនុវត្តច្បាប់ស្តីពីសំណង់ និងបទប្បញ្ញត្តិដែលរួមបញ្ចូលស្តង់ដារការបង្កលក្ខណៈងាយស្រួល ការលើកកម្ពស់ការរចនាប្លង់ជាសកលក្នុងអគារ និងទីសាធារណៈ និងការធានាថា គម្រោងសាងសង់ថ្មីៗមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។ ក្រសួងក៏ធ្វើការលើគម្រោងកែលម្អអគាររដ្ឋាភិបាលផងដែរ តាមរយៈការសង់ជម្រាល និងហេដ្ឋារចនាសម្ព័ន្ធដែលបង្កលក្ខណៈងាយស្រួល។

**ក្រសួងផែនការ (MoP)** តាមរយៈវិទ្យាស្ថានជាតិស្ថិតិ មានសក្តានុពលក្នុងការវាស់វែងវឌ្ឍនភាពនៃការពង្រឹងបរិយាបន្នពិការភាព តាមរយៈការប្រមូលទិន្នន័យទាក់ទងនឹងពិការភាពសម្រាប់ការស្ទង់មតិផ្សេងៗ ដូចជា ជំរឿនប្រជាជន ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា និងការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចផ្សេងទៀត។

**ក្រសួងកិច្ចការនារី (MoWA)** លើកកម្ពស់សិទ្ធិស្ត្រី និងកុមារ តាមរយៈការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច លទ្ធភាពទទួលបានការអប់រំ និងកម្មវិធីទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ។ គោលនយោបាយ និងកម្មវិធីទាំងអស់សុទ្ធតែមានបរិយាបន្នសម្រាប់ស្ត្រី និងក្មេងស្រីមានពិការភាព។

**ក្រុមប្រឹក្សាជាតិគាំពារសង្គម (NSPC)** ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៧ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ គឺជាស្ថាប័នសម្របសម្រួលក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។ ក្រុមប្រឹក្សាជាតិគាំពារសង្គមមានសមាសភាពតំណាងជាន់ខ្ពស់មកពីក្រសួង និងស្ថាប័នពាក់ព័ន្ធ។ ក្រុមប្រឹក្សាជាតិគាំពារសង្គម ដើរតួនាទីសំខាន់ក្នុងការធានាបរិយាបន្នពិការភាពក្នុងគោលនយោបាយ និងកម្មវិធីគាំពារសង្គម។ មូលនិធិជាតិជំនួយសង្គម ត្រូវបានបង្កើតឡើងដើម្បីរួមបញ្ចូលកម្មវិធីជំនួយសង្គមទាំងអស់ឱ្យស្ថិតក្រោមស្ថាប័នតែមួយ។ ស្ថាប័ននេះស្ថិតក្រោមការណែនាំ និងការតម្រង់ទិសគោលនយោបាយរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម និងផ្តល់របាយការណ៍ ទិន្នន័យ និងព័ត៌មានទៅតាមការស្នើសុំរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម[115]។

រចនាសម្ព័ន្ធរដ្ឋាភិបាលជាច្រើនផ្សេងទៀតនៅថ្នាក់ជាតិ ក៏អាចពាក់ព័ន្ធនឹងការពង្រឹងបរិយាបន្នពិការភាពផងដែរ ដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

---

[115] មាត្រា ៣៩ ជំពូក ៥ នៃអនុក្រឹត្យស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល (ការបកប្រែក្រៅផ្លូវការ)

### *រដ្ឋបាល និងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ*

ដោយផ្តោតសំខាន់លើវិមជ្ឈការនៅកម្ពុជា រដ្ឋបាល និងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ (SNA) នៅថ្នាក់ខេត្ត ស្រុក និងឃុំ មានតួនាទីសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នពិការភាពក្នុងសេវា និងសកម្មភាពអភិវឌ្ឍន៍សំខាន់ៗ និងការកសាងសហគមន៍បែបបរិយាបន្ន។ គ្រប់ក្រសួងទាំងអស់សុទ្ធតែមានមន្ទីរថ្នាក់ខេត្ត និងការិយាល័យថ្នាក់ស្រុកដើម្បីត្រួតពិនិត្យការផ្តល់ និងការអនុវត្តគោលនយោបាយ និងកម្មវិធីនានា ដូចជា មន្ទីរ/ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរ/ការិយាល័យសុខាភិបាល និងមន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា។ រចនាសម្ព័ន្ធសំខាន់ៗផ្សេងទៀតដែលមានតួនាទីពង្រឹងបរិយាបន្នពិការភាព ដូចជា ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត ក្រុមប្រឹក្សាឃុំ/សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ មានបង្ហាញក្នុងផ្នែកទី ៤ (មាត៌ាឆ្ពោះទៅរកការពង្រឹងបរិយាបន្នពិការភាពនៅថ្នាក់ក្រោមជាតិ)។

### *អង្គការតំណាងជនមានពិការភាព*

ចលនារបស់ជនមានពិការភាពនៅកម្ពុជា មានការរៀបចំបានល្អ និងផ្អែកតាមច្បាប់ និងគោលនយោបាយទាក់ទងនឹងពិការភាព។ អង្គការតំណាងជនមានពិការភាព (OPD) រួមទាំងវេទិកាស្ត្រីពិការ (WWDF) មានតួនាទីសំខាន់ក្នុងការរួមចំណែកដល់ការងាររបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត តាមរយៈការនាំយកសំឡេងរបស់សមាជិករបស់ពួកគេទៅដាក់ក្នុងកិច្ចពិភាក្សា[116]។ អង្គការតំណាងជនមានពិការភាព ដឹកនាំដោយជនមានពិការភាពផ្ទាល់ ដោយដើរតួនាទីជាសំឡេងរួមមួយសម្រាប់សមាជិក ដើម្បីធានាថា សិទ្ធិរបស់ពួកគេត្រូវបានគោរព និងការពារ។ ការកៀរគរសហគមន៍ និងការបង្កើតបណ្តាញ គឺជាចំណុចស្នូលនៃភាពជោគជ័យរបស់អង្គការតំណាងជនមានពិការភាព។ តាមរយៈការចូលរួមជាមួយសហគមន៍  អង្គការទាំងនេះអាចលើកកម្ពស់ការគាំទ្រដល់បរិយាបន្នពិការភាព និងជំរុញការចូលរួមក្នុងសកម្មភាពដែលលើកកម្ពស់សុខុមាលភាពរបស់សមាជិក។

**អង្គការជនពិការកម្ពុជា (CDPO)** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកបរិយាបន្នពិការភាព និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៤។ CDPO គឺជាអង្គការមេម្រាប់អង្គការតំណាងជនមានពិការភាពដែលផ្អែកលើសមាជិកភាព ដែលដំណើរការ និងគ្រប់គ្រងដោយជនមានពិការភាព។ CDPO តំណាងឱ្យជនមានពិការភាពគ្រប់ប្រភេទនៅគ្រប់ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា តាមរយៈបណ្តាញអង្គការតំណាងជនមានពិការភាពចំនួន ៧៥ រួមទាំងវេទិកាស្ត្រីពិការចំនួន ១១ និងក្រុមជួយខ្លួនឯងជាង ១.០០០ ក្រុម។ CDPO មិនមែនជាអ្នកផ្តល់សេវាទេ ប៉ុន្តែតំណាងឱ្យអង្គការតំណាងជនមានពិការភាព និងវេទិកាស្ត្រីពិការនៅថ្នាក់ជាតិ ស្វែងរកមតិគាំទ្រសិទ្ធិ និងផលប្រយោជន៍របស់ជនមានពិការភាព ព្រមទាំងកសាងសមត្ថភាពរបស់ជនមានពិការភាពដើម្បីទាមទារសិទ្ធិរបស់ពួកគេ និងបង្កើនការយល់ដឹងរបស់សហគមន៍ដើម្បីលើកកម្ពស់បរិយាបន្នពិការភាព។

អង្គការតំណាងជនមានពិការភាពផ្សេងទៀត ផ្តោតលើប្រភេទពិការភាពជាក់លាក់ ដូចជា សមាគមនៃជនពិការភ្នែកកម្ពុជា និងសមាគមជនពិការខួរឆ្អឹងខ្នងកម្ពុជា។

**សមាគមនៃជនពិការភ្នែកកម្ពុជា (ABC)** គឺជាអង្គការជួយខ្លួនឯងដែលមានសមាជិកជាជនពិការភ្នែក និងមានកម្សោយគំហើញ។ សមាគមនេះចាប់ដៃគូសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធផ្សេងទៀតដើម្បីលើកកម្ពស់ការរួមបញ្ចូលជនពិការភ្នែក និងមានកម្សោយគំហើញទៅក្នុងផែនការ និងកម្មវិធីនានា តាមរយៈការតស៊ូមតិ ការបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាព និងលើកកម្ពស់ការចូលរួមពេញលេញក្នុងសង្គម។

**សមាគមជនពិការខួរឆ្អឹងខ្នងកម្ពុជា (SCIA)** ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១២ ក្នុងខេត្តបាត់ដំបង ខិតខំបង្កើនការយល់ដឹងជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរជាតិស្តីពីសិទ្ធិ និងតម្រូវការថែទាំសុខភាព និងស្តារលទ្ធភាពពលកម្មដើម្បីលើកកម្ពស់សុខុមាលភាព និងបរិយាបន្នរបស់ជនពិការខួរឆ្អឹងខ្នង។

### *អង្គការមិនមែនរដ្ឋាភិបាល (NGO)*

អង្គការមិនមែនរដ្ឋាភិបាលជាច្រើន ធ្វើការជាមួយ និងដើម្បីជនមានពិការភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ខាងក្រោមនេះជាទិដ្ឋភាពទូទៅនៃអង្គការមិនមែនរដ្ឋាភិបាលចំនួន។

---

[116] Social Inclusion Situation Analysis – Cambodia, Draft Report, 8 November 2022, 11

**អង្គការសកម្មភាពលើពិការភាព និងអភិវឌ្ឍន៍ (ADD)** គាំទ្រចលនាជនមានពិការភាពនៅទូទាំងប្រទេសកម្ពុជា។ ADD ធ្វើការដោយផ្ទាល់ជាមួយក្រុមជួយខ្លួនឯង នៅខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពត កណ្តាល ព្រៃវែង ពោធិ៍សាត់ និងតាកែវ និងនៅតាមខេត្តផ្សេងទៀត តាមរយៈអង្គការតំណាងជនមានពិការភាពក្នុងមូលដ្ឋាន។ ក្រៅពីនេះ ADD សហការជាមួយបណ្តាញអង្គការតំណាងជនមានពិការភាពដើម្បីតស៊ូមតិឱ្យមានបរិយាបន្នមនុស្សពេញវ័យ និងកុមារដែលមានពិការភាពទៅក្នុងសង្គម។

**សមាគមសម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន (AAR Japan)** លើកកម្ពស់ការអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព តាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀន និងការសង់ជម្រាល និងបង្គន់អនាម័យដែលមានជាសុករវត្ថុនៅតាមសាលារៀន។ ក្រៅពីនេះ AAR Japan គាំទ្រដល់រោងជាងផលិតរទេះរុញនៅភ្នំពេញដែលផលិត និងផ្តល់រទេះរុញ ឧបករណ៍ជំនួយការដើរ និងឧបករណ៍ជំនួយផ្សេងទៀតដោយឥតគិតថ្លៃដល់ជនមានពិការភាព។

**អង្គការឃែរកម្ពុជា (CARE Cambodia)** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកបរិយាបន្នពិការភាព ធ្វើការជាមួយស្ត្រីសហគមន៍របស់ពួកគេ ថ្នាក់ដឹកនាំ និងអាជ្ញាធរនៅខេត្តរតនគិរី ដើម្បីធានាថាស្ត្រី និងក្មេងស្រីដែលត្រូវបានផាត់ចេញពីសង្គម និងជនជាតិដើមភាគតិច រួមទាំងស្ត្រី និងក្មេងស្រីមានពិការភាព ទទួលបានការគោរពសិទ្ធិ ការឱ្យតម្លៃដល់អត្តសញ្ញាណរបស់ពួកគេ និងមានលទ្ធភាពទទួលបានមុខរបរចិញ្ចឹមជីវិត និងឱកាសផ្សេងទៀតដោយស្មើភាព។ អង្គការឃែរក៏គាំទ្រដល់ការរួមបញ្ចូលជនមានពិការភាពទៅក្នុងកម្មវិធីស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រផងដែរ។ អង្គការឃែរអនុវត្តអភិក្រមផ្លូវភ្លោះដើម្បីពង្រឹងបរិយាបន្នពិការភាព។

**មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវវ័យ (CCAMH)** គឺជាគម្រោងសហការជាមួយក្រសួងសុខាភិបាល និងអង្គការការីតាសកម្ពុជា ដើម្បីបង្កើនការយល់ដឹងអំពីសុខភាពផ្លូវចិត្ត និងសារៈសំខាន់របស់វា។ CCAMH ធ្វើការយ៉ាងជិតស្និទ្ធជាមួយកុមារ អាយុ ០-១៨ ឆ្នាំដែលមានបញ្ហាផ្លូវចិត្ត បញ្ហាប្រព័ន្ធប្រសាទ និងពិការភាពសតិបញ្ញា។ ក្រុមការងារពហុវិស័យដើរតួនាទីសំខាន់ក្នុងសេវា ដែលត្រូវបានផ្តល់រួមជាមួយនឹងការពិនិត្យបឋមលើសុខភាពបុគ្គល និងការគ្រប់គ្រងករណី។

**កម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់ (DDP)** គឺជាគម្រោងរបស់អង្គការម៉ារីណុលកម្ពុជា ដែលប្តេជ្ញាធ្វើការជាមួយមនុស្សថ្លង់ និងគ្រួសាររបស់ពួកគេដើម្បីជួយឱ្យពួកគេចូលរួមពេញលេញក្នុងសង្គម និងសម្រេចបានឯករាជ្យភាព និងសមភាព។

**កម្មវិធីសេវាកម្មអភិវឌ្ឍន៍ជនពិការ (DDSP)** ធ្វើការក្នុងខេត្តពោធិ៍សាត់ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់មនុស្សពេញវ័យ និងកុមារដែលមានពិការភាព តាមរយៈការបង្កើនលទ្ធភាពទទួលបានសេវា និងឱកាសជាច្រើន ដូចជា ការស្តារលទ្ធភាពពលកម្ម ការអប់រំបរិយាបន្ន និងពិសេស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការហ្វឹកហ្វឺនការងារ។ DDSP បង្កើនការយល់ដឹងរបស់សហគមន៍ស្តីពីសិទ្ធិរបស់ជនមានពិការភាព និងខិតខំសម្រេចបានបរិយាបន្នសង្គមសម្រាប់ជនមានពិការភាព។ ក្រៅពីនេះ DDSP ខិតខំកសាងសមត្ថភាពអង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរផ្សេងទៀតដើម្បីផ្តល់ឱកាសឱ្យជនមានពិការភាពបានចូលរួមដោយស្មើភាព ក្នុងការអភិវឌ្ឍសហគមន៍របស់ពួកគេប្រកបដោយចីរភាព។

**អង្គការ Epic Arts** ខិតខំធ្វើឱ្យពិភពលោកកាន់តែមានបរិយាបន្នដោយប្រើប្រាស់អនុភាពនៃសិល្បៈដើម្បីផ្លាស់ប្តូរជីវិត និងកសាងសង្គមបរិយាបន្នមួយនៅកម្ពុជាដែលមនុស្សគ្រប់រូប រួមទាំងជនមានពិការភាព ត្រូវបានគេអបអរសម្រាប់លក្ខណៈពិសេសរបស់ពួកគេ។

**អង្គការ Exceed Worldwide** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកស្តារលទ្ធភាពពលកម្ម (ពីមុនហៅថា The Cambodia Trust) ផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាគ្រប់ជ្រុងជ្រោយនៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន ៣ (កំពង់ឆ្នាំង កំពង់សោម និងភ្នំពេញ) និងអង្គភាពអវយវៈសិប្បនិម្មិត ឬរណប នៅតាមមន្ទីរពេទ្យមួយចំនួន។ អង្គការនេះក៏គាំទ្រដល់ការបណ្តុះបណ្តាលគ្រូពេទ្យឯកទេសអវយវៈសិប្បនិម្មិត ឬរណប និងអ្នកបច្ចេកទេសអវយវៈសិប្បនិម្មិត និងរណបនៅមហាវិទ្យាល័យវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណបនៃវិទ្យាស្ថានជាតិសង្គមកិច្ច។ កម្មវិធីអភិវឌ្ឍន៍សហគមន៍របស់ Exceed ផ្តល់លទ្ធភាព និងបង្កើនភាពអង់អាចដល់មនុស្សពេញវ័យ និងកុមារមានពិការភាពក្នុងការទទួលបានការអប់រំ ការងារ ការចាប់ផ្តើមអាជីវកម្មថ្មី និងកសាងជីវិតដែលបរិបូរណ៍ក្នុងនាមជាផ្នែកមួយនៃសហគមន៍របស់ពួកគេ។

**មូលនិធិ Fred Hollows (FHF)** បានធ្វើការងារនៅគ្រប់កម្រិតក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៩៨ លើផ្នែកសុខភាពភ្នែក រួមទាំងតាមរយៈកម្មវិធីបង្ការភាពពិការភ្នែកដែលអាចជៀសវាងបាន។ FHF ធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូសំខាន់ៗផ្សេងទៀតដើម្បីពង្រឹង និងពង្រីកគ្រប់កម្រិតនៃប្រព័ន្ធថែទាំភ្នែកសាធារណៈដែលប្រកបដោយចីរភាព និងប្រសិទ្ធភាពថវិកា រួមទាំងតាមរយៈការផ្ដល់វិវេនតា។

**អង្គការ Humanity & Inclusion (HI)** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកស្តារលទ្ធភាពពលកម្ម ( ពីមុនហៅថា អង្គការជនពិការអន្តរជាតិ ) បានធ្វើការនៅកម្ពុជាតាំងពីឆ្នាំ ១៩៨៧។ បច្ចុប្បន្ន HI ផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ចាម ដើម្បីធានាសេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាព រួមទាំងសេវាចុះផ្សព្វផ្សាយនៅខេត្តកំពង់ចាម និងត្បូងឃ្មុំ។ ក្រៅពីនេះ HI ផ្ដល់សេវាដើម្បីគាំទ្រដល់ការអភិវឌ្ឍកុមារតូច និងបរិយាបន្នសេដ្ឋកិច្ចរបស់ជនមានពិការភាពដើម្បីកាត់បន្ថយភាពក្រីក្រ និងការផាត់ចេញពីសង្គម។

**អង្គការគ្រួសារថ្មី (KT)** បាន និងកំពុងបំពេញការងារតាំងពីឆ្នាំ ១៩៩៤ ដើម្បីគាំទ្រការអប់រំរបស់កុមារគថ្លង់ ឬពិការភ្នែក និងការដាក់បញ្ចូនពួកគេទៅក្នុងសង្គមតាមរយៈបណ្ដាញសាលាអប់រំពិសេសចំនួន ៥។ សាលាទាំងនេះត្រូវបានផ្ទេរទៅក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ ២០១៩។ អង្គការនេះជួយដល់ការអនុវត្តការអប់រំប្រកបដោយគុណភាពនៅវិទ្យាល័យអប់រំពិសេសទាំង ៥ និងថ្នាក់រៀនបរិយាបន្ននៅសាលារដ្ឋ។ អង្គការអនុវត្តសកម្មភាពនានាដើម្បីបង្កើនបរិយាបន្នរបស់កុមារមានពិការភាពក្នុងប្រព័ន្ធអប់រំ និងក្នុងសង្គម តាមរយៈការផ្ដល់ឧបករណ៍រៀនសូត្រដែលបានកែសម្រួល និងការបង្កើនលទ្ធភាពរបស់ពួកគេក្នុងការទទួលបានការបណ្ដុះបណ្ដាល និងការងារ។

**អង្គការធ្វើឱ្យប្រសើរឡើងដល់សេវាព្យាបាលការប្រាស្រ័យទាក់ទង និងលេបអាហារនៅកម្ពុជា (OIC)** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកស្តារលទ្ធភាពពលកម្ម ខិតខំបង្កើតឱ្យមានការគាំទ្រប្រកបដោយចីរភាពសម្រាប់មនុស្សពេញវ័យ និងកុមារដែលមានការលំបាកក្នុងទំនាក់ទំនង និងការលេបអាហារ ដែលជាក្រុមមួយដែលត្រូវបានផាត់ចេញ និងមិនត្រូវបានទទួលស្គាល់ភាគច្រើនក្នុងសេវា និងប្រព័ន្ធដែលមានស្រាប់។ OIC មានបទពិសោធន៍យ៉ាងច្រើនក្នុងការប្រើប្រាស់ចំណេះដឹងបច្ចេកទេសព្យាបាលការនិយាយ សម្រាប់ការពង្រឹងប្រព័ន្ធ និងដើម្បីបំពាក់បំប៉នវិស័យសុខាភិបាល វិស័យអប់រំ និងវិស័យស្តារលទ្ធភាពពលកម្មរបស់កម្ពុជា តាមរយៈការបណ្ដុះបណ្ដាល ការអភិវឌ្ឍធនធាន ការអភិវឌ្ឍគោលនយោបាយ និងការផ្ដល់សេវាដោយផ្ទាល់។

**អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍបរិយាបន្ន (PAfID)** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកបរិយាបន្នពិការភាព ខិតខំលើកកម្ពស់សង្គមបរិយាបន្ន ដែលបើកទូលាយឱកាសចូលរួមក្នុងបរិស្ថានវប្បធម៌ សង្គម និងសេដ្ឋកិច្ចសម្រាប់មនុស្សគ្រប់រូប ជាពិសេសជនមានពិការភាព។ PAfID មានគោលបំណងពង្រឹង និងគាំទ្រសមត្ថភាពរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា អង្គការតំណាងជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។ ក្រៅពីនេះ PAfID ធ្វើការដោយផ្ទាល់ជាមួយជនមានពិការភាពដើម្បីធានាថា ពួកគេអាចទទួលបានសិទ្ធិ និងសម្រេចបានសក្ដានុពលរបស់ខ្លួន។

**សាលារៀនទន្សាយ (Rabbit School)** ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៧ ផ្ដល់ការអប់រំសម្រាប់កុមារដែលមានពិការភាពសតិបញ្ញាក្នុងថ្នាក់រៀនបរិយាបន្ន/ចម្រុះ នៅសាលារៀនចំនួន ១៥ ក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កណ្ដាល និងសៀមរាប។

**អង្គការ Safe Haven** ដែលត្រូវបានបង្កើតឡើងនៅខេត្តសៀមរាបក្នុងឆ្នាំ ២០១០ ធ្វើការតាមរយៈក្រុមការងារពហុវិស័យ ដើម្បីផ្ដល់ការព្យាបាល និងការហ្វឹកហាត់កាយសម្បទាឡើងវិញ (physical and occupational therapy) ការគាំទ្រថែទាំ ការបំប៉នអាហារូបត្ថម្ភ សេវាអភិវឌ្ឍន៍ និងសេវាសង្គមកិច្ចសម្រាប់កុមារដែលមានពិការភាព និងបញ្ហា វេជ្ជសាស្ត្រស្មុគស្មាញដើម្បីឱ្យពួកគេអាចសម្រេចបានសក្ដានុពលពេញលេញ និងភាពម្ចាស់ការក្នុងកម្រិតខ្ពស់។

**អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO)** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ លើកកម្ពស់ការថែទាំសុខភាពផ្លូវចិត្ត និងសុខុមាលភាពចិត្តសង្គម និងតស៊ូមតិឱ្យមានការកែលម្អសេវាថែទាំសុខភាពផ្លូវចិត្តនៅកម្ពុជា។ TPO ផ្ដល់ជម្រើសថែទាំ និងគាំទ្រសុខភាពផ្លូវចិត្តគ្រប់ជ្រុងជ្រោយ តាមរយៈកម្មវិធីមានរចនាសម្ព័ន្ធ

ជាច្រើននៅមជ្ឈមណ្ឌលរបស់ខ្លួនក្នុងរាជធានីភ្នំពេញ និងក្នុងសហគមន៍។ ក្រៅពីនេះ TPO ផ្តល់ជម្រើសបណ្តុះបណ្តាលជាច្រើនសម្រាប់អ្នកជំនាញ ក៏ដូចជាអ្នកដែលចង់កសាង ឬពង្រីកចំណេះដឹង និងជំនាញក្នុងវិស័យសុខភាពផ្លូវចិត្ត។

*អង្គការអន្តរជាតិ*

អង្គការអន្តរជាតិ (IO) ជាច្រើនកំពុងដើរតួនាទីយ៉ាងសកម្មនៅកម្ពុជា តាមរយៈផ្តល់ទាំងអន្តរាគមន៍ផ្អែកតាមពិការភាព ឬតាមរយៈការរួមបញ្ចូលពិការភាពទៅក្នុងកម្មវិធីទូលំទូលាយរបស់ពួកគេ។

**គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC)** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកស្តារលទ្ធភាពពលកម្ម មានវត្តមាននៅកម្ពុជាតាំងពីឆ្នាំ ១៩៩២។ ICRC ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈដល់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទានៅខេត្តបាត់ដំបង និងកំពង់ស្ពឺ។ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាដែលគាំទ្រដោយ ICRC ក៏លើកកម្ពស់បរិយាបន្នសង្គមរបស់ជនមានពិការភាពតាមរយៈការបញ្ជូនបន្ត និងសកម្មភាព លេងកីឡាផងដែរ។ ICRC បានផ្តល់ជំនួយយ៉ាងច្រើនដល់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS) ដូចជា ការអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់ក្រោយឧត្តមសម្រាប់ការព្យាបាលដោយចលនា អាហារូបករណ៍សម្រាប់និស្សិត និងការបណ្តុះបណ្តាលបុគ្គលិកគ្រប់ជ្រុងជ្រោយ។។

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)** ខិតខំគាំទ្រគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា រួមទាំងតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច កំណើនបរិយាបន្ន និងការអភិវឌ្ឍធនធានមនុស្ស។ UNDP រួមចំណែកដល់ការលុបបំបាត់ឧបសគ្គរចនាសម្ព័ន្ធដែលរារាំងបរិយាបន្នសេដ្ឋកិច្ចសង្គម និងការបង្កើនភាពអង់អាចដល់ក្រុមជួបការលំបាក រួមទាំងជនមានពិការភាព តាមរយៈការពង្រីកការគ្របដណ្តប់នៃកិច្ចគាំពារសង្គម។ ក្រៅពីនេះ UNDP ធ្វើការជាមួយក្រសួង និងទីភ្នាក់ងាររាជរដ្ឋាភិបាលកម្ពុជាដើម្បីកសាងសមត្ថភាពក្នុងការពង្រឹងបរិយាបន្នពិការភាព និងពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃដើម្បីវាស់វែងវឌ្ឍនភាព។

**មូលនិធិសហប្រជាជាតិដើម្បីកុមារ** ( **អង្គការយូនីសេហ្វ** ) ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកបរិយាបន្នពិការភាព ផ្តល់ជំនាញបច្ចេកទេសដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីពង្រឹងប្រព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលប្រកបដោយគុណភាព សមធម៌ បរិយាបន្នពិការភាព មានរំញោចយេនឌ័រ និងធន់នឹងអាកាសធាតុ។ ក្រៅពីនេះ អង្គការយូនីសេហ្វផ្តល់ការគាំទ្រផ្នែកបច្ចេកទេសលើបញ្ហានានា ដូចជា ការកំណត់អត្តសញ្ញាណ និងការគ្រប់គ្រងទិន្នន័យពិការភាព ការអប់រំបរិយាបន្ន សុខភាព ទឹកស្អាត និងអនាម័យ កិច្ចគាំពារសង្គម និងការរៀបចំថវិកាបែបបរិយាបន្ន។

**មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA)** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានកាតព្វកិច្ចធានាលទ្ធភាពទទួលបានជាសកលនូវសេវា និងព័ត៌មានស្តីពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។ អង្គការ UNFPA ប្រចាំនៅកម្ពុជា លើកកម្ពស់សិទ្ធិមនុស្ស និងបរិយាបន្នសង្គមរបស់ស្ត្រី និងយុវជនមានពិការភាពក្នុងផ្នែកនានា ដូចជា លទ្ធភាពទទួលបានសេវា ព័ត៌មាន និងការអប់រំស្តីពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសម្រាប់ជនមានពិការភាព រួមទាំងការទប់ស្កាត់ និងការដោះស្រាយអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNOHCHR)** ផ្តល់ជំនួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់ និងគោរពសិទ្ធិមនុស្ស រួមទាំងសិទ្ធិជនមានពិការភាព។ UNOHCHR បានគាំទ្រការតាក់តែងច្បាប់ស្តីពីពិការភាពថ្មី ដើម្បីធានាថា ច្បាប់នោះបន្សុីគ្នាអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងបានផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមេធាវី និងក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត ដើម្បីបង្កើនលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ជនមានពិការភាព។

**អង្គការសុខភាពពិភពលោក (WHO)** ដែលជាដៃគូកម្មវិធី ACCESS 2 ក្នុងផ្នែកស្តារលទ្ធភាពពលកម្ម បានសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ដៃគូអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីលើកកម្ពស់សុខភាព និងសុខុមាលភាពរបស់ប្រជាជនកម្ពុជាទាំងអស់ រួមទាំងជនមានពិការភាព។ WHO ផ្តល់ជំនាញបច្ចេកទេសស្តីពីការពង្រឹងការស្តារលទ្ធភាពពលកម្មក្នុងប្រព័ន្ធសុខាភិបាល និងការអនុវត្ត *ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការគ្របដណ្តប់ សុខភាពជាសកលនៅកម្ពុជា*។

## ឧបសម្ព័ន្ធ ៣ ៖ ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយទូលំទូលាយដើម្បីលើកកម្ពស់បរិយាបន្នពិការភាព

លិខិតុបករណ៍ច្បាប់ និងគោលនយោបាយទូលំទូលាយរបស់កម្ពុជាដែលអាចជួយឱ្យសម្រេចបានបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាពប្រកបដោយប្រសិទ្ធភាព រួមមានរដ្ឋធម្មនុញ្ញ យុទ្ធសាស្ត្របញ្ចកោណ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ២០២៣-២០២៨ *ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ២០២៤-២០៣៥ ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ច្បាប់ស្តីពីកិច្ចការពារសិទ្ធិជនពិការ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០២៤-២០២៨* អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្ត្រអ៊ីនឈាន់។

### *ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយជាតិ*

ច្បាប់កំពូលគឺ***រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*** ឆ្នាំ ១៩៩៣ ដែលត្រូវបានធ្វើវិសោធនកម្ម ៩ ដង ហើយការធ្វើវិសោធនកម្មចុងក្រោយគឺនៅឆ្នាំ ២០២១។ ខណៈដែលច្បាប់នេះមិនសំដៅជាក់លាក់ទៅលើពិការភាព មាត្រា ៣១ ចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។"

***យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព៖ កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០*** បន្តការអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ ដោយកំណត់យកអាទិភាពគន្លឹះ ៥ គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។ គោលបំណងមួយនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ គឺ "ប្រជាជនកម្ពុជារស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុភមង្គល និងទទួលបានការគាំពារសង្គមប្រកបដោយសមធម៌ ស្មើសិទ្ធិ ស្មើឱកាស"។ *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១* គឺជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ច-សង្គមកិច្ចនៃ*កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភាសម្រាប់ការកសាង និងការការពារមាតុភូមិ ឆ្នាំ ២០២៣-២០២៨* និងរួមបញ្ចូលកម្មវិធីគោលនយោបាយអាទិភាពទាំង ៦ នៃកម្មវិធីនយោបាយនេះ។ សកម្មភាពក្រោមកម្មវិធីនយោបាយនេះកំណត់យ៉ាងច្បាស់ថា ជនមានពិការភាពគឺជាផ្នែកមួយនៃក្រុមប្រជាជនងាយរងគ្រោះ។ កម្មវិធីអាទិភាពចំនួន ៣ ក្នុងចំណោមកម្មវិធីអាទិភាពទាំង ៦ មានភាពពាក់ព័ន្ធពិសេសទៅនឹងបរិយាបន្នពិការភាព៖ ការផ្តល់សេវាថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល (UHC) ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសទូទាំងប្រទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងងាយរងគ្រោះ និងការធ្វើស្ថាប័នីយកម្មវិធីសន្តិសុខសង្គមជាតិសម្រាប់គ្រួសារក្រីក្រ សមាជិកងាយរងគ្រោះនៃគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ។

***ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ២០២៤-២០៣៥*** របស់រាជរដ្ឋាភិ-បាលកម្ពុជា ដែលបានចេញផ្សាយនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២៤ បញ្ជាក់ឡើងវិញនូវអាទិភាពទី ១ នៃ*យុទ្ធសាស្ត្របញ្ចកោណ* ហើយនឹងរួមចំណែកដល់គោលដៅ "មិនទុកនរណាម្នាក់ចោល" រួមទាំងជនមានពិការភាព។ *ផែនទីបង្ហាញផ្លូវឆ្ពោះទៅរក UHC* ត្រូវបានរៀបចំឡើងស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPPF)។ ផែនទីបង្ហាញផ្លូវនេះកំណត់មាគ៌ាយុទ្ធសាស្តឆ្ពោះទៅរក UHC នៅអំឡុងឆ្នាំ ២០២៤ ដល់ ២០៣៥ តាមរយៈការកំណត់សកម្មភាពយុទ្ធសាស្ត្រ និងគោលដៅអាទិភាព។ សកម្មភាពយុទ្ធសាស្ត្ររួមមាន ការអភិវឌ្ឍប្រព័ន្ធគាំពារសុខភាពសង្គមជាបណ្តើរៗ ការពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន និងការកាត់បន្ថយការចំណាយពីហោប៉ៅផ្ទាល់ខ្លួនលើសុខភាព ក៏ដូចជាការបង្កើនប្រសិទ្ធភាពក្នុងការចំណាយលើសុខភាព[117]។

---

[117] សម្រាប់ព័ត៌មានបន្ថែម សូមមើល ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ២០២៤-២០៣៥ ដែលរៀបចំឡើងដោយក្រុមប្រឹក្សាជាតិគាំពារសង្គម ខែ មេសា ឆ្នាំ ២០២៤

*ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០* (CSDGs) គឺជាក្របខណ្ឌជាតិដែលផ្អែកលើ *របៀបវារៈ ឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព* (SDGs)។ SDGs បានប្តេជ្ញាមិនទុកនរណាម្នាក់ចោល រួមទាំងជនមានពិការភាព និងក្រុមជួបការលំបាកផ្សេងទៀត និងបានទទួលស្គាល់ថា ពិការភាពគឺជាបញ្ហាឆ្លងវិស័យដែលត្រូវលើកមកពិចារណាក្នុងការអនុវត្តគោលដៅទាំងអស់របស់ខ្លួន។ CSDGs ក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការមិនទុកនរណាម្នាក់ចោលផងដែរ ដើម្បីឱ្យប្រជាជនកម្ពុជាទាំងអស់ទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍ និងវិបុលភាពនាពេលអនាគតរបស់កម្ពុជា។ CSDGs រួមបញ្ចូលគោលដៅបន្ថែមមួយទាក់ទងនឹងសកម្មភាពកម្ចាត់មីន និងជំនួយដល់ជនរងគ្រោះ[118]។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា**



**ប្រភព៖ UNDP កម្ពុជា**

គិតត្រឹមខែតុលា ឆ្នាំ ២០២៤ ***ច្បាប់ស្តីពីកិច្ចការពារសិទ្ធិជនពិការ (ច្បាប់ពិការភាព) ថ្មីដែលផ្អែកលើសិទ្ធិ*** ត្រូវបានធ្វើសេចក្តីព្រាង និងកំពុងរង់ចាំការអនុម័ត។ ច្បាប់ស្តីពីពិការភាពថ្មីនេះ នឹងជំនួសឱ្យច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការឆ្នាំ ២០០៩។ គោលបំណងនៃច្បាប់ស្តីពីពិការភាពថ្មីនេះ ដូចការគូសបញ្ជាក់ក្នុងសេចក្តីព្រាង គឺដើម្បីការពារ លើកកម្ពស់ និងធានាការទទួលបានពេញលេញ និងស្មើភាពគ្នានូវសិទ្ធិ និងសេរីភាពជាមូលដ្ឋានទាំងអស់ដោយជនមានពិការភាពគ្រប់រូប ដោយស្មើភាពជាមួយអ្នកដទៃ។ ច្បាប់នេះព្យាយាមលុបបំបាត់ការរើសអើងគ្រប់បែបយ៉ាងដើម្បីលើកកម្ពស់បរិយាបន្នជនមានពិការភាពយ៉ាងពេញលេញ និងមានប្រសិទ្ធភាព និងការពារសុខុមាលភាពរបស់ជនមានពិការភាពដែលរស់នៅដោយឯករាជ្យ និងសេចក្តីថ្លៃថ្នូរ។ សេចក្តីព្រាងច្បាប់ស្តីពីពិការភាពនេះ គូសបញ្ជាក់ពីការទទួលខុសត្រូវលើបរិយាបន្នពិការភាព ដោយចែងថា «អង្គភាពសាធារណៈ និងអង្គភាពឯកជនពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ ទទួលខុសត្រូវលើការអនុវត្តច្បាប់នេះដោយដាក់បញ្ចូលបទប្បញ្ញត្តិបរិយាបន្នពិការភាពសមស្របទៅក្នុងគោលនយោបាយ កម្មវិធី ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្របតាមផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងឯកសារច្បាប់ដែលទាក់ទងនឹងពិការភាព....[និង] គួរសម្រួលដល់ការចូលរួមពេញលេញរបស់ជនពិការក្នុងការរៀបចំគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌....[119]»។

---

[118] សម្រាប់ព័ត៌មានបន្ថែម សូមមើល *Cambodian Sustainable Development Goals (CSDGs) Framework 2016-2030*, approved by the Council of Minister, 19 November 2018

[119] ច្បាប់ស្តីពីកិច្ចការពារសិទ្ធិជនពិការ ការបកប្រែក្រៅផ្លូវការនៃសេចក្តីព្រាងច្បាប់ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២១

ក្របខណ្ឌសំខាន់មួយដើម្បីពង្រឹងបរិយាបន្នពិការភាព គឺ***ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០២៤-២០២៨*** (NDSP3) ដែលជាក្របខណ្ឌទូទាំងរដ្ឋាភិបាល។ ទិសដៅយុទ្ធសាស្ត្រទាំង ៧ របស់ NDSP3 ឆ្លុះបញ្ចាំងពីអាទិភាពដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា។

### *ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយអន្តរជាតិ*

នៅឆ្នាំ ២០១២ កម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD)។ CRPD លើកកម្ពស់គំរូសង្គមដែលជនមានពិការភាពគឺជាប្រធានបទនៃសិទ្ធិមនុស្ស ដើរតួនាទីយ៉ាងសកម្មក្នុងសេចក្តីសម្រេចដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ និងមានភាពអង់អាចក្នុងការទាមទារសិទ្ធិរបស់ពួកគេ។ CRPD មិនបង្កើតសិទ្ធិថ្មីណាមួយទេ ប៉ុន្តែផ្ទុយទៅវិញវាកំណត់កាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបំពេញសិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិនយោបាយ និងសិទ្ធិសង្គមដែលមានស្រាប់នៅក្នុងបរិបទជាក់លាក់នៃជនមានពិការភាព។

លើសពីនេះ ក្នុងនាមជារដ្ឋសមាជិកនៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (UNESCAP) កម្ពុជាបានអនុម័ត***យុទ្ធសាស្ត្រអ៊ីនឈាន់***នៅខែ វិច្ឆិកា ឆ្នាំ ២០១២ សម្រាប់ជាផ្នែកមួយនៃការចាប់ផ្តើមទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក លើកទី ៣ (២០១៣-២០២៣)។ *យុទ្ធសាស្ត្រអ៊ីនឈាន់* បានផ្តល់នូវគោលដៅអភិវឌ្ឍន៍ប្រកបដោយបរិយាបន្នពិការភាព ដែលត្រូវបានឯកភាពនៅថ្នាក់តំបន់ជាលើកដំបូង។

កម្ពុជាក៏បានអនុម័តសេចក្តីប្រកាសទីក្រុងហ្សាការតាស្តីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ២០២៣-២០៣២ និងបានបន្តការប្តេជ្ញាចិត្តចំពោះយុទ្ធសាស្ត្រអ៊ីនឈាន់ និងសេចក្តីប្រកាសទីក្រុងប៉េកាំង រួមទាំង ***ផែនការសកម្មភាពដើម្បីពន្លឿនការអនុវត្តយុទ្ធសាស្ត្រអ៊ីនឈាន់។ ផែនការមេអាស៊ាន ឆ្នាំ ២០២៥៖ ការបញ្ជ្រាបសិទ្ធិរបស់ជនពិការ*** អះអាងឡើងវិញពីការប្តេជ្ញាចិត្តរបស់រដ្ឋសមាជិកចំពោះបរិយាបន្នពិការភាព។ ផែនការមេនេះរួមមានការប្តេជ្ញាចិត្តចំនួន ២៧ ដែលភ្ជាប់ទៅនឹងគោលការណ៍ទាំង ៨ របស់ CRPD។

# ឧបសម្ព័ន្ធ ៤ ៖ ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយពាក់ព័ន្ធផ្សេងទៀតដើម្បីលើកកម្ពស់បរិយាបន្នពិការភាព

## *ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយថ្នាក់ជាតិផ្សេងទៀត*

ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយថ្នាក់ជាតិផ្សេងទៀតដែលអាចជួយពង្រឹងបរិយាបន្ន សមធម៌ និងសិទ្ធិជនមានពិការភាព រួមមាន *ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្រាប់ការអភិវឌ្ឍសង្គម អតីតយុទ្ធជន និងយុវនីតិសម្បទា ២០២៤-២០២៨* និង *ក្របខណ្ឌត្រួតពិនិត្យកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*។

***ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្រាប់ការអភិវឌ្ឍសង្គម អតីតយុទ្ធជន និងយុវនីតិសម្បទា ២០២៤-២០២៨*** រួមបញ្ចូលយុទ្ធសាស្ត្រដែលលើកកម្ពស់ការបញ្ជ្រាបពិការភាព ក៏ដូចជាអន្តរាគមន៍ផ្អែកលើពិការភាព ដូចជា ការបង្កើនឱកាសការងារ និងសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា។ លើសពីនេះ ***ក្របខណ្ឌត្រួតពិនិត្យកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា*** របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមបញ្ចូលសូចនាករជាក់លាក់ទាក់ទងនឹងកុមារមានពិការភាព។

ផែនការសកម្មភាព ១០ ឆ្នាំដំណាក់កាលទី ២ សម្រាប់ឆ្នាំ ២០២១-២០៣០ ដើម្បីបន្តការអនុវត្ត***កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*** (NP-SNDD2) មានភាពពាក់ព័ន្ធជាពិសេសទៅនឹងអភិបាលកិច្ចមូលដ្ឋាន និងការអភិវឌ្ឍសហគមន៍ដែលមានបរិយាបន្នពិការភាព ដោយកម្មវិធីនេះទទួលស្គាល់តម្រូវការឱកាសស្មើគ្នាសម្រាប់ប្រជាពលរដ្ឋទាំងអស់ក្នុងការចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ NP-SNDD2 គឺប្រជាពលរដ្ឋមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានសេវាសាធារណៈ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋាន ដែលផ្តល់ដោយអាជ្ញាធរថ្នាក់ក្រោមជាតិ ប្រកបដោយសមធម៌ និងបរិយាបន្នសង្គម[120]។

## *សេចក្តីសង្ខេបលិខិតុបករណ៍ច្បាប់ជាតិផ្សេងទៀតដើម្បីពង្រឹងបរិយាបន្នពិការភាព*

| ចំណងជើង | ឯកសារយោង/កាលបរិច្ឆេទ |
|---|---|
| លិខិតរបស់ក្រសួងសុខាភិបាលស្តីពីការផ្តល់សេវាថែទាំសុខភាពដោយឥតគិតថ្លៃសម្រាប់ជនពិការក្រីក្រ | ០០៦ អបស.ឆភស<br>ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ |
| អនុក្រឹត្យស្តីពីកូតាការងារសម្រាប់ជនពិការ (ចំណងជើងពេញ៖ អនុក្រឹត្យស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ) | ១០៨ អនក្រ.បក<br>ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១០ |
| អនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ | ១៣៧ អនក្រ.បក<br>ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ |
| អនុក្រឹត្យស្តីពីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ | ២៩១ ខែ ធ្នូ ឆ្នាំ ២០១១ |
| សារាចរអន្តរក្រសួងស្តីពីផាសុកសមរម្យសម្រាប់ការជ្រើសរើសជនពិការចូលបម្រើការងារ | ០០៥ សអយ.សរណន<br>ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ |
| ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន | ០០១ កសជ.ប្រក<br>ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ |
| ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ ថ្នាក់រាជធានី/ខេត្ត | ០០២ កសជ.ប្រក<br>ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ |
| អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិអប់រំពិសេស | ១១៧/ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ |
| ប្រកាសស្តីពីការបែងចែកប្រាក់ពីក្រសួង គ្រឹះស្ថានសាធារណៈ និងបុគ្គលដែលមិនបានបំពេញការជ្រើសរើសជនពិការនៅស្ថាប័នរបស់ខ្លួន | ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៨ |
| ប្រកាសស្តីពីការអនុវត្តគោលនយោបាយសម្រាប់ជនពិការក្រីក្រនៅក្នុងសហគមន៍ដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មពីរដ្ឋ | ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ |
| ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណពិការភាពដោយផ្អែកលើអភិក្រមសង្គម និងសិទ្ធិ | ខែ សីហា ឆ្នាំ ២០២០ |
| អនុក្រឹត្យអន្តរក្រសួងស្តីពីការផ្តល់បណ្ណបើកបរសម្រាប់ជនមានពិការភាព (ក្រសួងសុខាភិបាល ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) | ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០២០ |

120 សម្រាប់ព័ត៌មានបន្ថែម សូមមើល *www.ncdd.gov.kh/en/*

### *សន្ធិសញ្ញា និងក្របខណ្ឌអន្តរជាតិ*

កម្ពុជាក៏មានកាតព្វកិច្ចក្រោមសន្ធិសញ្ញា និងក្របខណ្ឌអន្តរជាតិផ្សេងទៀត ដែលអាចជួយលើកកម្ពស់សិទ្ធិ និងបរិយាបន្នជនមានពិការភាពផងដែរ។

កម្ពុជាជាប្រទេសហត្ថលេខីនៃ ***សន្ធិសញ្ញាម៉ារ៉ាកេស*** ដែលមានគោលបំណងសម្រួលដល់លទ្ធភាពទទួលបានឯកសារបោះពុម្ពផ្សាយសម្រាប់ជនដែលមានពិការភាពផ្សេងៗ ដែលរារាំងដល់ការអានឯកសារបោះពុម្ពប្រកបដោយប្រសិទ្ធភាព ដូចជា ជនពិការភ្នែក ឬមានកម្សោយគំហើញ  និងជនមានពិការភាពកាយសម្បទាដែលមិនអាចកាន់ឯកសារបោះពុម្ពបាន។

ក្រៅពីនេះ រាជរដ្ឋាភិបាលកម្ពុជាស្ថិតក្រោមកាតព្វកិច្ចអន្តរជាតិដែលអាចអនុវត្តបានចំពោះការដោះស្រាយសិទ្ធិ និងបរិយាបន្នមនុស្សពេញវ័យ និងកុមារដែលមានពិការភាព ក្រោមលិខិតុបករណ៍ផ្សេងៗនៃច្បាប់មនុស្សធម៌ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាគឺជាភាគី មានជាអាទិ៍ ***អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) និងអនុសញ្ញាស្តីពីការហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស (APMBC)***។ មាត្រា ៦.៣ នៃ APMBC តម្រូវឱ្យ «រដ្ឋភាគីនីមួយៗដែលមានលទ្ធភាពត្រូវផ្តល់ជំនួយសម្រាប់ការថែទាំ និងស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មសង្គម និងសេដ្ឋកិច្ចឡើងវិញសម្រាប់ជនរងគ្រោះដោយសារគ្រាប់មីន (...)»។ ក្នុងនាមជារដ្ឋភាគី កម្ពុជាបានទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួនក្នុងការជួយអ្នករស់រានមានជីវិតពីគ្រាប់មីន និងគ្រួសាររបស់ពួកគេនៅក្នុងបរិបទទូលំទូលាយនៃពិការភាព និងការអភិវឌ្ឍ។

## ឧបសម្ព័ន្ធ ៥ ៖ ភាសាដែលមានបរិយាបន្នពិការភាព

តារាងខាងក្រោមបង្ហាញពីភាសាដែលត្រូវបានណែនាំដើម្បីពង្រឹងបរិយាបន្នពិការភាព និងភាសាដែលត្រូវជៀសវាង[121]។

| ភាសាសមស្រប | ភាសាដែលត្រូវជៀសវាង | ភាសាសមស្របជាភាសាខ្មែរ |
|---|---|---|
| person with disability<br>person with [type of impairment]<br>persons with disabilities<br>people with disabilities | disabled person, handicapped, person with special needs, atypical, person living with a disability, differently abled, people of all abilities, people of determination, person living with a disability | ជនមានពិការភាព |
| person without disability<br>the rest of the population | normal, healthy, able-bodied, typical, whole, of sound body/mind | ជនមិនមានពិការភាព<br>ប្រជាពលរដ្ឋទូទៅ |
| have [disability/impairment/condition] | suffer from, afflicted by, stricken by, troubled with | មាន (ពិការភាព ឬកម្សោយ ឬ លក្ខខណ្ឌណាមួយ) |
| person with an intellectual impairment<br>person with an intellectual disability | retarded, simple, slow, afflicted, brain-damaged, intellectually challenged, subnormal, of unsound mind, feeble-minded, mentally handicapped | ជនមានពិការភាពសតិបញ្ញា<br>ជនមានកម្សោយសតិបញ្ញា |
| person with a psychosocial disability | insane, crazy, maniac, psycho, hypersensitive, lunatic, demented, panicked, agitated, mentally deranged, mentally ill | ជនមានពិការភាពចិត្តសង្គម |
| deaf person<br>person who is deaf<br>person with a hearing disability<br>person with a hearing impairment<br>person with hearing loss<br>deafblind person | the deaf, hearing impaired, deaf and dumb, deaf and mute | ជនមានពិការភាពគ ថ្លង់<br>ជនដែលពិការ គ ថ្លង់<br>ជនមានពិការភាពស្តាប់<br>ជនមានកម្សោយក្នុងការថ្លង់ |

[121] *Disability-Inclusive Language Guidelines*, United Nations Office at Geneva, 2021

| ភាសាសមស្រប | ភាសាដែលត្រូវជៀសវាង | ភាសាសមស្របជាភាសាខ្មែរ |
|---|---|---|
| blind person<br>person who is blind<br>person with a vision/visual disability<br>person with a vision/visual impairment<br>person with low vision<br>deafblind person | the blind, partially-sighted | ជនមានពិការភាពភ្នែក<br>ជនមានកម្សោយគំហើញ<br>ជនមានការពិបាកមើល<br>ជនមានពិការភាពគ ថ្លង់ និងភ្នែក |
| person with a physical disability<br>person with a physical impairment | crippled, invalid, deformed, lame, handicapped, physically challenged, person with physical limitations, limp | ជនមានពិការភាពផ្នែករាងកាយ |
| wheelchair user<br>person who uses a wheelchair<br>person with a mobility disability<br>person with a mobility impairment<br>person using a mobility device | confined/restricted to a wheelchair<br>wheelchair-bound | ជនមានពិការភាពប្រើប្រាស់រទេះរុញ<br>ជនមានពិការភាពដែលពិបាកក្នុងការធ្វើការបំលាស់ទី |
| person of short stature<br>little person | midget, dwarf, stunted | ជនមានពិការភាពផ្នែករាងកាយ |
| person with Down syndrome | mongoloid, special person | ជនមានពិការភាពសតិបញ្ញា<br>ជនមានពិការដោនស៊ីនដ្រូម |
| accessible parking<br>parking reserved for persons with disabilities<br>accessible bathroom | disabled/handicapped parking<br>handicapped bathroom | ចំណតអទិភាព ឬចំណតដែលមានផាសុកវត្ថុ<br>ចំណតសម្រាប់ជនមានពិការភាព<br>បន្ទប់ទឹកដែលមានផាសុកវត្ថុ |

## ឧបសម្ព័ន្ធ ៦ ៖ បញ្ជីត្រួតពិនិត្យសម្រាប់កិច្ចប្រជុំ សន្និសីទ និងព្រឹត្តិការណ៍ផ្សេងៗដែលបង្កលក្ខណៈងាយស្រួល[122]

| | សំណួរ | | មតិយោបល់ |
|---|---|---|---|
| | **ការបង្កលក្ខណៈងាយស្រួលផ្នែករូបវន្ត** | | |
| ១ | តើចិញ្ចើមថ្នល់ខាងក្រៅមានកំណល់ជម្រាលដែរ ឬទេ (បើត្រូវការ)? | មែន/ទេ | |
| ២ | តើច្រកចូលមានទំហំធំល្មមដែរ ឬទេ? (យ៉ាងហោចណាស់ ១០០ សម)? | មែន/ទេ | |
| ៣ | តើមានឧបសគ្គអ្វីទេនៅលើកម្រាលឥដ្ឋ ក្បែរច្រកចូល(កំណល់មាត់ទ្វារ ជង្ហុក រន្ធ ក្រឡាចត្រង្គ រណ្តៅ។ល។)? | មែន/ទេ | |
| ៤ | តើមានឧបសគ្គអ្វីទេនៅលើកម្រាលឥដ្ឋ នៅរវាងច្រកចូលបន្ទប់ និងច្រកចូលអគារ (ជណ្តើរ ផ្លូវតូចចង្អៀត វត្ថុលយចេញក្រៅ ដីមិនរាបស្មើ រណ្តៅ ជង្ហុក។ល។)? | មែន/ទេ | |
| ៥ | ចំពោះអ្នកដែលធ្វើដំណើរមកដោយតាក់ស៊ី/ទុកទុក តើមានកន្លែងឡើងចុះនៅក្បែរច្រកចូលធំដែរ ឬទេ (តិចជាង ៣០ ម៉ែត្រ)? | មែន/ទេ | |
| ៦ | ចំពោះអ្នកដែលមកដោយប្រើឡានផ្ទាល់ខ្លួន តើមានចន្លោះចំណតយ៉ាងតិចមួយសម្រាប់ជនមានពិការភាពដែរ ឬទេ? | មែន/ទេ | |
| ៧ | តើមានចំណតធំល្មមដែរ ឬទេ (៣៦០ សមx ៦០០ សម)? | មែន/ទេ | |
| ៨ | តើមានចន្លោះគ្រប់គ្រាន់បន្ថែមពីលើចន្លោះចំណតសម្រាប់ចេញ/ចូលឡាន ឬទេ (១២០ សម)? | មែន/ទេ | |
| ៩ | តើចំណតរថយន្ត ស្ថិតនៅជិតច្រកចូលអគារ ឬទេ (តិចជាង ៥០ ម៉ែត្រ)? | មែន/ទេ | |
| ១០ | តើផ្លូវពីចំណតរថយន្តទៅច្រកចូល គ្មានឧបសគ្គ រាបស្មើ និងធំល្មម ឬទេ (យ៉ាងហោច ១២០ សម)? | មែន/ទេ | |
| ១១ | តើមានជម្រាលនៅពីមុខច្រកចូលធំដែរ ឬទេ (បើត្រូវការ)? | មែន/ទេ | |
| ១២ | តើទ្វារច្រកចូលធំ ងាយស្រួលបើក និងប្រើប្រាស់ដែរ ឬទេ? | មែន/ទេ | |
| ១៣ | តើមានបង្គន់ដែលមានលក្ខណៈងាយស្រួល នៅជិតកន្លែងទទួលភ្ញៀវដែរ ឬទេ? | មែន/ទេ | |
| ១៤ | តើជណ្តើរយន្តប្រអប់ ដែលមានលក្ខណៈងាយស្រួល ស្ថិតនៅជិតកន្លែងទទួលភ្ញៀវដែរ ឬទេ បើមាន? | មែន/ទេ | |
| ១៥ | ប្រសិនបើមានជណ្តើរជើង តើមានជម្រាលដែលមានលក្ខណៈងាយស្រួលដែរ ឬទេ? (ទទឹងយ៉ាងតិច ១២០ សម ចំណោតតិចជាង ៨%) | មែន/ទេ | |
| ១៦ | ប្រសិនបើអគារមានច្រើនជាង ១ ជាន់ តើមានជណ្តើរយន្តប្រអប់ដែលមានលក្ខណៈងាយស្រួលដែរ ឬទេ (រួមទាំងឡៅតឿ)? | មែន/ទេ | |
| ១៧ | តើជណ្តើរយន្តប្រអប់ដែលមានលក្ខណៈងាយស្រួល ភ្ជាប់ទៅកាន់គ្រប់ជាន់ទាំងអស់នៃអគារដែរ ឬទេ (រួមទាំងឡៅតឿ)? | មែន/ទេ | |
| ១៨ | តើមានបង្គន់ដែលមានលក្ខណៈងាយស្រួល យ៉ាងតិចមួយនៅគ្រប់ជាន់ដែរ ឬទេ? | មែន/ទេ | |
| ១៩ | តើទ្វារបង្គន់មានលក្ខណៈងាយស្រួលដែរ ឬទេ? (ចន្លោះទទឹងយ៉ាងតិច ៩០-៩៥ សម មិនពិបាករុញ/ទាញ ឬរអិល ដៃទ្វារស្ថិតនៅកម្ពស់សមរម្យ (៨៥-១១០ សម) | មែន/ទេ | |
| ២០ | តើយើងអាចទៅបង្គន់ដែលមានលក្ខណៈងាយស្រួល ដោយមិនចាំបាច់ឡើងជណ្តើរបាន ឬទេ? | មែន/ទេ | |
| | **ការប្រាស្រ័យទាក់ទង និងសម្ភារៈ** | | |
| ១ | លិខិតអញ្ជើញ/ទម្រង់បែបបទចុះឈ្មោះ ស្នើសុំព័ត៌មានស្តីពីលក្ខខណ្ឌបង្កលក្ខណៈងាយស្រួល | មែន/ទេ | |
| ២ | មានការកក់ទុកអ្នកបកប្រែភាសាសញ្ញា | មែន/ទេ | |
| ៣ | ឯកសារកិច្ចប្រជុំ/ស្លាយ អនុលោមតាមលក្ខខណ្ឌស្តង់ដារស្តីពីការបង្កលក្ខណៈងាយស្រួល | មែន/ទេ | |
| ៤ | មានផ្តល់ឯកសារក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួលផ្សេងទៀត បើត្រូវការ | មែន/ទេ | |

122 Trainer's Manual

# ឧបសម្ព័ន្ធ ៧ ៖ បញ្ជីឈ្មោះអង្គការ និងអ្នកផ្តល់សេវាដែលបានជ្រើសរើសដែលធ្វើការនៅថ្នាក់ក្រោមជាតិ

បញ្ជីឈ្មោះនេះ (អង្គភាព/ស្ថាប័ន គណៈកម្មាធិការ និងអ្នកផ្តល់សេវាដែលបានជ្រើសរើសដែលបំពេញការងារនៅថ្នាក់ជាតិ និង/ឬថ្នាក់ក្រោមជាតិ) បង្ហាញពីការទទួលខុសត្រូវ/សកម្មភាពក្រោមទិសដៅយុទ្ធសាស្ត្រទាំង ៧ នៃ NDSP3។ បញ្ជីឈ្មោះនេះមានគោលបំណងផ្តល់ធនធានសម្រាប់បញ្ជូនជនមានពិការភាពទៅកាន់សេវាសមស្រប និងដើម្បីពង្រឹងបរិយាបន្នពិការភាព។ ឧបសម្ព័ន្ធ ២ ផ្តល់ព័ត៌មានបន្ថែមអំពីអង្គការតំណាងជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ។

| អង្គការ/គណៈកម្មាធិការ/អ្នកផ្តល់សេវា | ទិសដៅយុទ្ធសាស្ត្រ | | | | | | |
|---|---|---|---|---|---|---|---|
| | ការងារ ការជ្រើសរើសឱ្យធ្វើការ និងសន្តិសុខសេដ្ឋកិច្ច | សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព | ការអប់រំ និងការរៀនសូត្រពេញមួយជីវិត | កិច្ចគាំពារសង្គម និងកម្រិតជីវភាពរស់នៅ | សហគមន៍ដែលមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួល | សន្តិសុខ សិទ្ធិ និងយុត្តិធម៌ | ហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ |
| **រដ្ឋបាល/គណៈកម្មាធិការ/អ្នកផ្តល់សេវារដ្ឋ** | | | | | | | |
| ក្រុមប្រឹក្សាឃុំសង្កាត់ | | | | * | * | * | * |
| មន្ទីរ/ការិយាល័យនៃក្រសួងពាក់ព័ន្ធ | * | * | * | * | * | * | * |
| ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី/ខេត្ត | * | * | * | * | * | * | * |
| គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ | * | * | * | * | * | * | * |
| **តំណាងជនមានពិការភាព** | | | | | | | |
| អង្គការតំណាងជនមានពិការភាព/វេទិកាស្ត្រីពិការ | | | | | * | * | |
| អង្គការជនពិការកម្ពុជា | | | | | * | * | |
| សមាគមនៃជនពិការភ្នែកកម្ពុជា (ABC) | | | | | * | | |
| សមាគមជនពិការខ្វះឆ្អឹងខ្នងកម្ពុជា | | | | | * | | |
| **អង្គការមិនមែនរដ្ឋាភិបាល** | | | | | | | |
| អង្គការសកម្មភាពលើពិការភាព និងអភិវឌ្ឍន៍ (ADD) | | | * | | | | |
| អង្គការយែរកម្ពុជា | | | | | | * | |
| មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវវ័យ (CCAMH) | | * | | | | | |

| អង្គការ/គណៈកម្មាធិការ/អ្នកផ្តល់សេវា | ទិសដៅយុទ្ធសាស្ត្រ | | | | | | |
|---|---|---|---|---|---|---|---|
| | ការងារ ការជ្រើសរើសឱ្យធ្វើការ និងសន្តិសុខសេដ្ឋកិច្ច | សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព | ការអប់រំ និងការរៀនសូត្រពេញមួយជីវិត | កិច្ចគាំពារសង្គម និងកម្រិតជីវភាពរស់នៅ | សហគមន៍ដែលមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួល | សន្តិសុខ សិទ្ធិ និងយុត្តិធម៌ | ហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ |
| កម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់ | | * | | | * | | |
| កម្មវិធីសេវាកម្មអភិវឌ្ឍន៍ជនពិការ (DDSP) | | * | | | * | | |
| អង្គការ Epic Arts | | | | | * | | |
| អង្គការ Exceed Worldwide | | * | * | | * | | |
| មូលនិធិ Fred Hollows | | * | | | | | |
| អង្គការ Humanity & Inclusion (HI) | | * | | | * | | |
| អង្គការគ្រួសារថ្មី | | | * | | * | | |
| អង្គការធ្វើឱ្យប្រសើរឡើងដល់សេវាព្យាបាលការប្រាស្រ័យទាក់ទង និងលេបអាហារនៅកម្ពុជា (OIC) | | * | | | | | |
| អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍបរិយាបន្ន | * | | | | * | | |
| សាលារៀនទន្សាយ | | | * | | | | |
| អង្គការ Safe Haven | | * | | | | | |
| អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) | | * | | | | | |
| **អង្គការអន្តរជាតិ** | | | | | | | |
| ICRC | | * | | | * | | |
| UNDP | | | | * | * | * | * |
| UNFPA | | | | | | * | |
| UNICEF | | * | | * | * | | |
| UNOHCHR | | | | | | * | |
| WHO | | * | | | * | | |

# ឧបសម្ព័ន្ធ ៨ ៖ ធនធាន និងឯកសារដែលបានជ្រើសរើស

- *A guide for ensuring inclusion and equity in education*, Education 2030, UNESCO, 2017
- *Accessible meetings and events: a toolkit*, CBM, May 2021
- *Basic Package of Interventions for Rehabilitation: A Toolkit for Primary Care Professionals, Information Sheet*, WHO, 22 August 2024
- *Capacity Building for Local Governance in Cambodia*, World Bank, 2020
- *Changing Perceptions – Empowering teachers: Interpersonal communication and community engagement to support inclusive education*, UNICEF Europe and Central Asia Region, January 2023
- *Disability Inclusion in Gender-Based Violence Programming: promising practices and innovative approaches from UNFPA Asia and the Pacific Country Office*, UNFPA, July 2023
- *Disability Inclusion Trainer's Manual: A guide for supporting training capacity for disability inclusion*, Light for the World, DAC and UNDP
- *Disability Inclusive Budgeting from a Child Rights Perspective: Pathways of Change for UNICEF and Partners*, UNICEF Eastern and Southern Africa Regional Office, Social Policy and Disability Inclusion, Technical Note, March 2024
- *Disability inclusive disaster recovery: Guidance note*, Global Facility for Disaster Reduction and Recovery, 2020
- *Disability Inclusive WASH Practices: Including people with disabilities in UNICEF Water, Sanitation and Hygiene (WASH) Programming*, UNICEF
- *Disability-Inclusive Development Toolkit*, CBM, January 2017
- *Disability-inclusive Disaster Risk Reduction (DIDRR): It is Our Responsibility*, UNESCAP
- *Disability-Inclusive Disaster Risk Reduction (DIDRR): It Is Our Responsibility – Advanced*, UNESCAP
- *Disability-Inclusive Health Services Toolkit: A Resource for Health Facilities in the Western Pacific Region*, WHO Regional Office for the Western Pacific, Manila, Philippines, 2020
- *Disability-Inclusive Health Services Training Package: A Companion to the Disability-Inclusive Health Services Toolkit*, WHO Regional Office for the Western Pacific, Manila, Philippines, 2022
- *Disability-Inclusive Language Guidelines*, United Nations Office at Geneva, 2021
- Finance for All: A Practical Guide to Disability Inclusion for Financial Services Providers in Cambodia, Good Return and Chamroeun Microfinance, March 2023
- Good Practice Guidelines for Engaging with People with Disability, Commonwealth of Australia (Department of Social Services), 2023
- *Guide on Inclusive Technical and Vocational Education and Training (TVET) for People with Disabilities, People in Need and Agile*, 2023
- *Guideline on the process of establishing One-Stop Service Center for survivors of gender-based violence*, MoWA, 2022
- *Guidelines for National Social Assistance Programme Framework for Family Package* (available in Khmer only)
- *Guidelines for National Social Assistance Programme Framework for Emergency Response* (available in Khmer only)

- *Handbook for Trainers on Incorporating Disabilities into Government in Sub-National Administration*, UNICEF and Ministry of Interior, 2016
- How to Design Disability-Inclusive Social Protection, UNESCAP, Bangkok, 2021
- *Inclusive Education – Including children with disabilities in quality learning: what needs to be done?* UNICEF, September 2017
- *The Inclusion Imperative: Towards Disability-inclusive and Accessible Urban Development: Key Recommendations for an Inclusive Urban Agenda*, CBM and Global Network on Disability Inclusive and Accessible Urban Development, 2016
- *International Principles and Guidelines on Access to Justice for Persons with Disabilities*, Special Rapporteur on the rights of persons with disabilities, Committee on the Rights of Persons with Disabilities and Special Envoy of the Secretary-General on Disability and Accessibility, Geneva, 2020
- *Mainstreaming Disability Inclusive Disaster Risk Reduction in Community Development: Guidance for Planning and Practice*, CBM, 2023
- MAKE IT COUNT: Guidance on disability inclusive WASH programme data collection, monitoring and reporting, UNICEF, 2021
- Making lifelong learning a reality: a handbook, Education 2030, UNESCO, 2022
- *Manual for the Identification of Poor Households Procedure*, MoP, 2022
- *National situational analysis and assessment of the impact of the COVID-19 crisis on the rights and wellbeing of persons with disabilities and their access to services and supports*, February 2021
- *Practical Guideline on Legal Aid for Persons with Disabilities in Criminal Justice*, UNDP, 2020 [available in English and Khmer]
- *Practice note: Collecting and using data on disability to inform inclusive development*, Plan International Australia and CBM Australia-Nossal Institute Partnership for Disability Inclusive Development, July 2015
- *Preparation and Development of Commune Development Plans for All*, CDPO and LFTW, December 2020
- *Promoting Disability Inclusion and Information Accessibility in Cambodia*, UNESCO News, 5 April 2024
- *Reasonable accommodation at work – Guidelines and good practices*, Directorate-General for Employment, Social Affairs and Inclusion, European Commission, March 2024
- *Reducing stigma and discrimination against children with disabilities*, UNICEF
- *Social and Behavioural Change Interventions to Strengthen Disability-Inclusive Programming: A synthesis of the evidence*, UNICEF, November 2020
- *Taking action to achieve inclusive WASH*, Global Water and Sanitation Partnership
- Technical Standards on Physical Accessibility Infrastructure for Persons with Disabilities, Disability Action Council Secretariat (DAC-SG), 2018 (unofficial translation)
- What you need to know on lifelong learning, UNESCO, 30 August 2024
- *Women and Young Persons with Disabilities: Guidelines for Providing Rights-Based and Gender-Responsive Services to Address Gender-Based Violence and Sexual and Reproductive Health and Rights*, UNFPA, November 2018



© ACCESS 2

ឯកសារនេះអាចរៀបចំឡើងបានអាស្រ័យដោយមានការណែនាំបច្ចេកទេសពី
លោកស្រី Sheree Bailey AM និងការរួមចំណែកពីដៃគូដែលធ្វើការក្នុងវិស័យបរិយាបន្នពិការភាពនៅកម្ពុជា
ក្រោមជំនួយថវិកាពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS 2

ACCESS 2
Sustainable quality services for all

Australian Aid